**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# មន្ត្រីនគរបាលយុត្តិធម៌ក្នុងនីតិវិធីព្រហ្មទណ្ឌ

ស្រាវជ្រាវពី ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **កញ្ញា. វណ្ណា ហង្សពីរ**
**កញ្ញា. អៀវ គានគឹងសេង**

ដោយសាស្ត្រាចារ្យណែនាំ
លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **វណ្ណា ហ្វាពីរ** និងនាងខ្ញុំឈ្មោះ **អៀរ គានគឹមសេង** គឺជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តជំនាន់ទី២០ ឆ្នាំសិក្សា២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

- លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើតដល់រូបកូនទាំងពីរ និងខិតខំចិញ្ចឹមបីបាច់ថែរក្សាការពារអប់រំទូន្មានប្រៀនប្រដៅរូបកូនទាំងពីរប្រកបដោយព្រហ្មវិហារធម៌ និងបានជួយទំនុកបំរុងកូនទាំងថវិការ ទាំងកម្លាំងចិត្ត ការលើកទឹកចិត្ត ឲ្យកូនទទួលបានការអប់រំដ៏ខ្ពង់ខ្ពស់រហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រប្រកបដោយភាពជោគជ័យគួរជាទីមោទនភាព។
- លោកអ៊ុំ លោកពូ អ្នកមីង បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី ទាំងអស់ដែលបានជួយទំនុកបំរុងទាំងផ្នែកស្មារតី ដោយផ្តល់នូវការលើកទឹកចិត្តដល់រូបយើងខ្ញុំឲ្យខិតខំប្រឹងប្រែងរៀនសូត្រ រហូតឈានដល់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តដល់សព្វថ្ងៃនេះ។
- សូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត លុយ ចណ្ឌា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។
- សូមថ្លែងអំណរគុណដល់ដល់ថ្នាក់ដឹកនាំលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ដល់យើងខ្ញុំ។
- សូមថ្លែងអំណរគុណដល់សាស្រ្តាចារ្យណែនាំ **លោក ជួន ម៉ុនធី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំព្រមទាំងជួយសម្រួល និងកែប្រែសារណារបស់យើងខ្ញុំទាំងពីរនាក់ ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់សូមបួងសួងដល់បារមីនៃវត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមតាមជួយថែរក្សាអស់លោក និងអ្នកមានគុណទាំងឡាយឲ្យជួបប្រទះតែ សេចក្តីសុខ សេចក្តីចម្រើន គ្រប់ពេលវេលាកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាមួយនេះ គឺជាជំនួយទៅដល់អ្នកដែលមានបំណងចង់សិក្សាអំពីវិស័យនីតិសាស្ត្រ ជាពិសេសនោះ គឺមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬមន្ត្រីអនុវត្តច្បាប់ និងនិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រផ្ទាល់តែម្តង។ស្នាដៃនេះនឹងចូលរួមចំណែកមួយក្នុងការពង្រឹងនីតិរដ្ឋនៅក្នុងប្រទេសជាតិ ក៏ដូចជាលើកស្ទួយវិស័យយុត្តិធម៌ តាមរយៈខ្លឹមសារនៃសារណាដែលបង្ហាញជូនជនរួមជាតិ និងសាធារណៈជន នូវមតិទូទៅគោលបំណង ឧត្តមគតិ និងការប្តេជ្ញាចិត្តរបស់យើងខ្ញុំ ក្នុងការពុះពារបម្រើជាតិ និងប្រជាជនគ្រប់កាលៈទេសៈ ព្រមទាំងបង្ហាញឲ្យបានច្បាស់អំពីចក្ខុវិស័យពាក់ព័ន្ធនឹងយុត្តិធម៌ដើម្បីបន្តស្តារ និងការពារមាតុភូមិឲ្យបានរុងរឿងនៃយើងឲ្យឈពោះទៅរកអនាគតមួយយ៉ាងត្រចះត្រចង់ស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរដែលចង់បាននូវភាពយុត្តិធម៌។

គោលបំណងក្នុងការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំ គឺចង់ឲ្យមានការរីកចម្រើននៅក្នុងវិស័យច្បាប់ទាក់ទងនឹងផ្នែកព្រហ្មទណ្ឌ ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តធម៌ ពីព្រោះនៅក្នុងដំណាក់មួយនេះ គឺពឹងផ្អែកទាំងស្រុងទៅលើសមត្ថភាព និងបច្ចេកទេសឬជំនាញមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្ការ និងបង្ក្រាបបទល្មើសដែលបានកើតមានឡើងនានា និងរក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារសង្គមកុំឲ្យមានភាពវឹកវរ ដើម្បីជៀសវាងកុំឲ្យមានភាព អសកម្មនៅក្នុងសង្គមជាតិ។

ក្នុងការសិក្សាស្រាវជ្រាវនេះ ក្រុមយើងខ្ញុំបានព្យាយាមធ្វើដោយយកចិត្តទុកដាក់ជាអតិបរមា យ៉ាងណាធ្វើឲ្យសារណានេះទុកជាប្រយោជន៍ក្នុងការសិក្សាស្រាវជ្រាវរបស់ពលរដ្ឋខ្មែរគ្រប់រូប មន្ត្រីនគរបាលដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ឬជាភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការភ្នាក់ងាសាធារណៈដទៃទៀតដែលមាននីតិសម្បទា ជាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន ពិសេសជាងនេះទៅទៀតសម្រាប់និស្សិតជំនាន់ក្រោយដែលមានបំណងស្វែងយល់អំពីមន្ត្រីនគរបាលយុត្តិធម៌ក្នុងរឿងក្តីព្រហ្មទណ្ឌ។

ដោយសារណានេះជាស្នាដៃដំបូងរបស់ខ្ញុំយើងខ្ញុំហេតុនេះ យើងខ្ញុំជឿជាក់ថាអាចមានភាពចន្លោះខ្វះខាត និងមានកំហុស ខ្លះៗជាក់ជាមិនខានឡើយ។ ដូច្នេះយើងខ្ញុំរងចាំទទួលនូវរាល់ការរិះគន់ដើម្បីកែលម្អដោយក្តីសោមនស្ស ក្នុងន័យស្ថាបនាចំពោះស្នាដៃនេះគ្រប់ពេលវេលា។ យើងខ្ញុំសូមសម្តែងនូវសេចក្តីគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុតដល់ជនរួមជាតិនៅគ្រប់ទិសទី ដែលបានផ្តល់ជំនឿ និងការគាំទ្រយ៉ាងធំធេងដល់ស្នាដៃនេះ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**........................................................................................................១

## ជំពូកទី១

## សមាសភាពរបស់នគរបាលយុត្តិធម៌

**ផ្នែកទី១៖ មន្ត្រីនគរបាលយុត្តិធម៌** .......................................................................... ៥

កថាខណ្ឌទី១៖ លក្ខខណ្ឌដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌.............................៥

១.១ ការទទួលបានតាមរយៈឋានន្តរស័ក្តិ..............................................................................៥

១.២  ទទួលបានតាមរយៈការប្រឡងប្រជែង ..........................................................................៦

១.៣-ការទទួលបានដោយស្វ័យប្រវត្តិ .................................................................................៦

កថាខណ្ឌទី២៖ ការកំណត់សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌..................................................៨

២.១-សមត្ថកិច្ចដែនដី ..........................................................................................................៨

២.២   សមត្ថកិច្ចសម្ភារៈ (សមត្ថកិច្ចតាមសាច់រឿង) ..........................................................៩

២.៣-អំណាចរបស់នគរបាលយុត្តិធម៌......................................................................................៩

២.៤-ការពន្លាតសមត្ថកិច្ចដែនដី ......................................................................................... ១០

២.៥-កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច..................................................................... ១០

**ផ្នែកទី២៖ ភ្នាក់ងារនគរបាលយុត្តិធម៌**..........................................................................១០

២.១ ការទទួលគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ ....................................................... ១១

២.២ សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌......................................................................... ១១

២.៣ បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌..................................................................... ១១

២.៤ សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ ..................................................................... ១១

២.៥ កំហុសដែលត្រូវបានប្រព្រឹត្តនៅពេលបំពេញមុខងារ ......................................................... ១២

**ផ្នែកទី៣៖ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន**................................................................................................១២

កថាខណ្ឌទី១៖ ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមួយចំនួន.........................១២

១.១ តាមរយៈច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ...........១៣

១.២ តាមរយៈច្បាប់ស្តីពីព្រៃឈើ..........................................................................................១៣

កថាខណ្ឌទី២៖ ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងាសាធារណៈដទៃទៀត ..................... ១៣
២.១ បុគ្គលដែលមានអំណាចក្នុងការតែងតាំង ..................... ១៣
២.២ សេចក្តីសម្រេចក្តីក្នុងការតែងតាំង ..................... ១៤
កថាខណ្ឌទី៣៖ សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ..................... ១៤
៣.១ ទីកន្លែងដែលត្រូវធ្វើសម្បថ ..................... ១៤
៣.២ នត្ថិភាពនៃអញ្ញាត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត.. ១៥
កថាខណ្ឌទី៤៖ កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតក្នុងពេលបំពេញមុខងារ .. ១៥
៤.១ នីតិវិធីខាងវិន័យ ..................... ១៥
៤.២ ទណ្ឌកម្មចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ..................... ១៦

## ជំពូក២

## ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

**ផ្នែកទី១៖ អំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង** ..................... ១៧
កថាខណ្ឌទី១៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ..................... ១៧
១.១ និយមន័យនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង ..................... ១៨
១.២ កិច្ចនានានៃការស៊ើបអង្កេតនៅក្នុងបទល្មើសជាក់ស្តែង ..................... ១៨
១.២.១ វិធានការដំបូងក្នុងករណីបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង ..................... ១៩
១.២.២ ការឆែកឆេរ ..................... ១៩
១.២.៣ ការបិទស្លាកបោះត្រាលើវត្ថុតាង ..................... ២០
១.២.៤ ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ..................... ២១
១.២.៥ កំណត់ហេតុស្តាប់ចម្លើយ និងការបញ្ជាឲ្យចូលខ្លួន ..................... ២១
១.៣ ការឃាត់ខ្លួន ..................... ២២
១.៣.១ លក្ខខ័ណ្ឌដែលត្រូវគោរពដើម្បីធ្វើការឃាត់ខ្លួន ..................... ២២
១.៣.២ រយៈពេលនៃការឃាត់ខ្លួន ..................... ២៣
១.៣.៣ ការឃាត់ខ្លួនចំពោះអនីតិជន ..................... ២៤
១.៣.៤ សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន ..................... ២៥
១.៣.៥ បញ្ជីនៃការឃាត់ខ្លួន ..................... ២៥
១.៣.៦ កំណត់ហេតុសរុបនៃការឃាត់ខ្លួន ..................... ២៦

១.៤. ការបញ្ជូនខ្លួន..............................................................................................................២៧
ក. ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន ..............................................................២៧
ខ. រយៈពេលនៃការបញ្ជូនខ្លួន....................................................................................២៧
១.៥ វិធានការទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង.........................................................២៨
១.៥.១ ការហាមឃាត់មិនឲ្យស្តាប់ចម្លើយ ..........................................................................២៨
១.៥.២ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា...................................................................២៨
១.៥.៣ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ ..................................................................២៩
កថាខណ្ឌទី២៖ ការស៊ើបអង្កេតក្នុងករណីមិនជាក់ស្តែង .............................................................២៩
២.១ អត្ថន័យបទល្មើសមិនជាក់ស្តែង ..........................................................................................៣០
២.២ ការឆែកឆេរ ..................................................................................................................... ៣២
២.៣ ការបញ្ជោឲ្យចូលខ្លួន........................................................................................................ ៣២
២.៤ ការឃាត់ខ្លួនជនសង្ស័យ ..................................................................................................... ៣៣
២.៥ កំណត់ហេតុក្នុងការស្តាប់ចម្លើយ ......................................................................................... ៣៣
កថាខណ្ឌទី៣៖ ការបញ្ចប់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ........................................... ៣៣
កថាខណ្ឌទី៤៖ ការបញ្ជូនខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌..............................................................៣៤
១. ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម ...........................................................៣៥
២. ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ ..............................................៣៥
៣. ការនាំខ្លួនជនជាប់ចោទទោបង្ហាញខ្លួនរយៈដីកាបញ្ជូន ឬសាលដីកាបញ្ជូន.....................៣៥
៤. ការធ្វើជាសាក្សីរបស់នគរបាលយុត្តិធម៌.................................................................................៣៥
៥. ការធានាសណ្តាប់ធ្នាប់នៃសវនាការ.......................................................................................៣៦
៦. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ...................................................................៣៦
៧. ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាល់ចំពោះសាលក្រមកំបាំងមុខ...........................៣៦
៨. ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ ..............................៣៦
**ផ្នែកទី២៖ បេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌នៅពេលមានដីកាចាត់ឲ្យស៊ើបសួរជំនួស**..៣៧
កថាខណ្ឌទី១៖ ដីកាចាត់ឲ្យស៊ើបសួរជំនួស.................................................................................. ៣៧
១. មូលហេតុនៃការស៊ើបសួរជំនួស.......................................................................................... ៣៧
កថាខណ្ឌទី២៖ បេសកកម្មនៅសាលាឧទ្ធរណ៍............................................................................. ៣៧

កថាខណ្ឌទី៣៖ សិទ្ធិអំណាចមន្ត្រីនគរបាលយុត្តិធម៌ក្នុងពេលអនុវត្តដីការ ចាត់ឲ្យ ស៊ើបសួរជំនួស....៣៩
១. បុព្វសិទ្ធិមន្ត្រីនគរបាលយុត្តិធម៌ ....................................................................................៣៩
២. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការកោះហៅ និងស្តាប់ចម្លើយសាក្សី ............៣៩
៣. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង................. ៤០
៤. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឃាត់ខ្លួន............................................. ៤០
៥. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស្តាប់ទូរសព្ទ ជាអាទិ៍............................ ៤១
កថាខណ្ឌទី៤៖ កាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីការរបស់តុលាការ............... ៤១
១. ការរក្សាការសម្ងាត់នៃការស៊ើបសួរ.................................................................................... ៤១
២. ការចាប់បង្ខំសាក្សីឲ្យចូលបង្ហាញខ្លួន ..............................................................................៤២
៣. ការរក្សាការសម្ងាត់នៃការស៊ើបសួរ ..................................................................................៤២
៤. ការជូនដំណឹងអំពីដីការបង្គាប់ឲ្យចូលខ្លួន .......................................................................៤៣
៥. ការអនុវត្តដីការបង្គាប់ឲ្យនាំខ្លួន.......................................................................................៤៣
៦. ការអនុវត្តដីការបង្គាប់ឲ្យចាប់ខ្លួន ...................................................................................៤៣
៧. ការអនុវត្តដីការកោះហៅ ឬដីការផ្សេងៗ ទៀត ................................................................ ៤៤
**ផ្នែកទី៣៖ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅដំណាក់កាលជំនុំជម្រះ**..................... ៤៥
កថាខណ្ឌទី១៖ បេសកកម្មនៅសាលាដំបូងរាជធានី - ខេត្ត ..................................................... ៤៥
១. ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់.................................................... ៤៥
២. ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម ........................................................ ៤៥
៣. ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ ........................................ ៤៥
៤. ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនរយៈដីកាបញ្ជូន ឬសាលដីកាបញ្ជូន ..................... ៤៥
៥. ការធ្វើជាសាក្សីរបស់នគរបាលយុត្តិធម៌ .......................................................................... ៤៦
៦. ការធានាសណ្តាប់ធ្នាប់នៃសវនាការ.................................................................................. ៤៦
៧. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ............................................................. ៤៦
៨. ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាល់ចំពោះសាលក្រមកំបាំងមុខ .......................... ៤៦
កថាខណ្ឌទី២៖ បេសកកម្មនៅសាលាឧទ្ធរណ៍.......................................................................៤៧
១. ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ ..............................៤៧
២. ការប្រគល់ដីកាកោះហៅ.................................................................................................៤៧

កថាខណ្ឌទី៣៖ បេសកកម្មនៅតុលាការកំពូល...................................................................................៤៧
**ផ្នែកទី៤៖ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ និងនីតិវិធីដោយឡែក**..........៤៨
កថាខណ្ឌទី១៖ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ ......................................................... ៤៨
១. កាធានារ៉ាប់រងការអនុវត្តទោស................................................................................................ ៤៨
២. ការស្នើសុំពិនិត្យបញ្ជី និងបង្ហាញជនជាប់ឃុំ.................................................................... ៤៩
៣. ការជូនដំណឹង ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិតក្នុងករណីបង្ខំដល់រូបរាងកាយ ............... ៤៩
កថាខណ្ឌទី២៖ បេសកកម្មនៅដំណាក់កាលនីតិវិធីដោយឡែក................................................... ៤៩

## ជំពូកទី៣

## បេសកកម្មរបស់មន្ត្រីរាជការនៅកន្លែងកើតហេតុ

**ផ្នែកទី១៖ បេសកកម្មទៅកាន់កន្លែងកើតហេតុ**.............................................................៥១
កថាខណ្ឌទី១៖ គោលបំណងនៃការស៊ើបអង្កេតកន្លែងកើតហេតុ................................................. ៥១
កថាខណ្ឌទី២៖ ដំណើរទៅកាន់កន្លែងកើតហេតុ........................................................................... ៥១
កថាខណ្ឌទី៣៖ ដំណើរទៅកាន់កន្លែងកើតហេតុ...........................................................................៥២
ក. ការចាត់ចែងបឋមនៅកន្លែងកើតហេតុ........................................................................................៥៣
ខ. វិធានការសណ្តាប់ធ្នាប់សាធារណៈ..............................................................................................៥៣
គ. ការពិនិត្យកន្លែងកើតហេតុ និងទីកន្លែងជុំវិញ......................................................................... ៥៤
កថាខណ្ឌទី៤៖ តួនាទី និងការទទួលខុសត្រូវនៅកន្លែងកើតហេតុ ............................................. ៥៥
១.មន្ត្រីកាន់កាប់បញ្ជីកត់ត្រាកន្លែងកើតហេតុ ................................................................................ ៥៥
២. មន្ត្រីថតរូប ឬថតវីឌីអូនៅកន្លែងកកើតហេតុ ........................................................................... ៥៦
៣. មន្ត្រីគំនូសប្លង់កន្លែងកើតហេតុ ................................................................................................ ៥៦
៤. មន្ត្រីឆែកឆេ និងរឹបអូស............................................................................................................. ៥៦
៥. មន្ត្រីគ្រប់គ្រងវត្ថុតាង ..............................................................................................................៥៧
**ផ្នែកទី២៖ បច្ចេកទេសក្នុងការប្រមូល និងរក្សាទុកវត្ថុតាង**........................................... ៥៧
កថាខណ្ឌទី១៖ ការប្រមូលវត្ថុតាងជាសំលៀកបំពាក់.................................................................... ៥៨
កថាខណ្ឌទី២៖  ការប្រមូលវត្ថុតាងជាឯកសារ ............................................................................... ៥៨
កថាខណ្ឌទី៣៖  ការប្រមូលវត្ថុតាងជាអេឡិចត្រូនិក...................................................................... ៥៩
កថាខណ្ឌទី៤៖ ការប្រមូលវត្ថុតាងជាវត្ថុដែលមុតស្រួច.................................................................. ៥៩

កថាខណ្ឌទី៥៖ ការប្រមូលវត្ថុតាងជាស្លាកស្នាមផ្សេងៗ ........................................................................ ៦០
កថាខណ្ឌទី៦៖ ការប្រមូលវត្ថុតាងជាស្នាមម្រាមដៃ ........................................................................ ៦០
កថាខណ្ឌទី៧៖ ការប្រមូលភស្តុតាងជា ឌី អ៊ីន អេ (DNA) ........................................................................ ៦១
១.សញ្ញាណទូទៅនៃ ឌី អ៊ិន អេ (DNA) ........................................................................ ៦១
២. ការប្រមូល និងថែរក្សា ឌី អ៊ិន អេ (DNA) ........................................................................ ៦២
កថាខណ្ឌទី៨៖ ការបិទកន្លែងកើតហេតុ ........................................................................ ៦៣
១.ការបិទកន្លែងកើតហេតុជាស្ថាពរ ........................................................................ ៦៣
២.ការបិទកន្លែងកើតហេតុជាបណ្ដោះអាសន្ន ........................................................................ ៦៤
កថាខណ្ឌទី៩៖ ការគ្រប់គ្រងកំណត់ហេតុ ........................................................................ ៦៤
**ផ្នែកទី៣៖ បេសកម្មក្នុងការស្វែងរកជនល្មើស** ........................................................................ ៦៥
កថាខណ្ឌទី១៖ ការស្វែងរកតាមរយៈការសម្ភាសន៍សាក្សី និងជនរងគ្រោះ ........................................................................ ៦៥
កថាខណ្ឌទី២៖ ការស្វែងរកតាមរយៈការសួរចម្លើយជនសង្ស័យ ........................................................................ ៦៦
កថាខណ្ឌទី៣៖ ការស្វែងរកតាមរយៈស្ទង់មតិតាមផ្ទះ ........................................................................ ៦៦
កថាខណ្ឌទី៤៖ ការការពារសាក្សី ........................................................................ ៦៦
១. មូលហេតុនៃការការពារសាក្សី ........................................................................ ៦៦
២.វិធានការណ៍ក្នុងការការពារសាក្សី ........................................................................ ៦៧

## ជំពូកទី៤

## ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

**ផ្នែកទី១៖ បញ្ហាប្រឈម** ........................................................................ ៦៨
កថាខណ្ឌទី១៖ ការធ្វេសប្រហែសគួបផ្សំ និងការខ្វះសម្ភារៈមធ្យោបាយ ........................................................................ **៦៨**
១.១ ការងារមួយចំនួនអសកម្ម ........................................................................ ៦៨
១.២ ការចាត់តាំងអនុវត្ត ........................................................................ ៦៨
១.៣ កាងារស៊ើបអង្កេត និងការបង្ក្រាប ........................................................................ ៦៨
១.៤ ការខ្វះមធ្យោបាយ ........................................................................ ៦៨
កថាខណ្ឌទី២៖ អាណាព្យាបាលរបស់មន្ត្រីនគរបាលយុត្តិធម៌ ........................................................................ ៦៨
២.១ គោលការណ៍ច្បាប់ ........................................................................ ៦៩
កថាខណ្ឌទី៣៖ សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ ........................................................................ ៦៩

**ផ្នែកទី២៖ ដំណោះស្រាយ**........................................................................................................៧០
កថាខណ្ឌទី១៖ យន្តការបណ្តុះបណ្តាលជំនាញ និងច្បាប់ ......................................................៧០
កថាខណ្ឌទី២៖ យន្តការពង្រឹងការអនុវត្តច្បាប់ ....................................................................៧០
២.១ ការលុបបំបាត់អំពើពុករលួយ ......................................................................................៧០
២.២ ការលុបបំបាត់វប្បធម៌អន្តរាគមន៍ .................................................................................៧០
២.៣ ការលុបបំបាត់វប្បធម៌និទណ្ឌភាព..................................................................................៧១
**សេចក្តីសន្និដ្ឋាន**..........................................................................................................................៧២
**អនុសាសន៍**................................................................................................................................ ៧៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ជាការពិតណាស់អំពើដែលល្មើសនឹងច្បាប់ព្រហ្មទណ្ឌ គឺជាបទល្មើស ម៉្យាងវិញទៀតបទល្មើសព្រហ្មទណ្ឌជាអំពើទាំងឡាយណា ដែលបង្កគ្រោះថ្នាក់ដល់សង្គមជាតិ ហើយអំពើទាំងនោះ គឺជាការបំពានទៅច្បាប់ព្រហ្មទណ្ឌ។ បទល្មើសដែលកើតមានឡើង ឬថយចុះវាអាស្រ័យទៅជំនាញ ឬសមត្ថភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងបច្ចេកទេស នៃការស៊ើបអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងបច្ចេកទេសនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ថា តើការប្រព្រឹត្តទៅស្របតាមវិជ្ជាជីវៈដែរឬទេ? ហើយវាស្រូបទៅនឹងអ្វីដែលចែងនៅក្នុងច្បាប់ដែរឬទេ?ជាក់ស្តែង ការស្វែងរកប្រមូលនូវភស្តុតាង ការសាកសួរ ការឃាត់ខ្លួន ការចាប់ខ្លួនការបញ្ជូនខ្លួន គឺជាបច្ចេកទេសរបស់មន្ត្រីនគរបាល យុត្តិធម៌ហើយមន្ត្រីនគរបាលយុត្តិធម៌ មានតួនាទីសម្រាប់ធ្វើការស៊ើបអង្កេត និងស្វែងរកបទល្មើសព្រមទាំងបង្ការ និងបង្ក្រាបបទល្មើសនៅក្នុងសង្គមជាតិជាតិ។ ម៉្យាងវិញទៀតយុត្តិសាស្ត្រ ឬបច្ចេកទេសរបស់មន្ត្រីនគបាលនេះ គឺជាមូលដ្ឋានសម្រាប់ធ្វើការស្វែងរកនូវភាពយុត្តិធម៌ជូនសង្គមព្រមទាំងជនរងគ្រោះឲ្យមានតម្លាភាព។

ដើម្បីឲ្យការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ មានប្រសិទ្ធភាព និងភាពជោគជ័យនោះ ត្រូវមានដំណោះស្រាយ មួយចំនួន ហើយដំណោះស្រាយនោះ គឺមានការពាក់ព័ន្ធទៅនឹងសិទ្ធ និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងសិទ្ធ និងកាតព្វកិច្ចរបស់ជនសង្ស័យ សាក្សី ឬក៏ជាជនរងគ្រោះ។

នៅក្នុងប្រធានបទមួយនេះ គឺមានវិសាលភាពគ្របដណ្តប់ទៅលើបទល្មើសព្រហ្មទណ្ឌណាមួយដែលកើតឡើងរហូត ដល់ដំណាក់ការស៊ើបអង្កេតរបស់មន្ត្រីនគាបាលយុត្តិធម៌ និងស្ថាប័ននគបាលយុត្តិធម៌ ដែលមានចែងយ៉ាង ច្បាស់លាស់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ វាមានវិសាលភាពគ្របដំណ្តប់ទូទាំងប្រទេសកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីឆ្នាំ២០០៧ ដែលក្រមនីតិវិធីព្រហ្មទណ្ឌ បានចូលជាធមានរហូតដល់បច្ចុប្បន្ន។

ការស្រាវជ្រាវលើប្រធានបទមួយនេះ គឺមានអត្ថប្រយោជន៍សម្រាប់ប្រជាពលរដ្ឋខ្មែរ និងសិស្សនិស្សិតដែលមានបំណងចង់ស្វែងយល់នូវចំណេះដឹងទូទៅ នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។ ជាពិសេស សម្រាប់អ្នកធ្វើការស្រាវជ្រាវ និងអ្នកសិក្សាផ្នែកនីតិសាស្ត្រផងដែរ។

ដោយហេតុថាសារណារបស់ក្រុមយើងខ្ញុំនេះលើកយកតែដំណាក់កាល ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌តែប៉ុណ្ណោះ។ អាស្រ័យនេះក្រុមហើយក្រុមរបស់យើងខ្ញុំព្យាយាមពន្យល់ លម្អិតអំពីការ ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ក្នុងដំណាក់កាលព្រហ្មទណ្ឌ ក្នុងដំណាក់កាលមន្ត្រីនគបាលយុត្តិធម៌។ នៅក្នុងខ្លឹមសារនៃប្រធានមួយនេះ ត្រូវបានចែងជា៤ជំពូក ដែលនៅក្នុងជំពូកទី១ និយាយអំពី សមាសភាពរបស់នគរបាលយុត្តិធម៌ ហើយក៏បានចែកចេញជា៣ ផ្នែកទៀត គឺផ្នែកទី១ មន្ត្រីនគរបាលយុត្តិធម៌ ផ្នែកទី២ ភ្នាក់ងារនគរបាលយុត្តិធម៌ និងផ្នែក៣ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទា

ពិសេសសម្រាប់ពិនិត្យបទល្មើសមួយចំនួន ចំណែកឯ ជំពូក២វិញ បកស្រាយអំពី ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានធ្វើការបែងចែកជា២ផ្នែក គឺផ្នែកទី១ សិទ្ធិអំណាចនៅក្នុងការស៊ើបអង្កេត និងផ្នែកទី២ បេសកម្មរបស់នគរបាលយុត្តិធម៌ពេលមានដីកា ចំពោះជំពូក៣វិញ ពណ៌នាអំពី ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ ដោយបានចែកចេញជា០២ផ្នែកផងដែរ គឺផ្នែកទី១ បញ្ហាប្រឈម និងផ្នែកទី២ ដំណោះស្រាយ និងជំពូកទី៤ បង្ហាញពី បេសកកម្មរបស់ទៅកាន់កន្លែងកើតហេតុ ផ្នែកទី២ បច្ចេកទេសក្នុងការប្រមូល និងរក្សាទុកវត្ថុតាង ផ្នែកទី៣ បេសកកម្មក្នុងការស្វែងរកជនល្មើស ដែលក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយទៅតាមចំនុចនីមួយៗទៅតាមការកំណត់ខាងលើ។

## នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់អំណាចតុលាការ (មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង។

ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីកាចាត់ចែងឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ (មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌដាក់នគរបាលយុត្តិធម៌ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ (មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

# ជំពូកទី១

# សមាសភាពរបស់នគរបាលយុត្តិធម៌

# ជំពូកទី១

# សមាសភាពរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់អំណាចតុលាការ (មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង[1]។

ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីកាចាត់ចែងឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ (មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ[2])។ ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌដាក់នគរបាលយុត្តិធម៌ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ (មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)[3]។

## សមាសភាពនគរបាលយុត្តិធម៌

មាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ពីសមាសភាពរបស់នគរបាលយុត្តិធម៌ដូចតទៅៈ

- មន្ត្រីនគរបាលយុត្តិធម៌
- ភ្នាក់ងារនគរយុត្តិធម៌
- មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន[4]។

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយមានអំណាចលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត កាលណាមន្ត្រីនេះបំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌។

ក្រៅពីនេះ នគរបាលយុត្តិធម៌ក៏ត្រូវស្ថិតនៅក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ផងដែរ ដោយអគ្គព្រះរាជាអាជ្ញាអមសាលាឧទ្ធរណ៍មានសិទ្ធិអនុវត្តអំណាចខាងវិន័យទៅលើនគបាលយុត្តិធម៌បាន (មាត្រា៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ បន្ទាប់ពីមានការរាយការណ៍ពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរដោយអគ្គព្រះរាជអាជ្ញាប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីផ្តើម

1.មាត្រា ៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

2.មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

3.មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

4.មាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ដំណើរ ការនីតិវិធីន័យ (មាត្រា៦៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)[5]។ ក្រៅពីនេះ អគ្គព្រះរាជអាជ្ញាក៏អាចចេញវិធានការវិន័យដោយផ្ទាល់ទៅលើមន្ត្រីនគរបាលយុត្តិធម៌ដែរ ក្នុងករណីមានកំហុសធ្ងន់ធ្ងរ ក្រៅពីកោះហៅមន្ត្រីនគរបាលយុត្តិធម៌នោះមកផ្តល់សេចក្តីសង្កេតរួចមក។

ក្រៅពីនេះ នគរបាលយុត្តិធម៌មានតួនាទីផ្តល់ព័ត៌មានយ៉ាងសំខាន់ ដោយត្រូវជូនដំណឹងដល់អាជ្ញាធរតុលាការដែលមានអយ្យការ និងចៅក្រមស៊ើបសួរ អំពីហេតុដែលខ្លួនបានដឹង។

ចំពោះការបង្កើតនគរបាលយុត្តិធម៌ ច្បាប់បានប្រើប្រាស់នូវបច្ចេកទេសគតិយុត្តសាមញ្ញមួយ។ ជាអាទិ ច្បាប់បានបង្កើតសមត្ថភាពដែលអាចប្រែប្រួលបានរបស់នគរបាលយុត្តធម៌(ខ)ហើយបែងចែកសមត្ថភាពនេះរវាង ភ្នាក់ងាររដ្ឋបាលផ្សេងៗដែលមានស្រាប់។

## ការរៀបចំទូទៅរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ត្រូវបែងចែកតាមឋានានុក្រមជាបីប្រភេទ៖ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យពិនិត្យកត់ត្រាបទល្មើសមួយចំនួន។

## ផ្នែកទី១៖ មន្ត្រីនគរបាលយុត្តិធម៌

### កថាខណ្ឌទី១៖ លក្ខខណ្ឌដើម្បីទទួលបានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីរាជការចំនួនបីជំពូកអាចទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ជាអាទិ៍ៈ

#### ១.១ ការទទួលបានតាមរយៈឋានន្តរស័ក្ក

-នៅក្នុងក្រមខ័ណ្ឌនគរបាលជាតិ អ្នកដែលមានឋានៈជាមន្ត្រីនគរបាលយុត្តិធម៌គឺ នាយនគរបាល ដែលមានឋានន្តរស័ក្កចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចពីរឆ្នាំក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។ នាយនគរបាលជាតិ ដែលមានវិញ្ញាបនប័ត្របញ្ជាក់ការសិក្សាស្តីពីមន្ត្រីនគរបាលយុត្តិធម៌ មុនពេលក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌[6]។

-ក្នុងកងរាជអាវុធហត្ថ អ្នកដែលមានឋានៈជានគរបាលយុត្តិធម៌ គឺនាយទាហាន នៃកងរាជអាវុធហត្ថដែលបានបំពេការងារយ៉ាងតិចពីរឆ្នាំក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរ បាលយុត្តិធម៌។ នាយទាហាននៃកងរាជអាវុធហត្ថដែលមានវិញ្ញាប័ត្រនៃមន្ត្រីប៉ូលីសតុលាការមុន

5.មាត្រា ៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

6.មាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមរបស់ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌ ។

បន្ទាប់ពីក្រមនេះចូលជាធរមាន ដើម្បីទទួលបាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបំពេញលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា៦០។រដ្ឋមន្ត្រីអាណាព្យាបាលនៃមន្ត្រីនគរបាល ឬជាអាណាព្យាបាលនៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមានចែងនៅក្នុងចំណុចទី១ ទី២ និងទី៣ នៃមាត្រានេះមានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយណាដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ១.២ ទទួលបានតាមរយៈការប្រឡងប្រជែង

មាត្រា៦១ បានជែងបន្ថែមថា ចំពោះមន្ត្រីនគរបាលយុត្តិធម៌ក្នុងជំពូកទាំងពីរដំបូងនេះ សញ្ញាប័ត្រជាន់ខ្ពស់នៃនគរបាលយុត្តិធម៌ ត្រូវផ្តល់ ជូនបន្ទាប់ពីឆ្លងកាត់ការប្រឡងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋាន ដូចខាងក្រោមៈ

១- វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌខ្មែរ។

២-វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌខ្មែរ។

៣- វិញ្ញាសាស្តីពីករណីយកិច្ចសាស្រ្ត ដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលតាក់តែងដោយអង្គការសហប្រជាជាតិ។

សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ និងមានបោះត្រាផង[7] ។

### ១.៣ ការទទួលបានដោយស្វ័យប្រវត្តិ

-អ្នកដែលមានឋានន្តរស័ក្ត និងមុខងារដូចខាងក្រោមទទួលដោយស្វ័យប្រវត្តិនូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ៈ

ក-អភិបាល និងអភិបាលរង ខេត្ត ក្រុង អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និង មេឃុំ ចៅសង្កាត់។

ខ-ប្រធាន និងអនុប្រធាននាយករដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាន នាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអង្គស្នងការ ដ្ឋាននគរបាលជាតិ។

គ-ប្រធាន និងនាយកដ្ឋាន ប្រធាននិងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ និងនាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

7.មាត្រា ៦០ និងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ឃ-ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកនៃ ៖

-នាយកដ្ឋាននគរបាលព្រំដែន «ចំពោះបទល្មើសឆ្លងដែន»

-មន្ទីរប្រឆាំងគ្រឿងញៀន

-នាយកដ្ឋាននគរបាលទេសចរណ៍ និងស្នងការពិសេសការពារបេតិកភ័ណ្ឌ។

ង-ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច-ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជាៈ

-ការិយាល័យនគរបាលព្រហ្មទណ្ឌកំរិតធ្ងន់ និង ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល

-ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យប្រឆាំងគ្រឿងញៀន

-ការិយាល័យប្រឆាំងភេរវកម្ម និង

-ការិយាល័យជនបរទេស។

ឆ-អធិការ និងអធិការរង ប្រធាន និងអនុផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាល ស្រុក ទណ្ឌ។

ជ- ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុផ្នែក នគរបាលចរាចរ «ចំពោះបទល្មើសចរាចរ»។ ប្រធាន និងនិងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធ ជាតិផ្ទុះ ប្រធាន និងអនុប្រធានផ្នែកការិយាល័យ គ្រប់គ្រងអាវុធជាតិផ្ទុះ «ចំពោះបទល្មើសអាវុធ ជាតិផ្ទុះ»។ ប្រធាន និងអនុប្រធានអង្គភាពប្រធាន និងអនុប្រធានការិយាល័យនគបាលទេសចរណ៍ ប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគបាលទេសចរណ៍។

ឈ-ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលឃុំសង្កាត់ «ចំពោះបទល្មើសព្រហ្មទណ្ឌ »។

ញ-មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថ ដែលដែលទទួឡបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ដ-មេបញ្ជាការ និងមេបញ្ជារងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឋ-មេបញ្ជាការ និង មេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ-ប្រធាន និងអនុប្រធានការិយាល័យ ប្រធាន និងអនុប្រធានផ្នែកកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ

ឍ- ប្រធាន និងអនុប្រធាន អង្គភាពផ្នែកផ្សេងទៀតដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

ជាចុងក្រោយ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវស្បថថាខ្លួននឹងបំពេញដោយភក្តីភាពនូវមុខងាតរបស់ខ្លួន សម្បថត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទានជាមន្ត្រី នគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានសមត្ថកិច្ចក្នុងរង្វង់ដែនដីនៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំង។ នៅទីក្រុងភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចលើវិសាលភាពទីក្រុងទាំងមូល ដោយមិនគិតពីអង្គភាពចាត់តាំងរបស់ខ្លួន។ សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌អាចពង្រីកលើវិសាលភាពនៃដែនដីប្រទេសទាំងមូល ដោយព្រះរាជអាជ្ញាក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង ឬក្នុងករណីបន្ទាន់។ ចៅក្រមស៊ើបសួរ ក៏អាចពង្រីកសមត្ថកិច្ចដែនដី របស់មន្ត្រីនគរបាលយុត្តិធម៌នៅពេលចេញដីកាចាត់អោយស៊ើបសួរសួរជំនួស ដោយមានបញ្ជាក់ពីលក្ខណៈបន្ទាន់។ អន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិធម៌នៅក្រៅដែនសមត្ថកិច្ចត្រូវធ្វើឡើងដោយមានកិច្ចសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចក្នុងតំបន់នោះ។ ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដីក៏ត្រូវទទួលដំណឹងអំពីអន្តរាគមន៍នេះផងដែរ ដោយចៅក្រមដែលបានពង្រីកសមត្ថកិច្ចរបស់ខ្លួន។ គ្រប់អន្តរាគមន៍ ក្រៅពីសមត្ថកិច្ច ដែលពុំទទួលបានការអនុញ្ញាតពីចៅក្រម ពុំមានសុពលភាពទេ ហើយការស៊ើបអង្កេតត្រូវចាត់ទុកជាមោឃៈ។

មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីទទួលពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហារ។ គ្រប់ការដាក់ពាក្យបណ្តឹងតម្រូវអោយមានការធ្វើកំណត់ហេតុ ដើម្បីអនុញ្ញាតអោយមានការស៊ើបអង្កេត ឬការបញ្ជូនទៅទៅអោយព្រះរាជអាជ្ញា។ ក្នុងករណីដែលបណ្តឹងបរិហារ មានមូលហេតុត្រឹមត្រូវ មន្ត្រីនគរបាលយុត្តិធម៌មានកាតកិច្ចជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ។ មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងស៊ើបអង្កេតបឋមព្រមទាំងអនុវត្តដីកាចាត់អោយសួរសាក្សីរបស់ចៅក្រមស៊ើបសួរ។ ហេតុដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ គឺជាអង្គនៃគំនិត នៃការដឹកនាំ នៃការបញ្ជា និងជាអង្គនៃក្រុម ខ័ណ្ឌបេសកកម្ម នៃនគរបាលយុត្តិធម៌ [៨]។

**កថាខណ្ឌទី២៖ ការកំណត់សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌**

នគរបាលយុត្តិធម៌មានសមត្ថកិច្ចសំខាន់ៗដូចខាងក្រោមៈ

**២.១-សមត្ថកិច្ចដែនដី**

៨. សៀវភៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៧ ទំព័រទី១០

មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅបម្រើការងារ[9] ។ការកំណត់ពីមណ្ឌលរដ្ឋបាលដែលជាដែនដីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌មានបញ្ជាក់នៅក្នុងសេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌នោះ។ ហេតុនេះ មន្ត្រីនគរបាលដែលបានចាត់តាំងអោយទៅបម្រើការងារនៅស្រុកណាមួយខេត្តណាមួយ មានសមត្ថកិច្ចដែនដីនៅស្រុកនោះប៉ុណ្ណោះ។

ករណីលើកលែងគឺៈ

-នៅក្នុងភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចលើវិសាលភាពនៃក្រុងទាំងមូល។

-ការអនុញ្ញាតឲ្យបំពេញប្រតិបត្តិការលើវិសាលភាពនៃដែនដីជាតិទាំងមូល ដោយព្រះរាជអាជ្ញាជាលាយលក្ខណ៍ អក្សរ ឬដោយផ្ទាល់មាត់ ក្នុងករណីបទល្មើសជាក់ស្តែង។

-ការអនុញ្ញាតឲ្យបំពេញប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូល ដោយចៅក្រមស៊ើបសួរនៅក្នុងដីការចាត់អោយស៊ើបសួរជំនួស។

ក្នុងករណីដែលមានការពន្លាតដែនដីសមត្ថកិច្ច មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាល យុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ ចៅក្រមត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី។

### ២.២ សមត្ថកិច្ចសម្ភារៈ (សមត្ថកិច្ចតាមសាច់រឿង)

តាមក្រមនីតិវិធីព្រហ្មទណ្ឌ កងរាជអាវុធហត្ថក៏ជានគរបាលយុត្តិធម៌ដែរ។ ហេតុនេះ កងរាជអាវុធហត្ថអាចបំពេញមុខងារជានគរបាលយុត្តិធម៌នៅក្នុងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ប៉ុន្តែចំពោះបទល្មើសយោធាមានតែកងរាជអាវុធហត្ថដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌ [10]។

ក្រៅពីនេះ រដ្ឋបាលព្រៃឈើ មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើមិនអាចស៊ើបអង្កេតបទល្មើសផ្សេងទៀត។

### ២.៣-អំណាចរបស់នគរបាលយុត្តិធម៌

ក្រមនីតិវិធីព្រហ្មទណ្ឌកំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅតាមក្រមខ័ណ្ឌនៃការស៊ើបអង្កេតថាការស៊ើបអង្កេតករណីជាក់ស្តែង ឬការស៊ើបអង្កេតបឋម។

9.មាត្រា ៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

10.មាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

### ២.៤-ការពន្លាតសមត្ថកិច្ចដែនដី

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងតាមអត្ថន័យនៃមាត្រា៨៦(និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា៨៧ (ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ ហើយប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ធ្វើប្រតិបត្តិការនៅលើវិសាលភាពនៃដែនដីជាតិទាំងមូលការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់ ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត។

ក្នុងក្រមខ័ណ្ឌនៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឲ្យស៊ើបសួរជំនួសក្នុងករណីបន្ទាន់ ចៅក្រមនេះ អាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីជាតិទាំងមូល។ កាលណាធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។

ចៅក្រមដែលបានអនុញ្ញាតឲ្យមានការពន្លាតសមត្ថកិច្ច ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចខាងដែនដី [11]។

### ២.៥-កម្មវិបាកនៃការមិនគោរពវិធានសមត្ថកិច្ច

វិធាននៃសមត្ថកិច្ចខាងដែនដី ដែលបានបញ្ញត្តិនៅក្នុងមាត្រាមុនៗនេះ មានលក្ខណៈដាច់ខាត។ បើមិនគោរពតាមទេនោះ កិច្ចទាំងឡាយដែលបំពេញដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាមោឃៈ [12]។

### ផ្នែកទី២៖ ភ្នាក់ងារនគរបាលយុត្តិធម៌

ភាក់ងារនគរបាលយុត្តិធម៌ គឺជានាយនគរបាល ស្នងការ និងអធិការនៃនគរបាលជាតិដែលពុំមានសញ្ញាបត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ ភ្នាក់ងារដទៃទៀតរបស់នគរបាលជាតិ នាយកងរាជអាវុធហត្ថដែលពុំមានសញ្ញាបត្រជាន់ខ្ពស់ខាងផ្នែកនគរបាលយុត្តិធម៌ និងទាហានដទៃទៀតរបស់កងរាជអាវុធហត្ថ។ ភ្នាក់ងារនីមួយៗត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងថានឹងបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។

ភ្នាក់ងារនគរបាលយុត្តិធម៌មានអំណាចពិនិត្យបទល្មើស។ អត្ថបទច្បាប់បានបញ្ជាក់យ៉ាងច្បាស់ថា ភ្នាក់ងារ នគរបាលយុត្តិធម៌មានអំណាចពិនិត្យបទលហុជាដើម។ ភ្នាក់ងារជួយមន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញតួនាទីរបស់ខ្លួន ដូច្នេះភ្នាក់ងារនគរបាលយុត្តិធម៌គឺជាអង្គនៃការគ្រប់គ្រង និងការអនុវត្ត [13]។

11.មាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

12.មាត្រា ៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

13.សៀវភៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៧ ទំព័រទី១៣

**២.១ ការទទួលគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌**

ដើម្បីទទួលបានគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌:

- នាយនគរបាល និងនាយនគរបាលរង ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។
- ភ្នាក់ងារនគរបាលជាតិផ្សេងទៀត។
- នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។
- យោធិនផ្សេងទៀតនៃកងរាជអាវុធហត្ថ។

**២.២ សម្បថរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់ ហើយសម្បថនេះត្រូវធ្វើឡើងនៅចំពោះមុខដសាលាដំបូង។ សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌ នាពេលក្រោយទៀត។ រូបមន្តសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**២.៣ បេសកកម្មរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ភ្នាក់ងារនគរបាលយុត្តិធម៌មានបេសកកម្មដូចតទៅ:

-ពិនិត្យបទល្មើស ជាអាទិ៍ បទលហុ ។

-ជួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងាររបស់គេ។

ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍ ហើយរបាយការណ៍នេះមានតម្លៃត្រឹមតែព័ត៌មានធម្មតា។

ក្នុងករណីណាក៏ដោយ ភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយ ដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវទុកជាមោឃៈ [14]។

**២.៤ សមត្ថកិច្ចរបស់ភ្នាក់ងារនគរបាលយុត្តិធម៌**

ភ្នាក់ងារនគរបាលយុត្តិធម៌មានសមត្ថកិច្ចក្នុងព្រំប្រទល់ដែនដីដែលខ្លួនបំពេញមុខងារខ្លួនតាមធម្មតា។ នៅពេលជំនួយដល់មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ ភ្នាក់ងារនគរបាលយុត្តិធម៌មានសមត្ថកិច្ចក្នុងព្រំប្រទល់ដែនដីដែលមន្ត្រីនគរបាលយុត្តិធម៌នោះបំពេញមុខការរបស់ខ្លួន។

14.មាត្រា ៧៦,មាត្រា៧៧ និងមាត្រា៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

ភ្នាក់ងារនគរបាលយុត្តិធម៌មិនអាចពន្លាតសមត្ថកិច្ចដោយខ្លួនឯងនោះទេ ប៉ុន្តែខ្លួនអាចអមដំណើរមន្ត្រីនគរបាលយុត្តិធម៌ដែលបានធ្វើដំណើរទៅក្រៅដែនសមត្ថកិច្ចរបស់ខ្លួនតាមការអនុញ្ញាតឲ្យពន្លាតសមត្ថកិច្ច។

ក្របខ័ណ្ឌស៊ើបអង្កេត (ការស៊ើបអង្កេតបទល្មើសជាក់ស្តែង ការស៊ើបអង្កេតបឋម ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស) មិនមានឥទ្ធិពលលើសមត្ថកិច្ចដែនដីដំបូងរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ឡើយ។

ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសមួយចំនួនឲ្យកាន់តែមានប្រសិទ្ធិភាព (ការជួញដូរគ្រឿងញៀន ភេរវកម្ម ចោរកម្មទ្រង់ទ្រាយធំ ការជួយដូរវត្ថុបុរាណ ការប្រយុទ្ធប្រឆាំងនឹងបទល្មើសផ្លូវភេទប្រព្រឹត្តចំពោះកុមារ។ល។) អាជ្ញាធរអាច សម្រេចបង្កើតអង្គភាពផ្សេងៗដែលមានសមត្ថកិច្ចថ្នាក់ជាតិ។ ដូចនេះមន្ត្រីនគរបាលយុត្តិធម៌ដែលតែងតាំងក្នុងអង្គភាពនេះអាចធ្វើដំណើរលើវិសាលភាពដែនដីជាតិទាំងមូលដោយមិនចាំបាច់សុំការអនុញ្ញាតពន្លាតសមត្ថកិច្ច [15]។

### ២.៥ កំហុសដែលត្រូវបានប្រព្រឹត្តនៅពេលបំពេញមុខងារ

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងពេលបំពេញមុខងាររបស់ខ្លួនត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញាត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីវិន័យ ។

## ផ្នែកទី៣៖ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតដែលមាននីតិសម្បទាពិសេស សម្រាប់ពិនិត្យបទល្មើសមួយចំនួន

នៅក្នុងផ្នែកនេះ ខ្ញុំនឹងបញ្ជាក់ជូនថាតើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះជានរណាគេ? តើមានច្បាប់ណាខ្លះដែលបានផ្តល់នីតិសម្បទាពិសេសដល់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ ?ការតាក់តែងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះត្រូវគោរពនូវបែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាអ្វីខ្លះ? បន្ទាប់ពីការតែងតាំងរួចហើយ តើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះត្រូវទៅស្បថនៅឯណា? ចុះនៅពេលដែលមន្ត្រីរាជការ និងភ្នាក់ងាសាធារណៈដទៃទៀតនោះបានប្រព្រឹត្តកំហុសក្នុងពេលបំពេញមុខងារ តើនឹងមានចំណាត់ការបែបណាខ្លះចំពោះពួកគាត់? ដើម្បីយល់កាន់ច្បាស់នូវសំណួរទាំងនេះទាមទារឲ្យយើងធ្វើ ការសិក្សានូវចំណុចលម្អិតមួយចំនួនដូចខាងក្រោម៖

### កថាខណ្ឌទី១៖ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមួយចំនួន

15.សៀវភៅនីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល ឆ្នាំ២០០៩ ទំព័រ១៥

ដោយមូលហេតុថា ការទទួលបាននូវនីតិសម្បទាតាមរយៈច្បាប់ដោយឡែកមានចំនួនច្រើន ប៉ុន្តែប្រធានបទយើងខ្ញុំពុំបានផ្តោតសំខាន់ទៅលើចំនុចនេះខ្លាំងពេកទេ។អាស្រ័យហេតុនេះដើម្បីផ្តល់ជំនួយក្នុងការសិក្សាស្រាវជ្រាវទាក់ទងទៅនឹងចំណុចនេះ ខ្ញុំសូមលើកយកមកបង្ហាញតែច្បាប់ចំនួនពីរតែប៉ុណ្ណោះ ទី១. ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងទី២. ច្បាប់ស្តីពីព្រៃឈើ។ ច្បាប់ទាំងពីប្រភេទនេះយើងខ្ញុំនឹងធ្វើការបង្ហាញជូនដូចខាងក្រោម៖

**១.១ តាមរយៈច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ**

យោងតាមមាត្រា១០ នៃច្បាប់នេះ[16] មន្ត្រីនៃក្រសួងកិច្ចការនារី បំរើការងារលើវិស័យដែលបញ្ញត្តិដោយច្បាប់ខាងលើត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងអាចធ្វើជាដើមបណ្តឹងជួសមុខឲ្យជនរងគ្រោះក្នុងគោលដៅទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

**១.២ តាមរយៈច្បាប់ស្តីពីព្រៃឈើ**

យោងតាមមាត្រា៧៦ និងមាត្រា៧៧ នៃច្បាប់នេះ[17] មន្ត្រីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺសំដៅទៅលើមន្ត្រីរដ្ឋបាលព្រៃឈើ ដែលមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ មានន័យថាត្រូវទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងកសាងសំណុំរឿងបញ្ជូលទៅតុលាការ។ មន្ត្រីរដ្ឋបាលព្រៃឈើធ្វើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទា។

## កថាខណ្ឌទី២៖ ការតែងតាំងចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

បន្ទាប់ពីមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃផ្សេងទៀតនោះ ទទួលបាននូវនីតិសម្បទាពិសេស រួចហើយពួកគេត្រូវទទួលបាននូវការតែងតាំងជាមុនសិន។ អាស្រ័យហេតុនេះទើបមានសំណួរចោទសួរថា តើបុគ្គលប្រភេទណាដែលមានសិទ្ធិអំណាចក្នុងការតែងតាំងពួកគាត់? តើមានសេចក្តីសម្រេចប្រភេទណាដែរក្នុងការតែងតាំងពួកគាត់? ដើម្បីឆ្លើយតបនឹងសំណួរទាំងនេះបានយើងត្រូវសិក្សាដូចតទៅៈ

**២.១ បុគ្គលដែលមានអំណាចក្នុងការតែងតាំង**

គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមួយរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធព្រោះបើផ្អែកលើមាត្រា៨២ នៃក្រមនេះ[18] ត្រង់វាក្យខណ្ឌ២បានចែងថា "បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទា ត្រូវកំណត់រវាងរដ្ឋមន្ត្រីក្រសួង

16.ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ តុលា ឆ្នាំ២០០៥
17.ច្បាប់ស្តីពីព្រៃឈើ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧
18.មាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ សីហា ឆ្នាំ២០០៧

យុត្តិធម៌និងក្រសួងពាក់ព័ន្ធ។ ឧទាហរណ៍ បើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្នុងក្រសួងកិច្ចការនារី ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី។ ចំណែកមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូច្នេះពួកគាត់ត្រូវមានការតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

### ២.២ សេចក្តីសម្រេចក្នុងការតែងតាំង

ដូចដែលបានដឹងស្រាប់ហើយថា រដ្ឋមន្ត្រីមានសិទ្ធិចេញ «ប្រកាស» ដើម្បីតែងតាំងមន្ត្រីមួយចំនួនដែលនៅក្រោមឱវាទរបស់ខ្លួន តែរដ្ឋមន្ត្រីនៃក្រសួងពីរផ្សេងៗគ្នាសម្រេចតែងតាំងមន្ត្រី តែមួយដូចគ្នា ដូច្នេះសេចក្តីសម្រេចរួមគ្នានោះគេហៅថាប្រកាសរួម ជាក់ស្តែងដើម្បីទទួលនីតិសម្បទា ជូនមន្ត្រីរាជាការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ ត្រូវចេញ ប្រកាសរួម ដើម្បីទុកជាសេក្តីសម្រេចក្នុងការ តែងតាំងពួកគាត់។

ឧទាឧទាហរណ៍៖ ចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកិច្ចការនារីដូច្នេះពួកបារាជការនិងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ដូច្នេះពួកគាត់ត្រូវតែង

តាំងដោយ «ប្រកាសរួម» ផងដែរ រវាងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។

## កថាខណ្ឌទី៣៖ សម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

នៅពេលដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមួយរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ បានចេញប្រកាសរួមតែងតាំងខ្លួនរួចហើយ មន្ត្រី រាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះ មិនទាន់អាចទៅបំពេញមុខងារនេះបានភ្លាមនោះទេ គឺគាត់ត្រូវឆ្លងកាត់ដំណាក់កាលមួយផ្សេងទៀត ដូចមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ ដែលដំណាក់កាលនេះគេឲ្យឈ្មោះថា ការធ្វើសម្បថ។

### ៣.១ ទីកន្លែងដែលត្រូវធ្វើសម្បថ

យោងតាមមាត្រា៨២ ត្រង់វាក្យខណ្ឌ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតអាចមកបំពេញមុខងារបានទាល់តែឆ្លងកាត់នូវសម្បថជាមុនសិន។ ប៉ុន្តែសម្បថរបស់គាត់មិនធ្វើនៅចំពោះមុខសាលាឧទ្ធរណ៍ ដូចមន្ត្រីនគរបាលយុត្តិធម៌នោះទេគឺគាត់ត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងដែលមានសមត្ថកិច្ច តាមខេត្ត រាជធានី នីមួយៗដូចគ្នា នឹងភ្នាក់ងារនគរបាលយុត្តិធម៌ដែរ។ រូបមន្តនៃសម្បថត្រូវ[19] កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

19.សម្បថនេះត្រូវស្បថថា បំពេញមុខងារដោយស្មោះត្រង់

### ៣.២ នត្ថិភាពនៃអញ្ញាត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

នត្ថិភាពនៃអញ្ញាត្រកម្មចំពោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតគឺមានភាពខុសគ្នាពីមន្ត្រីនគរបាលយុត្តិធម៌និងភ្នាក់ងារនគរបាលយុត្តិធម៌ ព្រោះសម្បថរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតគឺនត្ថិភាព[20] ចំពោះអញ្ញាត្រកម្ម មានន័យថា បើយោងតាមមាត្រាខាង គឺមិនមានកំណត់នូវករណីលើកលែងចំពោះសម្បថឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិរួចរាល់នោះ។ ចំណុចនេះហើយដែលខ្ញុំមើលឃើញថាខុសគ្នាមន្ត្រីនគរបាលយុត្តិធម៌ក៏ដូចជាភ្នាក់ងារនគរបាលយុត្តិធម៌ដែរ ព្រោះពួកគេមានករណីលើកលែងមួយចំពោះសម្បថរបស់ខ្លួនដូចបានរៀប រាប់ខាងដើមហើយថា «សម្បថនេះពុំចាំបាច់ធ្វើឡើងវិញឡើយនៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ឬ នៅពេលដែលទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌នាពេលក្រោយទៀត»។
ផ្ទុយទៅវិញចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតទាំងនេះពុំមានចែងច្បាស់លាស់អំពីចំណុចនេះឡើយ។

## កថាខណ្ឌទី៤៖ កំហុសរបស់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតក្នុងពេលបំពេញមុខងារ

ក្រោយពេលទទួលបាននូវប្រកាសរួមតែងតាំងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីនៃក្រសួងពាក់ព័ន្ធ និងក្រោយពីបានទៅធ្វើសម្បថនៅចំពោះមុខសាលាដំបូងរួចមក មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតចំពោះការពិនិត្យលើបទល្មើស មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះធ្វើរបាយការណ៍។របាយការណ៍នេះមានតំលៃត្រឹមតែព័ត៌មានធម្មតា ប៉ុណ្ណោះ។

ប្រសិនបើមន្ត្រីរាជការនិងភ្នាក់ងារសាធារណៈដទៃទៀតប្រព្រឹត្តកំហុសពេលអនុវត្តមុខងាររបស់ខ្លួន តើនិងមាន ទណ្ឌកម្មដូចម្តេចចំពោះគាត់ ? ហើយដើម្បីដាក់ទណ្ឌកម្មបាន តើគេត្រូវមាននីតិវិធីខាងវិន័យបែបណាខ្លះ ?ចម្លល់ទាំងនេះនិងត្រូវបានបង្ហាញដូចខាងក្រោម ៖

### ៤.១ នីតិវិធីខាងវិន័យ

រាល់កំហុសទាំងឡាយដែលបានប្រព្រឹត្តិដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឲ្យដមណឹងទៅដល់ព្រះរាជអាជ្ញា ឬ ចៅក្រមស៊ើបសួរជួនចំពោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រកាសប្រាប់រដ្ឋមន្ត្រីដែលមន្ត្រី ឬ ភ្នាក់ងារនោះនៅក្រោមឪវាទដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនីតិវិធីខាងវិន័យនេះ។

20.នត្ថិភាព គឺភាវគ្មាន ឬភាពនៃអ្វីៗដែលមិនមាន (យោងតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណី នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧)

## ៤.២ ទណ្ឌកម្មចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មិនខុសគ្នាទេចំពោះការដាក់ទណ្ឌកម្មខាងវិន័យសម្រាប់នាយទាហាន នៃកងរាជអាវុធហត្ថនិងនាយនគរបាលជាតិ ដូច្នេះមិនមែនជាឧបសគ្គទៅដល់មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈក្នុងការធ្វើបណ្ដឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត។ ដោយមូលហេតុ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវបានច្បាប់នេះ ផ្ដល់នូវនីតិសម្បទាឲ្យក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌ ដូច្នេះនៅពេលដែលពួកគាត់ប្រព្រឹត្តនូវកំហុសក្នុងពេលអនុវត្តមុខងាររបស់ខ្លួនពេល នោះបទបញ្ញត្តិដែលទាក់ទងនិង"កំហុសប្រព្រឹត្តក្នុងពេលអនុវត្តមុខងារ នៃក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា៤ ដល់ មាត្រា ៦៦ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

# ជំពូកទី ២

# ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

# ជំពូកទី ២
# ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ក្នុងដំណាក់កាលស៊ើបអង្កេត ត្រូវបានគេបែងចែកយ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលក្នុងនោះយើងឃើញមានបែងចែកការស៊ើបអង្កេតបទល្មើសជា ២(ពីរ)ដែលទី១គឺការស៊ើបអង្កេតបទល្មើសជាក់ស្តែង និង ទី២គឺការស៊ើបអង្កេតបឋម ឬ បទល្មើសមិនជាក់ស្តែង។ យោងតាមមាត្រា៨៤ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ បានចែងថា អំណាចទាំងឡាយដែលឲ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះ បំពេការក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខណ្ឌស៊ើបអង្កេតជាបឋម។ ស្ថិតក្នុងករណីនេះ យើងអាចសន្និដ្ឋានបានថាការស៊ើបអង្កេតទាំងពីរ ពិតជាមានភាពខុសគ្នាជាច្រើនផងដែរ។ អាស្រ័យហេតុនេះ យើងនឹងលើកយកនូវចំណុចនីមួយៗ នៃបេសកកម្មក្នុងការស៊ើបអង្កេតទាំងពី មកបកស្រាយដូចខាងក្រោម៖

## ផ្នែកទី១៖ អំណាចក្នុងការស៊ើបអង្កេតបទល្មើសជាក់ស្តែង

នៅពេលមានបទល្មើសមួយបានកើតឡើង មន្ត្រីនគរបាលយុត្តិធម៌ សំខាន់បំផុតត្រូវកំណត់ថាបទល្មើសនោះជាបទល្មើសជាក់ ឬ មិនជាក់ស្តែង។ ពីព្រោះថា បើយើងពិនិត្យមើលលើក្រមនីតិវិធីព្រហ្មទណ្ឌយើងឃើញថា នគរបាលយុត្តិធម៌ទទួលបានអំណាចធំធេងណាស់ ក្នុងការស៊ើបអង្កេតបទល្មើស បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដោយសម្អាងលើភាពបន្ទាន់នៃការធ្វើសកម្មភាព ដើម្បីបញ្ចៀកពីភាពវឹកវរដល់សណ្តាប់ធ្នាប់សាធារណៈ ប្រមូលភស្តុតាងដែលបន្សល់ទុកនៅនឹងកន្លែងប្រព្រឹត្តបទល្មើស ព្រមទាំងដើម្បីចាប់ខ្លួនចារីសន្នត។ ភាពបន្ទន់នៅតែមានកាលណាបទល្មើសមួយត្រូវបានប្រព្រឹត្តរួចហើយ តែបានបន្តស្តែងចេញតាមរយៈធាតុសំខាន់ៗ ដូចជា ការស្រែកដេញចាប់របស់សាធារណៈ ការរកឃើញវត្ថុដែលត្រូវបានលួច ស្លាកស្នាម ឬតម្រុយណាមួយដើម ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើកាលៈទេសៈមិនមែនជាបទល្មើសជាក់ស្តែងទេ ហើយគាត់ធ្វើការស៊ើបអង្កេតដោយប្រើអំណាចក្នុងករណីបទល្មើសជាក់ស្តែង នោះអ្វីដែលគាត់បានធ្វើទាំងអប្បាន្មាន ត្រូវបានទុកជាអសាបង់ ព្រោះជាកម្មវត្ថុនៃការស្នើសុំមោឃភាព ។ ស្ថិតក្នុងស្ថានភាពនេះ យើងនឹងធ្វើការសិក្សាស៊ីជម្រៅលើចំណុចនីមួយៗ ថាតើអ្វីទៅជាបទល្មើសជាក់ស្តែង? ហើយមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចអ្វីខ្លះពេលមានបទល្មើសជាក់ស្តែងកើតឡើង? យើងនឹងធ្វើការបកស្រាយយ៉ាងក្បោះក្បាយដូចខាងក្រោម៖

### កថាខណ្ឌ១៖ ការស៊ើបអង្កេតបទល្មើសជាក់ស្តែង

នីតិវិធីនៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ក្នុងករណីបទល្មើសជាក់ស្តែងមានច្រើនចំនុចសំខាន់ៗដែលយើងនឹងធ្វើការបកស្រាយប៉ុន្តែមុននឹងធ្វើការបកស្រាយឲ្យបានលម្អិតអំពីនីតិវិធីរបស់មន្ត្រីនគរបាល

យុត្តិធម៌ចំពោះការស៊ើបអង្កេតក្នុងករណីជាក់ស្តែង ទាល់តែយល់ឲ្យបានច្បាស់ជាមុនសិន ថាអ្វីទៅជាបទល្មើសជាក់ស្តែង ?

### ១.១ និយមន័យនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង[21]

មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងបញ្ជាក់ពីករណីផ្សេងៗនៃបទល្មើសជាក់ស្តែងដែលតម្រូវឲ្យមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបាន។ ដែលមាត្រា ៨៦ នេះបានចែងថាបទឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែងគឺៈ

- បទល្មើសដែលកំពុងប្រព្រឹត្ត
- បទល្មើសដែលទើបតែប្រព្រឹត្តរួចភ្លាម
- ត្រូវចាប់ទុកជា បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក
- ជនដែលគេសង្ស័យត្រូវបានសាធារណៈជនស្រែកដេញប្រដាប់ចាប់ប្រភឹង
- បុគ្គលដែលគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀតដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស។

លក្ខខណ្ឌមួយទៀតក៏បានបញ្ជាក់ ក្នុងបទល្មើសជាក់ស្តែងផងដែរ ដែលបានកំណត់ក្នុងមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលចែងបញ្ជាក់ថាត្រូវចាប់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ ទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬ បទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់ទីនោះ សុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។ ក្នុងករណីចុងក្រោយ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌។

### ១.២ កិច្ចនានានៃការស៊ើបអង្កេតនៅក្នុងបទល្មើសជាក់ស្តែង

ទោះបីជាការស៊ើបអង្កេតត្រូវបានធ្វើឡើងក្រោមរូបភាពណាក៏ដោយ ទាំងបទល្មើសជាក់ស្តែងការស៊ើបអង្កេត ឬដីកាចាត់ឲ្យស៊ើបសួរជំនួស កិច្ចស្រាវជ្រាវនានាដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ គឺមានលក្ខណៈដូចគ្នាទាំងអស់។ ក្នុងនោះ កិច្ចទាំងឡាយដែលទាក់ទងនឹងបទល្មើសជាក់ស្តែងនេះមានចែងចាប់ពីមាត្រា ៨៥ ដល់ មាត្រា១១០ ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

---

[21] . យោងតាមប្រសាសន៍ ឯកឧត្តម កើតរិទ្ធិ អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមនីតិវិធីព្រហ្មទណ្ឌ

### ១.២.១ វិធានការដំបូងក្នុងករណីបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង

វិធានការដំបូងក្នុងករណីបទល្មើសឧក្រិដ្ឋ ឬ បទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកតម្រុយនៃភស្តុតាងទាំងឡាយដែលអាចបាត់បង់។ ពួកគាត់អាចហាមឃាត់បុគ្គលគ្រប់រូបកុំឲ្យទៅឆ្ងាយពីកន្លែងកើតហេតុ រហូតទាល់តែបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។ ប្រសិនបើយល់ឃើញថា មានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់ទីកើតហេតុ និងដឹកនាំស៊ើបអង្កេត ហើយបើមានការបន្ទាន់ ព្រះរាជាអាជ្ញាអាចអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ២០០៧។ រាល់ការស្រាវជ្រាវពិនិត្យបទល្មើសទាំងឡាយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែ ធ្វើកំណត់ហេតុ ក្នុងការពិនិត្យរបស់ខ្លួន។

### ១.២.២ ការឆែកឆេរ

ការឆែកឆេរ ត្រូវតែគោរពទៅលក្ខខណ្ឌ និងនីតិវិធីដែលចែងក្នុងមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌយ៉ាងតឹងរឹងបំផុត ហើយមាត្រានេះបញ្ជាក់ជូនមន្ត្រីនគរបាលយុត្តិធម៌អាចមានសិទ្ធិក្នុងការឆែកឆេរបាន។ ក្នុងករណីនេះមន្ត្រីនគរបាលយុត្តិធម៌មិនចាំបាច់មានដីកាពីតុលាការទេ ប៉ុន្តែគាត់ត្រូវមានការអនុញ្ញាត ជាបឋមពីព្រះរាជ្ញាហើយការអនុញ្ញាត
អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់។ ដូច្នេះទើបមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ប៉ុន្តែគាត់ត្រូវគោរពនូវ លក្ខខណ្ឌមួយចំនួនដូចជា

- ការឆែកឆេរត្រូវធ្វើជាទូទៅនៅមុខអ្នកកាន់កាប់ទីកន្លែង ប៉ុន្តែប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ
- ការឆែកឆេរត្រូវធ្វើនៅចំពោះមុខសាក្សីចំនួន ០២ (ពីរ) រូប ដែលសាក្សីនោះ ត្រូវបានចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលចុះប្រតិបត្តិការ។

យោងតាមគោលការណ៍ដែលមានចែងនេះ គឺត្រូវជ្រើសរើសអ្នកដែលមិនមានជាប់ពាក់ព័ន្ធជាមួយប្រតិបត្តិការ មានន័យថាសាក្សីមិនមែនជានគរបាល ឬ កងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ដូច្នេះសាក្សីត្រូវជ្រើសរើសចេញពីអ្នកដែលមិនបានចូលរួមក្នុងប្រតិបត្តិកការនៃឆែកឆេរនោះ។ ចំពោះម៉ោងសម្រាប់ធ្វើការឆែកឆេរមន្ត្រីនគរបាលយុត្តិធម៌មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦(ប្រាំមួយ) ព្រឹក នឹងក្រោយម៉ោង ១៨(ដប់ប្រាំបី)។

ចំពោះករណីដែលអាចធ្វើការឆែកឆេរ បានលើកលែងតែមានករណីដូចជា៖

- ក្នុងករណីមានសម្រេកឲ្យគេជួយពីក្នុងកន្លែង
- ករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជនសំដៅទៅដល់ទីតាំងដែលបើកអាជីវកម្ម នៅពេលយប់ ខុសពីម៉ោងឆែកឆេរ ដូច្នេះអាចធ្វើការឆែកឆេរនៅទីកន្លែងដោយមិនគោរពតាមលក្ខខណ្ឌពេលវេលានៃការឆែកឆេរបាន។
- ការឆែកឆេរនៅទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ក្នុងករណីនេះ គឺជាវិធានពិសេសមួយដែលទាក់ទងនឹងបទល្មើសគ្រឿងញៀន។
- ការអនុញ្ញាតរបស់ព្រះរាជអាជ្ញា ដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនោះ
- អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬ របស់សាក្សីនីមួយៗ ។
- ក្នុងករណីដែលចែងដោយមាត្រា ៨៦ និង មាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

លក្ខខណ្ឌពិសេស ដោយមានវិជ្ជាជីវៈមួយចំនួនដែលត្រូវបានគាំពារជាពិសេសដោយច្បាប់។ ដូច្នេះការឆែកឆេរត្រូវគោរពនូវលក្ខខណ្ឌពិសេសនេះក្នុងនោះសំដៅដល់ជិជ្ជាជីវៈចំនួន០២ គឺ (**វិជ្ជាជីវៈមេធាវី និងវិជ្ជាជីវៈសារព័ត៌មាន**) ។ ផ្លូវច្បាប់គាំពារវិជ្ជាជីវៈ ទាំងក្នុងក្របខណ្ឌនីតិវិធីព្រហ្មទណ្ឌដោយបានហាមឃាត់មន្ត្រីនគរបាលយុទ្ធធម៌មិនអោយធ្វើការឆែកឆេរចំពោះការិយាល័យមេធាវីបានឡើយ។ ការឆែកឆេរអាចធ្វើបានដោយព្រះរាជអាជ្ញា ឬចៅក្រមស៊ើមសួរហើយការឆែកឆេរនេះត្រូវធ្វើចំពោះមុខប្រធានគណៈមេធាវីដែលមន្ត្រីនគរបាលយុទ្ធធម៌មិនអាចបំពានបានឡើយ។

ម្យ៉ាងវិញទៀត គឺដល់វិជ្ជាជីវៈសាព័ត៌មាន ព្រោះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយើងក៏បានការពារផងដែរ។ ចំពោះវិជ្ជាជីវៈសាព័ត៌មាន ទាំងសារព័ត័មានសរសេរ និងសារសោតទស្សន៍ គឺមានន័យថាមន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឆែកឆេរនៅក្នុងអាគារសារព័ត៌មាន ដោយឯកឯងបានទេត្រូវធ្វើចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់។ ហេតុអ្វីត្រូវចាំបានមានវត្តមានព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ នៅពេលធ្វើការឆែកឆេរនៅក្នុងសហគ្រាសទាំងនោះ? ព្រោះគាត់ជាអ្នកធានារ៉ាបរងកុំឱ្យមានការឆែកឆេរ ក្លាយទៅជាការរំលោភបំពានដែលនាំឱ្យដែលនាំអោយមានការយឺតយ៉ាវក្នុងការប្រកបវិជ្ជាជីវៈដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាន។

**ឧទាហរណ៍** មន្ត្រីនគរបាលយុត្តិធម៌បានចុះឆែកឆេរទៅលើការិយាល័យមេធាវី ដោយបំពានដោយ នោះនាំឲ្យការឆែកឆេរនោះចាប់ទុកជាមោឃៈ ដោយមានន័យថានីតិវិធីនេះគឺមិនអាចយកជាការបានឡើយ (៣១)។

## ១.២.៣ ការមិនស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងក្របខណ្ឌនៃការឆែកឆេរ ប្រសិនបើគាត់រកឃើញនូវវត្ថុតាងណាមួយដែលគួរឲ្យសង្ស័យ ពួកគាត់មានសិទ្ធិអំណាចអំណាចក្នុងការចាប់យកវត្ថុតាងនោះបាន ។

ក្រោយពេលដែលគាត់ចាប់យកវត្ថុតាងនោះមកហើយ គាត់ចាំបាច់ត្រូវវេចខ្ចប់ភស្តុតាងនោះទុក ។ នៅពេលចាប់យកវត្ថុតាងនោះ គាត់ត្រូវបង្ហាញវត្ថុដែលចាប់បាននោះដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច គាត់ចាប់យកទៅវេចខ្ចប់ ដោយពេលវេចខ្ចប់ត្រូវធ្វើការបិទស្លាក និងបោះត្រា ដើម្បីរក្សាធានាថាមិនឲ្យមានការលួចដូរឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យកដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យកដែលពិពណ៌នាពីវត្ថុតាង និងទីតាំងដែលរកវាឃើញ ។ កំណត់ហេតុចុះហត្ថលេខា ឬផ្តិតមេដៃដោយអ្នក កាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។ មន្ត្រីនគរយុត្តិធម៌ត្រូវភ្ជាប់ជាមួយនូវកំណតើហេតុនៃការឆែកឆេរមួយទៀតដែលបញ្ជាក់ឲ្យបានច្បាស់អំពីការអនុញ្ញាតនៅវេលាម៉ោងដែលព្រះរាជអាជ្ញាគាត់បានផ្តល់ការអនុញ្ញាតឲ្យ ដែលអាចលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

### ១.២.៤ ការត្រួតពិនិត្យផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញថ្នាក់ជាតិដូចមានចែងក្នុងមាត្រា ១៦៣ នោះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

### ១.២.៥ កំណត់ហេតុស្តាប់ចម្លើយ និងការបញ្ជាឲ្យចូលខ្លួន

ក្នុងក្របខណ្ឌនៃការស្តាប់ចម្លើយរបស់នគរបាលយុត្តិធម៌ បើសង្កេតមើលក្នុងក្រមនីតិវិធីព្រហ្មទណ្ឌយើងឃើញមានគោលការចំនួនពីរ ត្រូវបានយកមកអនុវត្តក្នុងការស្តាប់ចម្លើយ ដែមានចែងក្នុងមាត្រា ៩៣ និងមាត្រា ៩៤ ។

***ទីមួយ*** : គ្រប់ការស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធក្នុងការកោះហៅបុគ្គលគ្រប់រូបដែលសង្ស័យថាបានចូលរួមក្នុងបទល្មើសដើម្បីផ្តល់ពណ៌មាន និងដកស្រង់ចម្លើយ ។ ដែលគាត់ត្រូវតែធ្វើកំណត់ហេតុគ្រប់ការស្តាប់ចម្លើយ ដែលកំណត់ហេតុនោះត្រូវបានបញ្ជាក់ពីការពិតនៃការឆ្លើយរបស់ជនដែលពាក់ព័ន្ធនោះ ហើយដែលគ្រប់កំណត់ហេតុនីមួយៗត្រូតែមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់មន្ត្រីនគរបាលយុត្តិធម៌រួមទាំងជនដែលពាក់ព័ន្ធ ឬអ្នកដែលបានស្តាប់ចម្លើយ ។ កិច្ចមុនពេលផ្តិតម្រាមដៃបុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗនូវខ្លឹមសារនៃកំណត់ហេតុ ។ បើកាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុដោយសរសេរថា (បានអានឲ្យស្តាប់ រួចហើយបុគ្គលនេះមិនព្រមចុះហត្ថលេខា ឬមិនផ្តិតម្រាមដៃទេ) ម៉្យាងទៀតរាល់កំហុសទាំងឡាយណាដែលមានការឆូតលុបក៏ត្រូវមានការចរចានិង

ឯកភាពគ្នា ក្នុងករណីអ្នកដែលបានកោះហៅហើយមិនចេះភាសាខ្មែរ នោះ មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែដែលបានស្បថទៅតាម ប្រពៃណី សាសនា និងជំនឿរបស់ខ្លួន ប៉ុន្តែអ្នកបកប្រែមិនត្រូវបានជ្រើសរើសក្នុងចំណោមមន្ត្រីនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទងក្នុងរឿងជាមួយគ្នានោះទេ។

***ទីពីរ*** : គ្រប់ការស្តាប់ចម្លើយមន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិកោះហៅ ជនដែលមានផលប្រយោជន៍ដើម្បីមកបំភ្លឺ ឬ ផ្តល់ព័ត៌មាន ។ ករណីដែលជននេះរឹងទទឹងដោយមិនព្រមចូលខ្លួន មន្ត្រីនគរបាលយុត្តិធម៌មានស្នើរសុំទៅព្រះរាជអាជ្ញាដើម្បីសុំឲ្យចេញបញ្ជាឲ្យចូលខ្លួន ព្រោះបញ្ជាឲ្យចូលខ្លួននេះមកបំភ្លឺ ឬផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ឲ្យកេណ្ឌកម្លាំងសាធារណៈដែលចាំបាច់ចាប់ខ្លួនជននេះមកបំភ្លឺនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌។បញ្ជាឲ្យចូលខ្លួននេះត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជ្ញា និងមានបោះត្រាផង។ ដូច្នេះកិច្ចទាំងឡាយណាមិនគោរពនូវវិធានដូចដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌនេះនឹងនាំឲ្យមាន មោឃភាពនូវកំណត់ហេតុរបស់នគរបាលយុត្តិធម៌ក្នុងការស្តាប់ចម្លើយ យោងតាមមាត្រា១០៩ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៧ ។

### ១.៣ ការឃាត់ខ្លួន

យើងពិនិត្យឃើញថា ការឃាត់នៅក្នុងការស៊ើបអង្កេតក្នុងករណីជាក់ស្តែងមានចែងពីមាត្រា ៩៦ ដល់មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះធ្វើការឃាត់ខ្លួនជនណាម្នាក់ត្រូវតាមនីតិវិធីអ្វីខ្លះ ? ហើយត្រូវគោរពបទដ្ឋានកម្រិតចំពោះការឃាត់ខ្លួន ? យើងខ្ញុំនឹងលើកយកមកពិភាក្សានៅចំណុចនីមួយៗដូចតទៅះ

### ១.៣.១ លក្ខខ័ណ្ឌដែលត្រូវគោរពដើម្បីធ្វើការឃាត់ខ្លួន

យោងតាមមាត្រា៩៦ នៃក្រមនេះបានចែងថា ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួម ក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួម ក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលផ្តល់ព័ត៌មានអំពី រឿងហេតុបានដែរប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាននិងការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។ ដូច្នេះយើងអាចទាញបានថា បុគ្គលដែលអាចត្រូវបានឃាត់ខ្លួនបានមាន ពីរប្រភេទគឺ ៖

- **ទីមួយ** គឺជាជនដែលត្រូវបានសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើសពេលនេះការឃាត់ខ្លួនត្រូវបានការអនុញ្ញាតជាបឋមពីព្រះរាជអាជ្ញា។ប៉ុន្តែចំពោះបុគ្គលមួយចំនួនដែលមន្ត្រីនគរបាលយុត្តិធម៌ ចង់បានព័ត៌មានពីគាត់ដែលជួនកាលគាត់មិនបានមិនបានប្រព្រឹត្តបទល្មើសទេ តែគាត់អាចធ្វើសាក្សីដែល ប៉ុន្តែគាត់បដិសេធមិនព្រមផ្តល់ព័ត៌មានឡើយ។ ហេតុនេះបាន បានចូលនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៩៦ ។

– **ទីពីរ** គឺមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីព្រះរាជអាជ្ញាដូច្នេះទើបមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលនោះបាន។

## ១.៣.២ រយៈពេលនៃការឃាត់ខ្លួន

រយៈពេលនៃការឃាត់ខ្លួនជាធម្មតា គឺ៤៨ ម៉ោង ដែលរយៈពេលនេះត្រូវគិតចាប់ផ្ដើមពីពេលដែលបុគ្គលដែលត្រូវបានឃាត់ខ្លួននោះ ត្រូវបានយកទៅដាក់មន្ទីរឃុំឃាំង ឬមកស្នាក់ការស្នាក់ការកងរាជអាវុធហត្ថ ឬនគរបាលទោះបីជាមួយណាក៏ដោយ ។ ដែលច្បាប់អនុញ្ញាតតែចំពោះបទឧក្រិដ្ឋហើយក្នុងលក្ខណថា បុគ្គលថា បុគ្គលដែលឃាត់ខ្លួននោះ មានតម្រុយច្រើន ដែលបង្ហាញថាបង្ហាញថាបុគ្គលនោះមានការពាក់ពន្ធ័នឹងបទឧក្រិដ្ឋ។ ការឃាត់ខ្លួនអាចពន្យាពេលបាន មិនអាចលើសពី ២៤ ម៉ោងបាននោះទេដែលចាំបាច់មានការស្នើរសុំការអនុញ្ញាតពីព្រះរាជអាជ្ញា។ ជាទូទៅនៅពេលដែលមានការស្នើរសុំ ព្រះរាជអាជ្ញានឹងធ្វើការពិនិត្យផ្ទៀងផ្ទាត់ថា ការស្នើរសុំមានមូលហេតុត្រឹមត្រូវសមហេតុផលដែរឬទេ ?ភាសារច្បាប់ គឺ ពិនិត្យមើលមូលកភាព ដែលមានន័យថា មើលលើលក្ខណៈសមស្របដែរ ឬទេ ?ដែលមិនមែនជាការស្នើរសុំពន្យាក្នុងគោលដៅទុច្ចរិត ចង់បំបិទសិទ្ធសេរីភាពរបស់គេ ចង់ឲ្យគេភ័យខ្លាចដើម្បីសារភាព ពោលគឺសំខាន់មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតម្រុយច្បាស់លាស់ថាបុគ្គលនោះមានពិរុទ្ធភាពពាក់ព័ន្ធនឹងបទល្មើសដែរ ទើបអាចសុំពន្យាពេលឃាត់ខ្លួនក្នុងគោលដៅយកចម្លើយបន្ថែមទៀត ឬចង់បានការស្វែងរកភស្តុតាងផ្សេងៗបន្ថែមទៀតរបស់ខ្លួន។ដូចនេះយើងពិនិត្យឃើញថា ការពន្យាពេលនៃការឃាត់ខ្លួនគឺត្រូវគោរពលក្ខខណ្ឌមួយចំនួនដូចជា[22]

- មានតម្រុយបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលឃាត់ខ្លួនជានីតិជនក្នុងបទឧក្រិដ្ឋ
- ការពន្យាពេលជាវិធានការចាំបាច់ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ
- អនុញ្ញាតដោយព្រះរាជអាជ្ញាលាយលក្ខណ៍អក្សរ និងសំអាងហេតុ។

បន្ទាប់ពីរយៈពេលនេះកន្លងផុតទៅ មន្ត្រីនគរបាលយុត្តិធម៌ត្រូវដោះលែងបុគ្គលនោះបើសិនជាមិនមានការអនុញ្ញាតត្រឹមត្រូវណាមួយពីអាជ្ញាធរតុលាការក្នុងការឃុំខ្លួនបន្តទេនោះ។ ករណីមជ្ឈិមនៅពេលដែលភស្តុតាងបញ្ជាក់ថា ជនជាប់ឃុំឃាំងជាពិរុទ្ធនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើសំណើរសុំពន្យាពេលឃាត់ខ្លួនបើវិធាន

[22] សៀវភៅ នីតិវិធីក្រមព្រហ្មទណ្ឌ លោកសាស្ត្រចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត បោះពុម្ពឆ្នាំ ២០១៥ ត្រង់ទំព័រ ២០

ការនេះចាំបាច់ដើម្បីឲ្យធ្វើការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យាពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើល និងសំរេច ចិត្តលើការពន្យាពេលការឃាត់ខ្លួន ។ រាល់ការអនុញ្ញាតពន្យាពេលឃាត់ខ្លួននេះត្រូវតែបញ្ជាក់ជាលាយលក្ខណ៍អក្សរ និងបញ្ចូលទៅក្នុងសំណុំរឿង ។

## ១.៣.៣ ការឃាត់ខ្លួនចំពោះអនីតិជន

យើងបានសិក្សាហើយនៅក្នុងចំណុចពីមុនដែលនិយាយពីការឃាត់ខ្លួនជាលក្ខណៈទូទៅ ដែលវាសំដៅទៅលើបុគ្គលដែលត្រូវបានឃាត់ខ្លួនជា នីតិជន ។ ដោយឡែក ក្នុងចំណុចនេះ យើងនឹងសិក្សាបន្ថែមទៅលើការឃាត់ខ្លួនបុគ្គលដែលអនីតិជនវិញម្តង ។ តើអនីតិជនអាចត្រូវបានឃាត់ខ្លួនដែរឬ? តើអនីតិជនអាចត្រូវបានឃាត់ខ្លួនដែរឬទេ ? តើគេអាចឃាត់ខ្លួនអនីតិជនបានក្នុងរយៈពេលប៉ុន្មាន ? អាចពន្យាបានដែរឬទេ ? យើងនឹងបកស្រាយដូចតតទៅៈ

ក្នុងករណីជនជាប់ឃុំជាអនីតិជន អាចធ្វើបានចំពោះតែអនីតិជននោះមានអាយុចាប់ពី ១៤ ឆ្នាំឡើងតែប៉ុណ្ណោះ។ ការពន្យាពេលការឃាត់ខ្លួនមិនត្រូវបានអនុញ្ញាតទេ ។ ជាទូទៅ អនីតិជនមិនអាចត្រូវបានឃាត់ខ្លួនមានរយៈពេលយូរដូចនីតិជនទេ ។ ចំពោះរយៈពេល គឺប្រែប្រួលទៅតាមប្រភេទបទល្មើស[23] ៖

- **បទមជ្ឈិម**

-អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ គឺមិនហួសពី ២៤ ម៉ោង ។

-អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ គឺមិនហួសពី ៣៦ ម៉ោង ។

- **បទឧក្រិដ្ឋ**

-អនីតិជនដែលមានអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ គឺមិនហួសពី ៣៦ ម៉ោង ។

-អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ គឺមិនហួសពី ៤៨ ម៉ោង ។

ចំណុចមួយទៀត ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើចំពោះការឃាត់ខ្លួនអនីតិជននោះ គឺកាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជនមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្តាយ អ្នកតំណាងអាណាព្យាបាល ឬ ដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ[24] ។

[23] .សៀវភៅ នីតិវិធីក្រមព្រហ្មទណ្ឌ លោកសាស្ត្រចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត បោះពុម្ពឆ្នាំ ២០១៥ ត្រង់ទំព័រ ២០

[24] .មាត្រា ១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ១.៣.៤ សិទ្ធិទទួលបានជំនួយក្នុងពេលឃាត់ខ្លួន

នៅក្នុងចំណុចនេះយើងនឹងស្វែងថាតើបុគ្គលណាដែលត្រូវបានឃាត់ខ្លួនហើយបានទទួលសិទ្ធិ និងជំនួយអ្វីខ្លះនៅក្នុងពេល និងបន្ទាប់ពីការឃាត់ខ្លួន ? យើងឃើញថាសិទ្ធិទាំងនោះគឺបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងមាត្រា ៩៨ និងមាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

- **សិទ្ធិទទួលបានជំនួយមេធាវី**

  បន្ទាប់ពីការឃាត់ខ្លួនរយៈពេល ២៤ ម៉ោងបានកន្លងផុសទៅ បុគ្គលដែលត្រូវបានឃាត់ខ្លួនមានសិទ្ធិសុំសន្ទនាជាមួយមេធាវី ឬ ជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឲ្យតែជននោះមានការទាក់ទិនក្នុងរឿងជាមួយ ។ រយៈពេលនៃការជួបសន្ទនានេះត្រឹមតែ ៣០ (សាមសិប) នាទី ហើយការសន្ទនានេះត្រូវធានាការសម្ងាត់ ។ ក្រោយពេលការសន្ទនា ជនដែលបានមកជួបនោះ ត្រូវធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរភ្ជាប់ជាមួយសំនុំរឿង ។[25]

- **សិទ្ធិទទួលបានជំនួយរបស់គ្រូពេទ្យ**

- មន្ត្រីនគរបានយុត្តិធម៌ ឬព្រះរាជអាជ្ញាអាចសុំឲ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលត្រូវបានឃាត់ខ្លួនបានគ្រប់ពេលវេលា ដែលគ្រូពេទ្យត្រូវបានផ្ទៀងផ្ទាត់មើលថា តើស្ថានភាពនៃបុគ្គលដែលត្រូវបានឃាត់ខ្លួននោះសមស្របនឹងការឃាត់ខ្លួនដែរឬទេ ។ ប្រសិនបើគ្រូពេទ្យយល់ឃើញថាស្ថានភាពសុខភាពរបស់បុគ្គលនោះពុំសមស្របនឹងការឃាត់ខ្លួននោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនព្រះរាជអាជ្ញា ហើយគ្រូពេទ្យត្រូវចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅលើកំណត់ហេតុ អំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោង នៃការពិនិត្យសុខភាព ។ ព្រះរាជអាជ្ញាចុះទៅកន្លែងកើតហេតុដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន ។[26]

### ១.៣.៥ បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងកន្លែងនីមួយៗរបស់នគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថដែលសម្រាប់ទទួលជនដែលត្រូវទទួលជនដែលត្រូវបានឃាត់ខ្លួន ត្រូវមានបញ្ជីស្ដីពីការឃាត់ខ្លួនមួយ ។គ្រប់ការឃាត់ខ្លួនត្រូវចុះបញ្ជីដោយមានសេចក្ដីដូចតទៅ[27] ៖

- ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឲ្យឃាត់ខ្លួន

[25] មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[26] មាត្រា ៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[27] មាត្រា ១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាខត់ខ្លួន
- អត្តសញ្ញាណបុគ្គលដែលត្រូវឃាត់ខ្លួន
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឲ្យបន្តការឃាត់ ជាយថាហេតុ
- ឈ្មោះ និងឋានៈរបស់គ្រូពេទ្យដែលបានមកពិនិត្យបុគ្គលដែលត្រូវបានឃាត់ខ្លួន ជាយថាហេតុ
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន

បញ្ជីនៃការឃាត់ខ្លួននេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ ។

### ១.៣.៦ កំណត់ហេតុសរុបនៃការឃាត់ខ្លួន

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចចិត្តរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឲ្យដឹងអំពីមូលហេតុនៃសេចក្តីសម្រេចចិត្តឃាត់ខ្លួន ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ដល់សាមីជនខ្លួនឲ្យបានដឹងផងដែរអំពីសិទ្ធិជំនួយផ្នែកច្បាប់ដែលមានចែងក្នុងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ចំពោះបុគ្គលដែលត្រូវបានឃាត់ខ្លួនដែលមិនចេះភាសាខ្មែរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែឲ្យបុគ្គលនោះ ។ មន្ត្រីនគរបាលយុត្តិធម៌ មានកិច្ចការមួយចាំបាច់ត្រូវតែធ្វើនោះគឺកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ដែលមានកំណត់ហេតុនេះត្រូវមានចុះសេចក្តីដូចជា៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឲ្យឃាត់ខ្លួន
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុ នៃការឃាត់ខ្លួន
- កាលបរិច្ឆេទ និងម៉ោងដែលបុគ្គលឃាត់ខ្លួន ត្រូវបានឲ្យដំណឹងពីសិទ្ធិជំនួយផ្នែកច្បាប់ក្នុងមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)នៃក្រមនេះ
- ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន
- អត្តសញ្ញាណរបស់ជនដែលបាន សន្ទនាជាមួយបុគ្គលឃាត់ខ្លួនស្របតាមមាត្រា៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឲ្យបន្តការឃាត់ខ្លួន
- ចិរវេលានៃការស្តាប់ចម្លើយនីមួយៗ និងចិរវេលានៃការសម្រាក់ដែលចន្លោះការស្តាប់ចម្លើយនីមួយៗ
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការឃាត់ខ្លួន
- ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន
- លក្ខខណ្ឌនៃការប្រព្រឹត្តិទៅនៃការឃាត់ខ្លួនព្រមទាំង ឧប្បត្តិហេតុជាយថាហេតុ

- កំណត់ហេតុសរុបនៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង ។

កំណត់ហេតុនេះត្រូវចុះហត្ថលេខា ឬផ្ដិតស្រាមដៃរបស់ជនត្រូវបានឃាត់ខ្លួនក្រោយពីសាមីខ្លួនបានអានឬបើសាមីខ្លួនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវកំណត់ហេតុឲ្យស្ដាប់ ឬប្រើអ្នកបកប្រែបើសាមីខ្លួនមិនចេះភាសាខ្មែរ ។ បើសិនជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្ដិតមេដៃ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង។

## ១.៤. ការបញ្ជូនខ្លួន

យើងបានសិក្សាហើយថា រយៈពេលនៃការឃាត់ខ្លួនគឺអាចឈានទៅដល់ ៤៨ម៉ោង ទោះបីរយៈពេលដែលច្បាប់អនុញ្ញាតជាអតិប្បរមាគឺ ៤៨ ម៉ោង ហើយបទឧក្រិដ្ឋដែលឃើញថាមានតម្រុយអាចពន្យាពេលបាន ២៤ ម៉ោងបន្ថែមទៀតនេះគ្រាន់តែជារយៈពេលអតិប្បរមា មិនមានន័យថា ទាល់តែគ្រប់ ៤៨ម៉ោងទើបអាចបញ្ជូនខ្លួនគេទៅនោះទេ ។ ក្នុងន័យនេះ គឺមន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនជនសង្ស័យតែ ៥ម៉ោង ឬតិចជាងនេះហើយគាត់បញ្ជូនទៅព្រះរាជអាជ្ញាក៏បានដែរ ព្រោះនៅពេលផុតរយៈពេលនេះគាត់ត្រូវតែបញ្ជូនបុគ្គលដែលឃាត់ខ្លួនទៅព្រះរាជអាជ្ញាតែម្ដង ។ ដោយមូលហេតុនេះ ពាក់ព័ន្ធនឹងការបញ្ជូនខ្លួន យើងត្រូវសិក្សាទៅលើ ២ ចំណុចដូចខាងក្រោម ៖

### ក. ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន

ជាទូទៅពេលដែលផុតកំណត់រយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវបញ្ជូនទៅព្រះរាជអាជ្ញា ។ ក្នុងករណីដែលគាត់យល់ឃើញថាមិនមានអ្វីធ្ងន់ធ្ងរនោះទេ ព្រះរាជអាជ្ញាអាចមិនបញ្ជូនបុគ្គលនោះទៅចៅក្រមស៊ើបសួរនោះទេ ដោយគាត់អាចបន្តនីតិវិធីរបស់គាត់ដោយដោះលែងបុគ្គលនោះឲ្យមានសេរីភាពឡើងវិញ ។ សេចក្ដីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា ថាតើត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរ ឬដោះលែងឲ្យមានសេរីភាពវិញ[28]។

### ខ. រយៈពេលនៃការបញ្ជូនខ្លួន

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនត្រូវបានបញ្ជូនខ្លួនទៅព្រះរាជអាជ្ញានោះ បុគ្គលនោះត្រូវបានគេនាំខ្លួនភ្លាមដោយមន្ត្រីនគរបាលយុត្តិធម៌ទៅចំពោះមុខព្រះរាជអាជ្ញា ប្រសិនបើការបង្ហាញខ្លួនមិនអាចធ្វើបានក្នុងថ្ងៃតែមួយដោយមូលហេតុពិសេស ដែលបណ្ដាលមកពីការលំបាកក្នុងការដឹកជញ្ជូនឬចម្ងាយផ្លូវនៃការដឹកជញ្ជូននោះ ព្រះរាជអាជ្ញាអាចផ្ដល់រយៈពេលបន្ថែមបាន ។ តែការបង្ហាញខ្លួនគ្រប់ករណីទាំងអស់ ត្រូវធ្វើឡើងក្នុង

[28] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

រយៈពេលមួយដ៏ឆាប់បំផុតតាមដលអាចធ្វើទៅបាន ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះកំណត់ ហេតុពីមូលហេតុនៃការឃឹតយ៉ាវហើយប្រគល់ជូនទៅព្រះរាជអាជ្ញា[29] ។

## ១.៥ វិធានការទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង

នៅក្នុងចំណុចនេះ យើងនឹងបង្ហាញពីវិធានមួយចំនួយសំរាប់មន្ត្រីនគរបាលយុត្តិធម៌ដែលទាក់ទងនឹងការស៊ើបអង្កេតករណីជាក់ស្តែង ដែលមានចែងក្នុងក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ត្រង់មាត្រា ១០៥ ដែលបានហាមមិនឲ្យមន្ត្រីនគរបាលយុត្តិធម៌មានអំណាចស្តាប់ចម្លើយ និងថតសម្លេងការសន្ទនាតាមទូរស័ព្ទបានឡើយ ។

### ១.៥.១ ការហាមឃាត់មិនឲ្យស្តាប់ចម្លើយ

អលទ្ធិភាពមួយដែលមានចែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ ត្រង់មាត្រា ១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលហាមមិនឲ្យមន្ត្រីនគរបាលយុត្តិធម៌មានអំណាចស្តាប់ចម្លើយ និងថតសម្លេងការសន្ទនាតាមទូរស័ព្ទបានឡើយ ។ ហើយរឹងតែមិនអាច បង្គាប់ឲ្យចាប់ខ្លួន និងថតការឆ្លើយឆ្លងដែលចេញតាមមធ្យោយបាយទូរគមនោគន៍ ជាអាទិ៍សារតាមទូរសារ ឬតាមអ៊ិនធើណែតបាននោះទេ ។

### ១.៥.២ ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា ។ កាលណាបុគ្គលណាមួយត្រូវបានត្រូវបញ្ជូនទៅព្រះរាជអាជ្ញា នោះការបញ្ជូនកំណត់ហេតុ និងវត្ថុតាងត្រូវធ្វើជាមួយការបញ្ជូននោះផងដែរ ។ ចំពោះកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌នោះត្រូវចុះនិទ្ទេសដូចតទៅ ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌
- កាលបរិច្ឆេទ ។

ទំព័រនីមួយៗ ត្រូវចុះលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ ។ ពាក្យឆូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រមដោយចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ ។ កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការ ឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ [30]។

**ឧទាហរណ៍៖** យល់ព្រមឲ្យលុបពាក្យ **ក** ដោយកែដាក់ថា **គ** វិញនិងចុះហត្ថលេខា ។

[29] មាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

[30] មាត្រា ១០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

ដូចដែលដឹងហើយថា ជាគោលការណ៍កំណត់ហេតុមានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ប៉ុន្តែកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ **ឯកសារដើម** មានន័យថា ត្រូវទុកជាឯកសារដែលត្រូវជឿរហូតដល់មានភស្តុតាងផ្ទុយ។ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមមធ្យោបាយត្រឹមត្រូវតាមច្បាប់។ ចៅក្រមធ្វើមូលវិចារណ៍ ដោយសេរីលើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគបាយុត្តិធម៌ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង[31]។

## ១.៥.៣ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

វិធាន និងទម្រង់ការដែលបានបញ្ញត្តិនៅមាត្រា ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ )
- មាត្រា ៩១ (ការឆែកឆេរ)
- មាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង )
- មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ)
- មាត្រា ៩៤ (បទបញ្ជាឲ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)
- មាត្រា ៩៩ (ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា ១០៥ (ការហាមមិនឲ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៦ (ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែង )
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) នៃក្រមនីតិព្រហ្មទណ្ឌ ។

មានលក្ខណៈដាច់ខាតត្រូវតែគោរព បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃភាពនៃនីតិវិធី។

## កថាខណ្ឌ២៖ ការស៊ើបអង្កេតក្នុងករណីមិនជាក់ស្តែង

ក្រៅពីការស៊ើបអង្កេត របស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងបទល្មើសជាក់ស្តែងពួកគាត់ក៏អាចធ្វើការស៊ើបអង្កេតក្នុងករណីបទល្មើសមិនជាក់ស្តែងបានដែរដោយគ្រាន់តែត្រូវគោរព នូវនីតិវិធីមួយចំនួនដូចតទៅ៖

[31] មាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧

### ២.១ អត្ថន័យបទល្មើសមិនជាក់ស្តែង

បទល្មើសមិនជាក់ស្តែង គឺចង់សំដៅថា នៅក្នុងករណីនៃការស៊ើបអង្កេតបឋម ឬ ការស៊ើបអង្កេតក្នុងករណីមិនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តន៍ទៅតាមគោលការណ៍ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា ១១១ ដល់មាត្រា ១១៨ ។

***កំណត់សម្គាល់*** ៖ អំណាចក្នុងការស៊ើបអង្កេតករណីជាក់ស្តែង គឺធំជាងគេក្នុងការស៊ើបអង្កេតករណីមិនជាក់ស្តែង ។ អំណាចនៅក្នុងករណីស៊ើបអង្កេតបឋមនេះហៅថាករណីមិនជាក់ស្តែង គឺខុសពីអំណាចក្នុងការស៊ើបអង្កេតករណីជាក់ស្តែង ដែលខ្ញុំនឹងលើកយកមកបង្ហាញដូចខាងក្រោម៖

#### ២.១.១ ការបើកស៊ើបអង្កេតបឋម

ទាក់ទងនឹងការបើកការស៊ើបអង្កេតបឋមមានភាពខុសគ្នាទៅនឹងការបើកការស៊ើបអង្កេតករណីជាក់ស្តែងដូចមានចែងក្នុងមាត្រា ១១១ ថា «កាលណាបានដឹងពីអំពើដែលអាចជាបទ ឧក្រិដ្ឋ ឬ បទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬ តាមការស្នើរសុំរបស់ព្រះរាជអាជ្ញា» ។

**<u>បញ្ជាក់</u>** ៖ ក្នុងការអនុវត្តន៍ជាក់ស្តែងរបស់មន្ត្រីនគរបាលយុត្តិធម៌ ចំពោះការបើកការស៊ើបអង្កេតបឋមនេះ ត្រូវធ្វើពាក្យស្នើរសុំបើកការស៊ើបអង្កេតបឋម ពីព្រះរាជអាជ្ញាជាមុនសិន ដើម្បីបន្តអនុវត្តន៍តាមនីតិវិធី ។

ក្នុងករណីព្រះរាជអាជ្ញាមិនអនុញ្ញាត គាត់ត្រូវចុះនិទ្ទេសថា «មិនអនុញ្ញាតលើសំណើរសុំគប្បី មន្ត្រីនគរបាលយុត្តិធម៌បញ្ជូនសំណុំរឿងមកអយ្យការ ដើម្បីចាត់ការតាមនីតិវិធី ។

ករណីមួយព្រះរាជអាជ្ញាអនុញ្ញាតគាត់ត្រូវចុះនិទ្ទេសថា «អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ បើកការស៊ើបអង្កេតបឋមតាមការស្នើរសុំ (អនុវត្តតាមមាត្រា ៣៧ ៧៤ និង ១១១ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ )។ ក្រោយពីទទួលបានការអនុញ្ញាត ក្នុងការលើកបើក ស៊ើបអង្កេតបឋមតាមការស្នើរសុំហើយនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវចាត់ការបន្តនីតិវិធីភ្លាម ដោយធ្វើការកោះហៅជនសង្ស័យ ឬ បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើស ឲ្យចូលមកកាន់ការិយាល័យជំនាញរបស់មន្ត្រីនគរបាលយុត្តិធម៌ដើម្បីសាកសួរអំពីរឿងហេតុ ។ បើសិនជនសង្ស័យ ឬ បុគ្គលដែលសង្ស័យថាបានប្រព្រឹត្តបទល្មើសមិនព្រមចូលមកបំភ្លឺ អំពីរឿងហេតុនោះទេ មន្ត្រីនគរបាលយុត្តិធម៌នឹងធ្វើនីតិវិធី គឺធ្វើសំណើរសុំដីកាបញ្ជាឲ្យចូលមកបំភ្លឺ អំពីរឿងហេតុនោះទេមន្ត្រីនគរបាលយុត្តិធម៌នឹងបន្តនីតិវិធី គឺធ្វើសំណើរសុំដីកាបញ្ជាឲ្យចូលខ្លួន ។

នៅក្នុងនីតិវីធីស្នើរសុំដីកាបញ្ជាឲ្យចូលខ្លួននេះ យើងខ្ញុំសុំធ្វើការបង្ហាញជូននៅមេរៀនបន្តបន្ទាប់ទៀតដែលស្តីអំពីដីកាបញ្ជាឲ្យចូលខ្លួន ។

## ២.១.២ វិធានដែលអនុវត្តចំពោះការស៊ើបអង្កេតបឋម

បើយើងសិក្សាមើលទៅគឺថា ចំពោះវិធានដែលត្រូវអនុវត្តនៅក្នុងករណីស៊ើបអង្កេត បឋមយើងសង្កេតឃើញថា មិនសូវជាខុសគ្នាប៉ុន្មានទេ ទាក់ទងទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែងព្រោះមានមាត្រា ១១២ នៃក្រមនេះ បានបញ្ជាក់ថាបទប្បញ្ញត្តិនៃមាត្រាមួយចំនួន ដែលមាន ចែងនៅក្នុងការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែង ត្រូវយកមកអនុវត្តនៅក្នុងការស៊ើបអង្កេត បឋមដែរ។ ចំពោះមាត្រាទាំងនោះមានដូចជា ៖

- មាត្រា ៩០ (កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ)
- មាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ)
- មាត្រា ១០៥ (ការហាមឃាត់មិនឲ្យស្តាប់ដោយ ឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅកំណត់ហេតុ)

យើងបានដឹងហើយថា ដោយសារតែវិធានការទាំងនេះ យើងបានបកស្រាយយ៉ាងលំអិតរួចមកហើយ នៅក្នុងការស៊ើបអង្កេតករណីជាក់ស្តែងដូច្នេះដើម្បីមានភាពច្បាស់លាស់សូមមេត្តាអាននូវចំនុចដែលពាក់ព័ន្ធ នឹងមាត្រាទាំង ៥ នេះដូចមានក្នុងការបកស្រាយខាងលើ ។

## ២.១.៣ មោឃភាពនៃការមិនគោរពវិធានបញ្ញត្តិ

ដើម្បីកុំឲ្យមានការមោឃភាពនៃនិតិវិធីមន្ត្រីនគរបាលយុត្តិធម៌ គប្បីត្រូវតែគោរពតាមនូវក្នុងក្រមខ័ណ្ឌនៃ ការស៊ើបអង្កេតបឋម វិធាន និងទម្រង់ការដែលចែងនៅក្នុងមាត្រាដូចខាងក្រោម ៖

- មាត្រា ៩៦ (ការឃាត់ខ្លួន)
- មាត្រា ៩៧ (កំណត់ហេតុស្តីពីការឃាត់ខ្លួន)
- មាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន)
- មាត្រា១០៥ (ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯង ជាអាទិ៍)
- មាត្រា ១០៧ (ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា)
- មាត្រា១១៣ (ការឆែកឆេរ)
- មាត្រា ១១៤ (ការបញ្ជាឲ្យចូលខ្លួន ការស៊ើបអង្កេតបឋម ) នៃក្រមនេះ ដែលមានលក្ខណៈដាច់ខាត ត្រូវតែគោរពតាម បើពុំដូច្នោះទេ នឹងនាំឲ្យមានការមោឃភាពនៃនីតិវិធី ។

### ២.២ ការឆែកឆេរ

ការឆែកឆេរនៅក្នុងការស៊ើបអង្កេតបឋម(បទល្មើសមិនជាក់ស្តែង) គឺវាមិនដូចគ្នាទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែងនោះទេ តែផ្ទុយទៅវិញក៏មានចំនុចមួយចំនួនដូចគ្នាផងដែរ ដែរទាក់ទងនឹងបែបបទដែលត្រូវគោរព ដូច្នេះដើម្បីអនុវត្តឲ្យបានត្រឹមត្រូវហើយមានប្រសិទ្ធិភាព ក្នុងការឆែកឆេរមន្ត្រីនគរបាលយុត្តិធម៌ ត្រូវគោរពនៅចំនុចមួយចំនួនដូចតទៅ ៖

កាលណាការស៊ើបអង្កេតបឋមនោះបានទាក់ទងទៅនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់វត្ថុតាងបាន ។មន្ត្រីនគរបាលយុត្តិធម៌ ជាបឋមត្រូវទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែងដែលយល់ព្រមនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរសរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង ។តែប្រសិនបើអ្នកកាន់កាប់មិនចេះសរសេរអក្សហើយយល់ព្រមឲ្យឆែកឆេរ ។ក្នុងករណីដែលអ្នកកាន់កាប់ទីកន្លែងអវត្តមាន ឬ បដិសេធការឆែកឆេរ ប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីអាចចេញដីការអនុញ្ញាតឲ្យឆែកឆេរតាមការសុំរបស់ព្រះរាជអាជ្ញា ព្រោះព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវ ការឆែកឆេរនេះ ។ ការឆែកឆេរត្រូវធ្វើឡើងនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានអ្នកកាន់កាប់ទេគឺត្រូវធ្វើឡើងចំពោះមុខសាក្សី ២ (ពីរ) នាក់ ហើយសាក្សីត្រូវចាត់តាំងដោយព្រះរាជអាជ្ញា។

<u>**សម្គាល់**</u> ៖ សាក្សីមិនអាចជានគរបាល ឬ ជាកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។ការឆែកឆេរមិនអាចផ្តើមមុនម៉ោង (៦ )ប្រាំមួយ ព្រឹក នឹងក្រោយម៉ោង(១៨ )ដប់ប្រាំបី ឡើយ។ ក្នុងករណីជាយថាហេតុ ក្នុងការចាប់យកវត្ថុតាង គឺត្រូវយកបទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុលើតាង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ២.៣ ការបញ្ជាឲ្យចូលខ្លួន

ការបញ្ជាឲ្យចូលខ្លួនក្នុងករណីស៊ើបអង្កេតបឋម ត្រូវយកមកអនុវត្តន៍ដូចគ្នានឹងបញ្ជាឲ្យចូលខ្លួនក្នុងករណីនៃការស៊ើបអង្កេតករណីជាក់ស្តែងផងដែរ ។ ក្រមនីតិវិធីព្រហ្មទណ្ឌត្រង់មាត្រា ១១៤ ស្តីពីការបញ្ជាឲ្យចូលខ្លួន បានកំណត់យ៉ាងចូលខ្លួនបានកំណត់យ៉ាងច្បាស់ថា មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬ ដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ប៉ុន្តែបើសិនក្នុងករណីបុគ្គលនោះ រឹងទទឹងមិនព្រមចូលខ្លួន តាមការកោះហៅរបស់មន្ត្រីនគរបាលយុត្តិធម៌នោះទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជូនដំណឹងដល់ ព្រះរាជអាជ្ញាភ្លាមដើម្បីសុំដីកាបញ្ជាឲ្យចូលខ្លួន ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។ហើយការស្នើរសុំបញ្ជាឲ្យចូលខ្លួននេះត្រូវមានចុះអត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ កាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសឲ្យច្បាស់លាស់បន្ទាប់មកបញ្ជូនពាក្យសុំនោះទៅព្រះរាជអាជ្ញា ពិនិត្យហើយសម្រេច។ នៅពេលដែលព្រះរាជអាជ្ញាអនុញ្ញាត ពេលនោះគាត់នឹងចេញដីកាបញ្ជាឲ្យចូលខ្លួន ដោយមានចុះ ហត្ថលេខា

របស់ព្រះរាជអាជ្ញា និងចៅក្រម អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ ប្រើប្រាស់កងកម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឲ្យចូលខ្លួន ។នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ដើម្បីបន្តនីតិវិធីស្តាប់ចម្លើយ បុគ្គលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬ ដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុ ។

### ២.៤ ការឃាត់ខ្លួនជនសង្ស័យ

អត្ថន័យក្នុងការឃាត់ខ្លួនជនសង្ស័យក្នុងករណីមិនជាក់ស្តែងគឺយើងមើលឃើញថា មានលក្ខណៈដូចគ្នានឹងការឃាត់ខ្លួនករណីជាក់ស្តែងដែរ ។

### ២.៥ កំណត់ហេតុក្នុងការស្តាប់ចម្លើយ

យោងតាមមាត្រា ១១៥ នៃក្រមនេះបានបញ្ញត្តិថា ការស្តាប់ចម្លើយនីមួយៗត្រូវមានធ្វើកំណត់ហេតុ ហើយកំណត់ហេតុ ត្រូវដកស្រង់ដោយត្រឹមត្រូវតាមចម្លើយរបស់បុគ្គលពាក់ព័ន្ធ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែដែលបានស្បថស្របតាម សាសនា ឬជំនឿរបស់ខ្លួនថាខ្លួនបកប្រែឲ្យបានត្រឹមត្រូវ ។អ្នកបកប្រែមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាលកងរាជអាវុធហត្ថ ឬ បុគ្គលដែលពាក់ព័ន្ធក្នុងរឿងទេ" ហើយរាល់ការស្តាប់ចម្លើយទាំងឡាយដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ចាំបាច់ត្រូវតែគោរពតាមមាត្រា ១១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌស្តីពី (កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេត បឋម) ។

<u>**ចំណាំ**</u> ក្នុងករណីរកអ្នកបកប្រែគឺសំដៅលើបុគ្គលណាដែលគាត់ស្តាប់ការសួរចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ អំពីភាសាជាតិមិនបាន និងមិនយល់ពីគ្នា (ជនជាតិបរទេស) ។

### កថាខណ្ឌទី៣៖ ការបញ្ចប់ការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលការស៊ើបអង្កេតត្រូវបានធ្វើការសន្និដ្ឋានបញ្ចប់ហើយនោះអ្នកដែលទទួលខុសត្រូវធ្វើការសន្និដ្ឋាននូវការស៊ើបអង្កេតមាននាទី ធ្វើរបាយការណ៍បញ្ចប់ការស៊ើបអង្កេត។ ការស៊ើបអង្កេតអាចនឹងត្រូវបានបញ្ចប់ ប្រសិនបើជនល្មើសត្រូវបានចាប់ខ្លួន ហើយមានភស្តុតាងគ្រប់គ្រាន់ និងបង្ហាញថាអំពើដែលកើតឡើងនោះ ពិតជាបទល្មើសមួយពិតប្រាកដមែន ហើយពិតជាមានភស្តុតាងគ្រប់គ្រាន់កំណត់បានថា អ្នកដែលប្រព្រឹត្តអំពើនោះ គឺជាជនជាប់ចោទ ។ របាយការណ៍នេះ អាចជាការច្របាច់បញ្ចូលដោយមានការសន្និដ្ឋានសរុបនូវរបាយការណ៍ស៊ើបអង្កេតបន្ថែមផ្សេងៗទៀត។ អ្នកស៊ើបអង្កេតក៏ត្រូវចងចាំដែលថាការស៊ើបអង្កេតដែលចាត់ទុកថាចប់សព្វគ្រប់នោះ មិនចាំបាច់លុះត្រាតែធ្វើការចាប់ខ្លួន ជនល្មើសនោះទេ។ តែទោះជាយ៉ាងណាការស៊ើបអង្កេតនោះមិនទាន់ចប់សព្វគ្រប់ក៏ដោយដូចជា៖

- ក្រោយពីបានប្រមូលភស្តុតាងទៅ នគរបាលដើម្បីសន្និដ្ឋានថាអំពើនោះ មិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ
- ល្មើសជនស្លាប់

- រឿងក្តីនោះជារឿងក្តី ឃាតកម្ម និងអត្តឃាតរបស់ជនល្មើស
- ល្មើសជនសារភាពមុនពេលខ្លួនដាច់ខ្យល់ស្លាប់
- ការចាប់ខ្លួនរបស់ជនសង្ស័យ មិនត្រូវបានជនរងគ្រោះ សហការគាំទ្រជាមួយ

ជនសង្ស័យស្ថិតនៅក្នុងយុត្តាធិការផ្សេង ហើយពិបាកនឹងរកមធ្យោបាយនាំខ្លួនជននោះមកបាន ឬ ក៏អយ្យការយល់ថាការចំណាយដើម្បីនាំខ្លួនជននោះជាការចាំបាច់ជនដែលត្រូវបានចាប់ខ្លួននោះត្រូវបានអយ្យការចោទប្រកាន់លើបទល្មើសដែលនគរបាលចោទ ទាបជាងបទល្មើសមុន។

**កថាខណ្ឌទី៤៖ ការបញ្ជូនខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌**

បន្ទាប់ពីបានបញ្ចប់នៃការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវ ៖

- បញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ ដោះលែង ឲ្យមានសេរីភាពឡើងវិញ
- សេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។
- ប្រសិនបើការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានបញ្ចប់ជាស្ថាពរហើយ ព្រមទាំងតម្រុយភស្តុតាង ស៊ីសង្វាក់គ្នាទៅនឹងបទល្មើស និងជនសង្ស័យព្រមទាំងផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវឃាត់ខ្លួននោះត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬ ដោះលែង ឲ្យមានសេរីឡើងវិញ ។

ប្រសិនសិនបើការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបាលបញ្ចប់ជាស្ថាពរហើយ ព្រមទាំងតម្រុយភស្តុតាងស៊ីចង្វាក់គ្នាទៅនឹងបទល្មើស និងជនសង្ស័យព្រមទាំងផុតរយៈពេល នៃការឃាត់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូននខ្លួនទៅកាន់អយ្យការ ។ ក្នុងការបញ្ជូលខ្លួននោះត្រូវគោរពរយៈពេលនៃការបញ្ជូនខ្លួនដូចជា ៖

- បើបុគ្គលនោះត្រូវបានបញ្ជូនទៅអយ្យការ ជននោះត្រូវបញ្ជូនខ្លួនភ្លាម
- បើមិនអាចបញ្ជូនដោយមូលហេតុលំបាកក្នុងការដឹកជញ្ជូន ព្រះរាជអាជ្ញាអាចផ្តល់រយៈពេលបន្ថែម
- ការបង្ហាញខ្លួនបុគ្គលឃាត់ខ្លួន ត្រូវធ្វើឡើងក្នុងរយៈពេលដែលអាចធ្វើទៅបាន
- កំណត់ហេតុអំពីការឃើតយ៉ាវត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌។

ទៅជំនុំជម្រះផ្ទាល់ដែលគាត់ត្រូវតែគោរពបញ្ជារបស់ព្រះរាជអាជ្ញា និងត្រូវបំពេញកិច្ចនេះដូចមានចែងក្នុងមាត្រា ៤៦០ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់ជនជាប់ចោទ ) ដល់មាត្រា ៤៦២ (ការប្រគល់ចុងដីកាកោះហៅដោយអាជ្ញាសាលាដល់មេឃុំ ឬចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ១. ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម

ផ្អែកតាមមាត្រា ៣០៣ ចែងពី (ការបង្ហាញខ្លួនភ្លាមរបស់ជនជាប់ចោទដោយកម្លាំងអម) នឹងមាត្រា ៣០៤ ចែងពី (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបង្ហាញឲ្យដឹងថា ជនជាប់ចោទត្រូវឃុំខ្លួនដោយកងការពារ រហូតដល់សាមីខ្លួននៅមុខតុលាការដែលបង្ហាញខ្លួននោះត្រូវប្រព្រឹត្តទៅនៅថ្ងៃនោះតែម្តង ។ យើងពិនិត្យឃើញថា កងការពារ គឺអាចសំដៅទៅរកស្ថាប័ននគរបាលយុត្តិធម៌ ដែលមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកបំពេញបេសសកម្មនេះ នៅក្នុងការអមជនជាប់ចោទដើម្បីចូលបង្ហាញខ្លួនចំពោះមុខតុលាការ ឬចៅក្រមជំនុំជម្រះ ។

### ២. ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ

នៅក្នុងការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកានោះ បានន័យថាគាត់ជាអ្នកដឹកនាំខ្លួនជនជាប់ចោទទៅកាន់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬមណ្ឌលឃុំខ្លួន ឬពន្ធនាគារដើម្បីរក្សាទុកជាមុន រហូតដល់ពេលពេលជននោះចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

### ៣. ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនរយៈដីកាបញ្ជូន ឬសាលដីកាបញ្ជូន

មាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងបញ្ជាក់ពី ករណីដែលតុលាកាទទួលពាក្យបណ្តឹងតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរីលើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ។ ព្រះរាជអាជ្ញាចាត់វិធានការចាំបាច់ដើម្បីឲ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួនត្រូវបានដឹកនាំទៅកាន់សវនាកាដោយកម្លាំងសាធារណៈដែលមានវត្តមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ចូលរួមការនាំខ្លួននេះផងដែរ។

### ៤. ការធ្វើជាសាក្សីរបស់នគរបាលយុត្តិធម៌

យោងតាមមាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់ពីប្រធានសវនាការដែលគាត់ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ។ ប្រធានសវនាការ អាចស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី ដូច្នេះយើងឃើញថា មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគបាលយុត្តិធម៌ក៏អាចធ្វើជាសាក្សីក្នុងពេលសវនាការចំពោះមុខចៅក្រមជំនុំជម្រះដើម្បីជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ ។

### ៥. ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ

ការធ្វើពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខគឺ មិនមែនគ្រាន់តែធ្វើបាននៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានសម្រេចដីកាឬនៅចំពោះមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួនឬនៅចំពោះមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន ឬធ្វើនៅចំពោះមុខអគ្គព្រះរាជអាជ្ញានោះទេ តែក៏អាចធ្វើបានដែរនៅអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថដែលភាគច្រើនសំដៅទៅលើអង្គភាពនគរបាលយុត្តិធម៌ ។ នៅពេលដែលមានការប្តឹងបែបនេះជាលាយលក្ខណ៍អក្សរ ពេលនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែទទួលបណ្តឹងនោះទុកដើម្បីចាត់ការតាមនីតិវិធី។

### ៦. ការធានាសណ្តាប់ធ្នាប់នៃសវនាការ

នៅក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ពីការធានារ៉ាប់រងសណ្តាប់ធ្នាប់ក្នុងសវនាការដែលជាតួនាទីរបស់ ប្រធានសវនាការ ។ ប៉ុន្តែប្រធានសវនាការក៏អាចប្រើប្រាស់កម្លាំងសាធារណៈដែលអាចមាននគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងការធ្វើជំនួយឲ្យស្ថាប័នតុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌពោលគឺពួកគាត់មានតួនាទីក្នុងការការពារ ថែរក្សា សណ្តាប់ធ្នាប់ល្អនៃសវនាការ ។

### ៧. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការក៏អាចប្រគល់ឲ្យផងដែរ ដល់ក្រលាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទផ្សេងទៀត ឬតាមរយៈអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ ។ ដូច្នេះ ប្រសិនបើតុលាការសម្រេចជូនដំណឹងតាមរយៈផ្លូវរដ្ឋបាល ឬអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ នោះមានន័យថាក៏សំដៅដល់មន្ត្រីនគរបាលយុត្តិធម៌ផងដែរដែលគាត់ត្រូវតែបំពេញបេសសកម្មតាមបញ្ជារបស់ព្រះរាជអាជ្ញា ។ កិច្ចនេះត្រូវធ្វើដូចមានចែងនៅមាត្រា ៤៨៧ (ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់មេឃុំ ឬ ចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ៨. ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាល់ចំពោះសាលក្រមកំបាំងមុខ

យើងពិនិត្យឃើញថា បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលសំដៅដល់អង្គភាពនគរបាលយុត្តិធម៌ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។កាលណាបើអង្គភាពនគរបាលយុត្តិធម៌បានទទួលពាក្យបណ្តឹងទាស់នោះ គាត់ត្រូវតែបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ។

## ផ្នែកទី២៖ បេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌នៅពេលមានដីកាចាត់ឲ្យសួរជំនួស

បន្ទាប់ពីបានស្វែងយល់អំពីអំណាចក្នុងការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ទាំងពីរករណីរួចមក នៅក្នុងចំណុចនេះយើងនឹងបង្ហាញឲ្យឃើញពីអំណាចមួយទៀតព្រមទាំងកាតព្វកិច្ច ដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្តនៅពេលដែលមានដីកាចាត់ឲ្យស៊ើបសួរជំនួស ពីសំណាក់ចៅក្រមស៊ើបសួរ ។

### កថាខណ្ឌ១៖ ដីកាចាត់ឲ្យស៊ើបសួរជំនួស

ដីការចាត់ឲ្យស៊ើបសួរជំនួស ជាដីកាមួយដែលចេញក្រោមទម្រង់ ជាប្រតិភូកម្មអាជ្ញាបញ្ជានៃអំណាចដែលជាញឹកញាប់បំផុតចៅក្រមស៊ើបសួរចេញឲ្យចៅក្រមនៃតុលាការរបស់ខ្លួន ឬ តុលាការផ្សេងទៀត ឬទៅឲ្យមន្ត្រីនគរបាលយុត្តិធម៌ ឬ ដល់អង្គភាពនគរបាលយុត្តិធម៌ដែលពួកគេត្រូវតែអនុវត្តការស្នើរសុំអនុលោមតាមវិធាននានាដែលច្បាប់តម្រូវ ដើម្បីបំពេញកិច្ចស៊ើបសួរ ។ ជាទូទៅប្រតិភូ(អាណត្តិគាហក) ត្រូវបំពេញតែកិច្ចណាចុះក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួសប៉ុណ្ណោះ ។ ម៉្យាងទៀតកិច្ចមួយចំនួនមិនអាចត្រូវធ្វើប្រតិភូកម្មទៅមន្ត្រីនគរបាលយុត្តិធម៌នោះឡើយដូចជា ការចេញចម្លើយ,ការស្តាប់ចម្លើយជនត្រូវចោទ,សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ។ល។ដីការចាត់ឲ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ ដែលកិច្ចនោះត្រូវមានទំនាក់ទំនងដោយផ្ទាល់ ជាមួយបទល្មើសដែលចោទប្រកាន់ ។ ដីកាចាត់ឲ្យស៊ើបសួរជំនួស មិនអាចមានលក្ខណៈជាទូទៅទេត្រូវណែនាំឲ្យបានច្បាស់លាស់ ។ ចៅក្រមស៊ើបសួរជំនួសកំណត់ថេរវេលាដែលត្រូវអនុវត្តដីកាចាត់ឲ្យស៊ើបសួរ និងមានបោះត្រាផង ។ ដីការចាត់ឲ្យស៊ើបសួរជំនួសត្រូវមានការចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង ។ ចៅក្រមស៊ើបសួរអាចដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា ។

### កថាខណ្ឌ២៖ បេសកកម្មនៅសាលាឧទ្ធរណ៍

នៅក្នុងដំណាក់កាលសាលាឧទ្ធរណ៍នេះ យើងពិនិត្យឃើញមានបេសកកម្មរបស់នគរបាលយុត្តិធម៌មួយចំនួនដែលមានចែងក្នុងមាត្រា មួយចំនួនដូចជា មាត្រា ៣៨៨ ( ការជូនដំណឹង និងដីកោះហៅចូលសវនាការ ) ដែលបានចង្អុលបង្ហាញឲ្យយកមាត្រាទាំងឡាយដូចមានចែងក្នុងមាតិកា ទី២ ស្តីពី « ដីកាកោះហៅជនក្រៅពីជនជាប់ចោទឲ្យចូលសវនាការ » នៃគន្ថីទី ៧ ស្តីពី « ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីការកោះហៅ និងដីកាជូនដំណឹង » នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត ។ យើងនឹងធ្វើការសិក្សាទៅលើចំណុចនីមួយៗ ដែលមានវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ចូលរួមបេសកកម្មដូចខាងក្រោម ៖

តើដីការចាត់ឲ្យស៊ើបសួរជំនួសជាអ្វី ? តើមូលហេតុអ្វីបានជាចាំបាច់ធ្វើការស៊ើបសួរជំនួស ? ហើយមានអំណាចអ្វីខ្លះដែលនគរបាលយុត្តិធម៌ទទួលបាននៅពេលបាននៅពេលមានដីការចាត់ឲ្យស៊ើបសួរជំនួស ? ខាងនេះយើងធ្វើការបកស្រាយ ។

## ១. មូលហេតុនៃការស៊ើបសួរជំនួស

មន្រ្តីនគរបាលយុត្តិធម៌អាចទទួលបានសិទ្ធិអំណាចក្នុងការស៊ើបសួរជំនួសចៅក្រមស៊ើបសួរ គឺយើងពិនិត្យឃើញថា ដោយសារតែចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចការចាំបាច់តែម្នាក់ឯងរហូត ដើម្បីដឹកនាំការស៊ើបសួរឲ្យបានល្អនោះឡើយ ព្រោះជយនកាលត្រូវជួបប្រទះនូវការលំបាកផ្នែកសម្ភារៈ ត្រូវធ្វើការឆែកឆេរព្រមៗគ្នានៅកន្លែងជាច្រើន ដើម្បីឲ្យមានប្រសិទ្ធិភាពត្រូវបំពេញកិច្ចទៅតាមសមត្ថកិច្ចដែនដីឆ្ងាយៗពីគ្នា ម្យ៉ាងទៀតមានការស្រាវជ្រាវជាច្រើនដែលត្រូវបានដឹកនាំ ហើយពុំមានពេលវេលា និងមធ្យោបាយធ្វើតែម្នាក់ឯងឡើយ ។ ហេតុដូច្នេះ ដើម្បីប្រសិទ្ធភាពការងារ ចៅក្រមស៊ើបសួរអាចធ្វើប្រតិភូកម្មមួយផ្នែកនៃអំណាចរបស់ខ្លួន ។ ប្រតិភូកម្មអំណាចតាមរយៈដីការចាត់ឲ្យស៊ើបសួរនេះមានចែងក្នុងមាត្រា ១៣១ និង ១៧៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## កថាខណ្ឌទី៣៖ សិទ្ធិអំណាចមន្ត្រីនគរបាលយុត្តិធម៌ក្នុងពេលអនុវត្តដីកា ចាត់ឲ្យស៊ើបសួរជំនួស

ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៧១ នៃក្រមបានចែងថា កាលណាការស៊ើបសួរបានចាប់ផ្ដើម មន្ត្រីនគរបាលយុត្តិធម៌អនុវត្តដីការឲ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរ ។ ដូច្នេះចៅក្រមស៊ើបសួរទទួលបានអំណាចដឹកនាំការស៊ើបសួរជំនួសមន្ត្រីនគរបាលយុត្តិធម៌ ។ វាផ្ទុយទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង ឬការស៊ើបអង្កេតបឋមដែលនគរបាលយុត្តិធម៌ប្រើប្រាស់នូវអំណាចដែលប្រគល់ឲ្យខ្លួន ដោយមាត្រា៨៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឬមាត្រា ១១១ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ឬអនុវត្តតាមសេចក្តីណែនាំ ។ចំពោះដីការចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ អំណាចដែលត្រូវបានផ្ទេរឲ្យនគរបាលយុត្តិធម៌គឺមានកម្រិតដោយអនុវត្តតាមមាត្រា ១៧៣ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។របៀបស៊ើបអង្កេតនេះមានលក្ខណៈពិសេស ដោយគេមិនអាចធ្វើការស្រាវជ្រាវ ក្នុងពេលតែមួយនៅលើរឿងហេតុតែមួយតាមរបៀបស៊ើបអង្កេតផ្សេងទៀតឡើយ។

### ១. បុព្វសិទ្ធិមន្ត្រីនគរបាលយុត្តិធម៌

ដែនកំណត់នៃដីការស៊ើបសួរជំនួស មន្ត្រីនគរបាលយុតិធម៌អនុវត្តអំណាចមួយចំនួនរបស់ចៅក្រមស៊ើបសួរ យោងតាមមាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ដែលមាត្រានេះផ្តល់អំណាចនានាដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលគាត់អនុវត្តអំណាចដែលមានចែងក្នុងមាត្រា ១៧៨ (កំណត់ហេតុស្តីពីការស្រាវជ្រាវ និងពិនិត្យ) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) ។ មន្ត្រីនគរបាយុត្តិធម៌មិនអាចសួរចម្លើយតទល់នឹងជនត្រូវចោទ និងមិនស្តាប់ចម្លើយភាគីដើមបណ្តឹងរដ្ឋប្បវេណីបានដែរ ។ មន្ត្រីនគរបាលយុត្តិធម៌អាចស្តាប់តែបញ្ជាចៅក្រមអាណត្តិទាយកប៉ុណ្ណោះដែលខ្លួនត្រូវតែរាយការណ៍ជូនចៅក្រមអាណត្តិទាយកជាប់ជានិច្ច ហើយប្រាប់ដល់គាត់សូម្បីតែបញ្ហាបន្តិចបន្តួចក៏ដោយ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពរយៈពេលនៃការអនុវត្ត គាត់អាចនឹងទទួលជាយថាហេតុ នូវការពន្លាតសមត្ថកិច្ចតាមរយៈដីការចាត់ឲ្យស៊ើបសួរដែលមានចុះពីប្រភេទកិច្ចការទាំងឡាយដែលត្រូវបំពេញ ។

### ២. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការកោះហៅ និងស្តាប់ចម្លើយសាក្សី

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយសាក្សី ។ មុននឹងឆ្លើយចំពោះសំណួរសាក្សីម្នាក់ៗត្រូវស្បថតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត។ ប៉ុន្តែសាក្សីដែលមានរៀបរាប់នៅមាត្រា ១៥៦

(សាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ)[32] ត្រូវបានលើកលែងមិនចាំបាច់ស្បថ ។ ដើម្បីគោរពសិទ្ធិការពារខ្លួន មន្ត្រីនគរបាលយុត្តិធម៌មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលណាមួយដែលមានតម្រុយនៃពិរុទ្ធភាពលើបុគ្គលនោះទេ ។ កាលណាស្តាប់សាក្សីណាម្នាក់ បានធ្វើឲ្យលេចតម្រុយនៃពិរុទ្ធភាពលើសាក្សីនោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ឈប់ការស្តាប់ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរ ។

មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែដែលបានស្បថស្របតាមជំនឿ ឬ សាសនារបស់ខ្លួនថា ខ្លួននឹងបកប្រែជូនតុលាការឲ្យត្រឹមត្រូវ ។ បុគ្គលដែលត្រូវកោះហៅក្នុងឋានៈជាសាក្សី ត្រូវតែបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹងមន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជូនចៅក្រមស៊ើបសួរ ដែលអាចចេញបញ្ជាឲ្យចូលខ្លួន ដោយចុះអត្តសញ្ញាណនៃសាក្សី ( ការបញ្ជានេះត្រូវមានចុះកាលបរិច្ឆេទ បោះត្រា និងមានចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ) ហើយមន្ត្រីនគរបាលយុត្តិធម៌ ក៏អាចអនុញ្ញាតឲ្យប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនចំពោះមុខខ្លួន ។ កថាខណ្ឌទី២ ដល់ទី៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តលើកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី[33] ។

### ៣. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង

យោងតាមមាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឆែកឆេរ និងចាប់យកវត្ថុតាង ដោយយកនូវបញ្ញត្តិនៃមាត្រា ៩១ (ការឆែកឆេរ) និងមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) មកអនុវត្ត ។ ប៉ុន្តែការអនុញ្ញាតដែលចែងនៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៩១ (ឆែកឆេរ) ត្រូវតែផ្តល់ឲ្យដោយចៅក្រមស៊ើបសួរ ។

### ៤. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការឃាត់ខ្លួន

ក្នុងក្របខណ្ឌនៃការអនុវត្តដីកាចាត់ឲ្យស៊ើបជំនួស គេត្រូវយកបញ្ញត្តិនៃមាត្រា ៩៦ (ការឃាត់ខ្លួន) ដល់មាត្រា ១០២ (កំណត់ហេតុសរុបនៃការឃាត់ខ្លួន) មកអនុវត្ត ។ ប៉ុន្តែអំណាចដែលប្រគល់ឲ្យដោយមាត្រាទាំងនេះដល់ព្រះរាជអាជ្ញា ត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ ។ សម្រាប់ការអនុវត្តមាត្រា ១០៣ (ការបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួន) និងមាត្រា ១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ(រយៈពេលនៃការបញ្ជូនខ្លួន)នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅពេលផុតកំណត់នៃការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ ត្រូវនាំជនដែលត្រូវបានឃាត់ខ្លួនទៅបង្ហាញ នៅចំពោះមុខចៅក្រមស៊ើបសួរ[34] ។

---

[32] .មាត្រា ១៥៦ សាក្សីដែលអនុញ្ញាតឲ្យរួចពីសម្បថ ៖ ១. ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ ២. កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតត្រូវចោទ ៣. បង បងប្រុស ស្រី របស់ជនត្រូវចោទ ៤. បង បងប្អូនថ្លៃប្រុស ស្រី របស់ជនត្រូវចោទ ៥. ប្តី ប្រពន្ធរបស់ជនត្រូវចោទ ទោះបីលែងលះ ៦. កុមារអាយុក្រោម ១៤ឆ្នាំ ។

[33] .មាត្រា ១៧៩ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧

[34] .មាត្រា ១៨២ នៃនៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧

### ៥. សិទ្ធិអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស្តាប់ទូរសព្ទ ជាអាទិ៍

កាលណាដីការចាត់ឲ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថតការសន្ទនាតាមទូរស័ព្ទ ឬ ការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដូចជា សារតាមទូរស័ព្ទ ឬសារតាមរយៈអ៊ិនធើណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាចដែលប្រគល់ឲ្យដោយចៅក្រមស៊ើបសួរដោយវក្យខណ្ឌទី២ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃមាត្រា ១៧២ (ការស្តាប់ទូរស័ព្ទ ជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមព្រហ្មទណ្ឌ ដែលក្នុងនោះវក្យខណ្ឌទី២ កថាខណ្ឌទី ១ នោះបានចែងថា ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យចាប់ និងថតគ្រប់ការ ឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសព្ទ ឬសារតាមអ៊ិនធើណែត ។ ព្រមទាំងកថាខណ្ឌទី ២ ដែលមានអត្ថន័យថា ចៅក្រមស៊ើបសួរអាចសុំឲ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និងធ្វើការថត ។ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីការសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេលនៃបេសកម្ម ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌យកសិទ្ធិអំណាចទាំងអស់នេះ មកប្រើប្រាស់ក្នុងបេសកម្មខ្លួន។

នៅត្រង់ចំណុចនេះ យើងអាចសន្និដ្ឋានឃើញច្បាស់ថា អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលមាននៅក្នុងការស្តាប់ចម្លើយក្នុងក្រមខណ្ឌនៃការស៊ើបអង្កេតករណីបទល្មើសជាក់ស្តែង ត្រង់មាត្រា ១០៥ និងក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម ត្រង់មាត្រា ១១២ ( ការហាមឃាត់មិនឲ្យស្តាប់ដោយឯកឯងជាអាទិ៍) ដែលមាត្រានោះបានចែងបញ្ជាក់ពី មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឲ្យស្តាប់ និងថតសំឡេងការសន្ទនាតាមទូរស័ព្ទឡើយ ។ មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឲ្យចាប់ និងថតការឆ្លើយឆ្លងចេញតាមមធ្យោបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូសារ ឬ សារតាមអ៊ិនធើណែត ។ ដូច្នេះយើងឃើញថា អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌មានភាពខុសគ្នា ហើយមានភាពប្រែប្រួលទៅតាមដំណាក់កាលនីមួយៗ នៃកិច្ចនីតិវិធីព្រហ្មទណ្ឌ ។

## កថាខណ្ឌ៤៖ ភាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីការរបស់តុលាការ

ឆ្លងកាត់ការសិក្សានូវអំណាចជាច្រើនរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេត និងស៊ើបសួររួចមកក្នុងចំណុចនេះយើងនឹងធ្វើការរៀបរាប់អំពីបេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីការបស់តុលាការ។ តើមន្ត្រី នគរបាលយុត្តិធម៌ត្រូវមានភារៈកិច្ចអ្វីខ្លះក្នុងការរក្សាការសម្ងាត់នៃការស៊ើបសួររបស់គាត់ដែរឬទេ ? តើដីការបស់តុលាការអ្វីខ្លះដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្ត ? នឹងត្រូវបានបកស្រាយដូចខាងក្រោមនេះ៖

### ១. ការរក្សាការសម្ងាត់នៃការស៊ើបសួរ

យើងឃើញថា បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ មានច្រើនដូចជា ចៅក្រម មេធាវី នគរបាលកងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងការពិនិត្យខាងផ្នែក

បច្ចេកទេស ឬវិទ្យាសាស្ត្រដែលអ្នកទាំងនោះដាច់ខាតត្រូវតែថែរក្សាការសម្ងាត់វិជ្ជាជីវៈ។ ប៉ុន្តែការគោរពនូវសម្ងាត់វិជ្ជាជីវៈមិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនបានឡើយ។
បំពាននៅលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន[35]ដូច្នេះការស៊ើបសួរត្រូវតែរក្សាការសម្ងាត់។

### ២. ការចាប់បង្ខំសាក្សីឲ្យចូលបង្ហាញខ្លួន

បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សីត្រូវតែចូលមកបង្ហាញខ្លួន បើសិនជាបុគ្គលនោះមិនចូលមកទេ នោះមានន័យថា គាត់រឹងទទឹង ដូច្នេះចៅក្រមស៊ើបសួរអាចសុំឲ្យកងកម្លាំងសាធារណៈ ដែលអាចមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ផងដែរដើម្បីបង្ខំសាក្សីនេះមកបង្ហាញខ្លួននៅមុខតុលាការ [36]។តើមន្ត្រី នគរបាលយុត្តិធម៌ត្រូវមានភារៈកិច្ចអ្វីខ្លះក្នុងការរក្សាការសម្ងាត់នៃការស៊ើបសួររបស់គាត់ដែរឬទេ ?
តើដីការបស់តុលាការអ្វីខ្លះដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវអនុវត្ត ? នឹងត្រូវបានបកស្រាយដូចខាងក្រោមនេះ៖

### ៣. ការរក្សាការសម្ងាត់នៃការស៊ើបសួរ

យើងឃើញថា បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ មានច្រើនដូចជា ចៅក្រម មេធាវី នគរបាលកងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងការពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រដែលអ្នកទាំងនោះដាច់ខាតត្រូវតែថែរក្សាការសម្ងាត់វិជ្ជាជីវៈ ។ ប៉ុន្តែការគោរពនូវសម្ងាត់វិជ្ជាជីវៈមិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនបានឡើយ ។ការបំពាននៅលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន[37]ដូច្នេះការស៊ើបសួរត្រូវតែរក្សាការសម្ងាត់។

### ៤. ការជូនដំណឹងអំពីដីកាបង្គាប់ឲ្យចូលខ្លួន

យោងតាមមាត្រា ១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់យ៉ាងច្បាស់ពីកាតព្វកិច្ចមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារយុត្តិធម៌ ឬអាជ្ញាសាលាក្នុងការជូនដំណឹងដល់បុគ្គលដែលពាក់ព័ន្ធ អំពីដីកាបង្គាប់ឲ្យចូលខ្លួន ។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ហើយត្រូវចុះហត្ថលេខានៅដើមដីកាដែលត្រូវបង្វិលជូនចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកម្មរបស់ខ្លួន ។

[35] .មាត្រា ១២១ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧
[36] .មាត្រា ១៥៣ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧
[37] .មាត្រា ១២១ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧

ដូច្នេះគោលដៅនៃដីកាបង្គាប់ឲ្យចូលខ្លួននេះ គឺដើម្បីបញ្ជាដល់បុគ្គលណាម្នាក់ឲ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ[38]។

**ឧទាហរណ៍** ៖ នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ យកដីការបង្គាប់ឲ្យចូលខ្លួនទៅកាន់លំនៅដ្ឋានរបស់ជនត្រូវចោទ តែលំនៅដ្ឋាននៃជននោះគ្មាននរណាម្នាក់ស្នាក់នៅឡើយ ។ ដូច្នេះ វាគឺជាការលំបាកក្នុងការអនុវត្តបេសកកម្មដែលមន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរពីបញ្ហានេះ ។

### ៥. ការអនុវត្តដីការបង្គាប់ឲ្យនាំខ្លួន

នៅក្នុងមាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា ការអនុវត្តដីការបង្គាប់ឲ្យនាំខ្លួន ត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ ។ ក្នុងករណីបន្ទាន់ដីការបង្គាប់ឲ្យនាំខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីការ ត្រូវប្រគល់ក្នុងរយៈពេលដែលយ៉ាងខ្លីបំផុតឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីការនោះ ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកម្មរបស់ខ្លួន ។ ដីការបង្គាប់ឲ្យនាំខ្លួននេះ គឺមានគោលដៅបង្គាប់ឲ្យកងកម្លាំងសាធារណៈចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះចៅក្រមស៊ើបសួរ ។

### ៦. ការអនុវត្តដីការបង្គាប់ឲ្យចាប់ខ្លួន

នៅក្នុងមាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថា ការអនុវត្តដីការបង្គាប់ឲ្យចាប់ខ្លួន ដែលត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ ។ ក្នុងករណីបន្ទាន់ដីការបង្គាប់ឲ្យនាំខ្លួនត្រូវផ្សព្វផ្សាយទៅតាមអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ។ ដើមដីការ ត្រូវប្រគល់ក្នុងរយៈពេលដែលយ៉ាងខ្លីបំផុតឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីការនោះ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឲ្យដំណឹងដល់ចៅក្រមស៊ើបសួរអំពីការលំបាកទាំងអស់ក្នុងពេលអនុវត្តបេសកម្មរបស់ខ្លួន ។ គោលដៅនៃដីកាបង្គាប់ឲ្យចាប់ខ្លួន គឺចេញក្នុងន័យបញ្ជាដល់ ៖

- កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវរកចាប់ និងឲ្យនាំខ្លួនបុគ្គលនោះទៅក្នុងពន្ធនាគា ឬមណ្ឌលឃុំខ្លួន
- ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល និងឃុំខ្លួនបុគ្គលនោះ ។ រាល់ការអនុវត្តដីការទាំងពីរ ទាំងដីកាបង្គាប់ឲ្យចាប់ខ្លួន និងឲ្យនាំខ្លួន ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវ

[38] .មាត្រា ១៨៦ នៃក្រមនីតិវិធីក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧

គោរពវិធាននៃពេលវេលា ពោលគឺគាត់មិនអាចចូលទៅលំនៅឋានរបស់បុគ្គលដែលនៅមុនម៉ោង ៦(ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយ ។

គ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬកងរាជអាវុធហត្ថ ដែលចៅក្រមស៊ើបសួរសុំឲ្យប្រគល់ដីកាកោះហៅ ឬដីកាផ្សេងៗទៀតត្រូវតែអនុវត្តតាមបញ្ជារបស់ចៅក្រមនេះ ។ បុគ្គលអង្គភាព ឬអាជ្ញាធរដែលចៅក្រមស៊ើបសួរចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬដីកាដល់សាមីខ្លួនដោយមានចំណាររបស់អ្នកបញ្ជាក់ថា បានទទួលទុកជាសម្គាល់ ។ ដីកាដែលមានចំណារទទួលនេះត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ យើងដឹងហើយថា មិនមែនគ្រប់មន្ត្រីរាជការ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬកងរាជអាវុធហត្ថ ទាំងអស់សុទ្ធតែជានគរបាលយុត្តិធម៌នោះទេ តែដោយសារក្នុងបរិបទនេះយើងកំពុងសិក្សាពាក់ព័ន្ធនឹងបេសកកម្មរបស់នគរបាលយុត្តិធម៌នោះទេ តែដោយសារក្នុងបរិបទនេះយើងកំពុងសិក្សាពាក់ព័ន្ធនឹងបេសកម្មរបស់នគរបាលយុត្តិធម៌ ដូច្នេះទើបយើងលើកយកពួកគាត់មកពិភាក្សា ។

ដែលយើងឃើញថា ចៅក្រមស៊ើបសួរ គាត់ក៏អាចបញ្ជាអ្នកមិនមែនជាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឲ្យអនុវត្តនូវការប្រគល់ដីការនេះបានដែរ ។

### ៧. ការអនុវត្តដីការកោះហៅ ឬដីការផ្សេងៗ ទៀត

គ្រប់មន្ត្រីជ្រាជការ គ្រប់អាជ្ញាធររដ្ឋបាល គ្រប់នគរបាល ឬកងរាជអាវុធហត្ថ ដែលចៅក្រមស៊ើបសួរសុំឲ្យប្រគល់ដីកោះហៅ ឬ ដីការផ្សេងៗ ទៀត ត្រូវដែអនុវត្តាមបញ្ជារបស់ចៅក្រមនេះ ។ បុគ្គលអង្គភាព ឬអាជ្ញាធរដែលមានចៅក្រមស៊ើបសួរ ចាត់តាំងនោះ ត្រូវតែប្រគល់ដីកាកោះ ឬដីកាដល់សាមីខ្លួនដោយមានចំណាររបស់អ្នកបញ្ជាក់ថា បានទទួលទុកជាសំគាល់ ។ ដីកាដែលមានចំណារទទួលនេះ ត្រូវបង្វិលជូនទៅចៅក្រមស៊ើបសួរក្នុងរយៈពេលយ៉ាងខ្លីបំផុត [39]។

## ផ្នែកទី៣៖ បេសកកម្មរបស់នគរបាលយុត្តិធម៌នៅដំណាក់កាលជំនុំជម្រះ

នៅក្នុងចំណុចនេះយើងនឹងធ្វើការសិក្សាទៅលើបេសកកម្មរបស់នគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលជំនុំជម្រះ ដែលយើងបែងចែកជា ៣ ចំណុចតូចៗ ហើយតើមន្ត្រីនគរបាលយុត្តិធម៌មានបេសកកម្មនៅសាលាជំនុំជម្រះក្តីណាខ្លះ ?ហើយមានការប្រព្រឹត្តទៅយ៉ាងដូចម្តេចក្នុងដំណាក់កាលសាលាជំនុំជម្រះក្តីនីមួយៗ យើងនឹងធ្វើការបកស្រាយដូចខាងក្រោម៖

[39] .មាត្រា ២៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ សីហា ឆ្នាំ ២០០៧

**កថាខណ្ឌ១៖ បេសកកម្មនៅសាលាដំបូងរាជធានី - ខេត្ត**

បើយើងពិនិត្យឲ្យច្បាស់ទៅបេសកកម្មរបស់នគរបាលយុត្តិធម៌ នៅដំណាក់កាលសាលាដំបូងរាជធានីខេត្ត យើងឃើញថា មានចែងចាប់ពីមាត្រា ២៨៧ ដល់មាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបេសកកម្មទាំងអស់នោះមានអត្ថន័យដូចតទៅ

**១. ការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

យោងតាមមាត្រា ៤៦៣ ដែលបានចែងពីការបញ្ជូនទៅជំនុំជម្រះផ្ទាល់គឺអាចត្រូវបានជូនតាមរយៈបុគ្គលច្រើនប្រភេទ ដែលក្នុងនោះយើងមានអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬអាជ្ញាធររដ្ឋបាល នោះមានន័យថា បើសិនជាគេបញ្ជូនតាមរយៈបុគ្គលណាមួយក្នុងចំណោមបុគ្គលទាំងនេះ មានន័យថាក៏មានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ចូលរួមក្នុងបេសកកម្មនេះផងដែរ បន្ទាប់ពីព្រះរាជអាជ្ញា សុំឲ្យប្រគល់ដីការកោះហៅបញ្ជូនបន្តទៀតពោលគឺគាត់ត្រូវបញ្ជូនបណ្តឹងនោះភ្លាមទៅក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានប្រកាសចេញសាលដីកាតាមមាត្រា ៤១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**២. ការអមជនជាប់ចោទនៅក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម**

ផ្អែកតាមមាត្រា ៣០៣ ចែងពី (ការបង្ហាញខ្លួនភ្លាមរបស់ជនជាប់ចោទដោយកម្លាំងអម) នឹងមាត្រា ៣០៤ ចែងពី (នីតិវិធីនៃការបង្ហាញខ្លួនភ្លាម) នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបង្ហាញឲ្យដឹងថា ជនជាប់ចោទត្រូវឃុំខ្លួនដោយកងការពារ រហូតដល់សាមីខ្លួននៅមុខតុលាការដែលបង្ហាញខ្លួននោះត្រូវប្រព្រឹត្តទៅនៅថ្ងៃនោះតែម្តង ។ យើងពិនិត្យឃើញថា កងការពារ គឺអាចសំដៅទៅកស្ថាប័ននគរបាលយុត្តិធម៌ ដែលមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ជាអ្នកបំពេញបេសសកម្មនេះ នៅក្នុងការអមជនជាប់ចោទដើម្បីចូលបង្ហាញខ្លួនចំពោះមុខតុលាការ ឬចៅក្រមជំនុំជម្រះ ។

**៣. ការរក្សាទុកជនជាប់ចោទមុនចូលបង្ហាញខ្លួននៅមុខតុលាការ**

នៅក្នុងការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្តដីកាកោះ បានន័យថាគាត់ជាអ្នកដឹកនាំខ្លួនជនជាប់ចោទទៅកាន់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬមណ្ឌលឃុំខ្លួន ឬពន្ធនាគារដើម្បីរក្សាទុកជាមុន រហូតដល់ពេលពេលជននោះចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

**៤. ការនាំខ្លួនជនជាប់ចោទទៅបង្ហាញខ្លួនរយៈដីកាបញ្ជូន ឬសាលដីកាបញ្ជូន**

មាត្រា ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងបញ្ជាក់ពី ករណីដែលតុលាកាទទួលពាក្យបណ្តឹងតាមដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរីលើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ។ព្រះរាជអាជ្ញាចាត់

វិធានការចាំបាច់ដើម្បីឲ្យជនជាប់ចោទដែលត្រូវបានឃុំខ្លួនត្រូវបានដឹកនាំទៅកាន់សវនាកាដោយកម្លាំងសាធារណៈ ដែលអាចមានវត្តមានមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ចូលរួមការនាំខ្លួននេះផងដែរ ។

### ៥. ការធ្វើជាសាក្សីរបស់នគរបាលយុត្តិធម៌

យោងតាមមាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ជាក់ពីប្រធានសវនាការដែលគាត់ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ តាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍ ។ ប្រធានសវនាការ អាចស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានចូលរួមក្នុងការស៊ើបអង្កេតក្នុងឋានៈជាសាក្សី ដូច្នេះយើងឃើញថា មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក៏អាចធ្វើជាសាក្សីក្នុងពេលសវនាការចំពោះមុខចៅក្រមជំនុំជម្រះ ដើម្បីជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ ។

### ៦. ការធានាសណ្តាប់ធ្នាប់នៃសវនាការ

នៅក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់ពីការធានារ៉ាប់រងសណ្តាប់ធ្នាប់ក្នុងសវនាការដែលជាតួនាទីរបស់ ប្រធានសវនាការ ។ ប៉ុន្តែប្រធានសវនាការក៏អាចប្រើប្រាស់កម្លាំងសាធារណៈដែលអាចមាននគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងការធ្វើជំនួយឲ្យស្ថាប័នតុលាការនៅក្នុងរឿងក្តីព្រហ្មទណ្ឌពោលគឺពួកគាត់មានតួនាទីក្នុងការការពារ ថែរក្សា សណ្តាប់ធ្នាប់ល្អនៃសវនាការ ។

### ៧. ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ

ការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការក៏អាចប្រគល់ឲ្យផងដែរ ដល់ក្រលាបញ្ជី តាមផ្លូវរដ្ឋបាល ដោយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទផ្សេងទៀត ឬតាមរយៈអង្គភាពនយោបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ ។ ដូច្នេះ ប្រសិនបើតុលាការសម្រេចជូនដំណឹងតាមរយៈផ្លូវរដ្ឋបាល ឬអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថ នោះមានន័យថាក៏សំដៅដល់មន្ត្រីនគរបាលយុត្តិធម៌ផងដែរ ដែលគាត់ត្រូវតែបំពេញបេសសកម្មតាមបញ្ជារបស់ព្រះរាជអាជ្ញា ។ កិច្ចនេះត្រូវធ្វើដូចមានចែងនៅមាត្រា ៤៨៧ (ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់មេឃុំ ឬ ចៅសង្កាត់) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ៨. ការទទួល និងការបញ្ជូនពាក្យបណ្តឹងទាល់ចំពោះសាលក្រមកំបាំងមុខ

យើងពិនិត្យឃើញថា បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលសំដៅដល់អង្គភាពនគរបាលយុត្តិធម៌ ឬនៅចំពោះមុខប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ។

កាលណាបើអង្គភាពនគរបាលយុត្តិធម៌បានទទួលពាក្យបណ្តឹងទាស់នោះ គាត់ត្រូវតែបញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម[40] ។

### កថាខណ្ឌ២៖ បេសកកម្មនៅសាលាឧទ្ធរណ៍

នៅក្នុងដំណាក់កាលសាលាឧទ្ធរណ៍នេះ យើងពិនិត្យឃើញមានបេសកកម្មរបស់នគរបាលយុត្តិធម៌មួយចំនួនដែលមានចែងក្នុងមាត្រា មួយចំនួនដូចជា មាត្រា ៣៨៨ ( ការជូនដំណឹង និងដីកោះហៅចូលសវនាការ ) ដែលបានចង្អុលបង្ហាញឲ្យយកមាត្រាទាំងឡាយដូចមានចែងក្នុងមាតិកា ទី២ ស្តីពី « ដីកាកោះហៅជនក្រៅពីជនជាប់ចោទឲ្យចូលសវនាការ » នៃគន្ថីទី ៧ ស្តីពី « ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹង » នៃក្រមនីតិវិធីព្រហ្មទណ្ឌមកអនុវត្ត ។ យើងនឹងធ្វើការសិក្សាទៅលើចំណុចនីមួយៗ ដែលមានវត្តមានរបស់មន្ត្រីនគរបាលយុត្តិធម៌ចូលរួមបេសកកម្មដូចខាងក្រោម ៖

#### ១. ការទទួល និងបញ្ជូនពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខ

ការធ្វើពាក្យបណ្តឹងទាស់ចំពោះសាលដីកាកំបាំងមុខគឺ មិនមែនគ្រាន់តែធ្វើបាននៅការិយាល័យក្រឡាបញ្ជីនៃសាសាឧទ្ធរណ៍ ដែលបានសម្រេចដីកាឬនៅចំពោះមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួនឬនៅចំពោះមុខប្រធានពន្ធនាគារឬមណ្ឌលឃុំខ្លួន ឬធ្វើនៅចំពោះមុខអគ្គព្រះរាជអាជ្ញានោះទេ តែក៏អាចធ្វើបានដែរនៅអង្គភាពនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថដែលភាគច្រើនសំដៅទៅលើអង្គភាពនគរបាលយុត្តិធម៌ ។ នៅពេលដែលមានការប្តឹងបែបនេះជាលាយលក្ខណ៍អក្សរ ពេលនោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែទទួលបណ្តឹងនោះទុកដើម្បីចាត់ការតាមនីតិវិធីបន្តទៀតពោលគឺគាត់ត្រូវបញ្ជូនបណ្តឹងនោះភ្លាមទៅក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានប្រកាសចេញសាលដីកាតាមមាត្រា ៤១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

#### ២. ការប្រគល់ដីកាកោះហៅ

ឆ្លងតាមមាត្រា ៤៧២ (របៀបផ្សេងៗនៃការប្រគល់ដីកាកោះ) យើងពិនិត្យឃើញថា នគរបាយុត្តិធម៌ ក៏មានបេសកកម្មផងដែរ ប្រសិនបើតុលាការ ប្រើនីតិវិធីប្រគល់តាមអង្គភាពនគរបាលយុត្តិធម៌ កងរាជអាវុធហត្ថ ឬតាមផ្លូវរដ្ឋបាល ។ អ្នកទាំងអស់នេះ ត្រូវតែគោរពបញ្ជារបស់ព្រះរាជអាជ្ញាតាមការសុំឲ្យប្រគល់ដីកាកោះហៅនោះ ហើយត្រូវបំពេញកិច្ចនោះ ដូចមានចែងក្នុងមាត្រា ៥៦៩ (ការប្រគល់ដីកាដោយអាជ្ញាសាលាដល់ជនជាប់ចោទ) ដល់មាត្រា ៤៧១ (ការប្រគល់ចុងដីកាកោះហៅដែលអាជ្ញាសាលា)។

### កថាខណ្ឌ៣៖ បេសកកម្មនៅតុលាការកំពូល

បេសកកម្មរបស់នគរបាលយុត្តិធម៌ នៅដំណាក់កាលតុលាការកំពូលនេះយើងឃើញថា បានចែងតែមួយមាត្រាប៉ុណ្ណោះក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នោះគឺមាត្រា ៤៣៣ ( ការជូនដំណឹងអំពីកាលបរិច្ឆេទសវនា

[40] .មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ សីហា ឆ្នាំ ២០០៧

កាចំពោះគូភាគី) ។ នៅពេលដែលប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនាការ និងជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនាការ អគ្គព្រះរាជអាជ្ញាត្រូវឲ្យដំណឹងអំពីកាលបរិច្ឆេទនេះដល់ភាគីនិងមេធាវី ។រីឯការឲ្យដំណឹងដល់ពិរុទ្ធជន ឬជនជាប់ចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និងដល់មេធាវី ត្រូវធ្វើដូចតទៅ ៖ ដោយផ្ទាល់មាត់ ឬតាមផ្លូវរដ្ឋបាល ឬតាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។ កាលណាការឲ្យដំណឹងត្រូវធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការឲ្យដំណឹងទៅលើសំណុំរឿង ។ ពិរុទ្ធជនជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសរដ្ឋប្បវេណី ឬមេធាវី ចុះហត្ថលេខារបស់ខ្លួន។នៅក្នុងករណីដទៃទៀត ការឲ្យដំណឹងត្រូវធ្វើដោយមានបង្កាន់ដៃបញ្ជាក់ថាបានទទួលសម្រាប់ទុកជាសម្គាល់ ។តាមរយៈអត្ថន័យខាងលើ យើងឃើញថាមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ក៏មានបេសកកម្មក្នុងការទាក់ទងនឹងការជូនដំណឹងអំពីការបរិច្ឆេទនៃសវនាការទៅដល់ភាគីផងដែរ ។

## ផ្នែកទី៤៖ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ និងនីតិវិធីដោយឡែក

បន្ទាប់ពីបានសិក្សានូវបេសសកម្មរបស់នគរបាលយុត្តិធម៌នៅក្នុងដំណាក់កាលនីតិវិធីទាំងឡាយដែលយើងបានរៀបរាប់ជូនខាងលើ នគរបាលយុត្តិធម៌នៅមានបេសកកម្មដទៃទៀតក៏មានផងដែរ ។ យើងនិងសិក្សាទៅលើបេសកកម្មរបស់នគរបាលយុត្តិធម៌ នៅក្នុងដំណាក់កាលនីតិវិធីប្រត្តិបត្តិ និងនីតិវិធីដោយឡែក ។ តើនគរបាលយុត្តិធម៌មានបេសកកម្មអ្វីខ្លះក្នុងនីតិវិធីដោយឡែក និងនីតិវិធីប្រត្តិបត្តិ ? យើងនឹងធ្វើការបកស្រាយដូចខាងក្រោម ៖

### កថាខណ្ឌ១៖ បេសកកម្មនៅដំណាក់កាលនីតិវិធីប្រតិបត្តិ

យើងឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌចាប់មាត្រា ៤៩៦ ដល់មាត្រា ៦៦៤ បានចែងពីបេសកកម្មរបស់នគរបាលយុត្តិធម៌ដូចជា:

#### ១. ការធានារ៉ាប់រងការអនុវត្តទោស

មាត្រា ៤៩៩ នៃក្រមព្រហ្មទណ្ឌ បានបញ្ជាក់ពីសិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាក្នុងការសុំកម្លាំងសាធារណៈ ដែលមានចែងដូចជា មន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ជាដើម ដើម្បីទៅបំពេញបេសកកម្មក្នុងការធានានូវការអនុវត្តទោស នៅពេលដែលមានសាលក្រម ឬសាលដីការបស់តុលាការឲ្យផ្តន្ទាទោសជនណាមួយ ។

### ២. ការស្នើសុំពិនិត្យបញ្ជី និងបង្ហាញជនជាប់ឃុំ

មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចក្នុងការពិនិត្យបញ្ជីជនជាប់ឃុំ ដែលអំណាចនេះត្រូវបានប្រគល់ដោយអាជ្ញាធរតុលាការ ដែលមានន័យថាគ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ និងមណ្ឌលឃុំខ្លួន ត្រូវតែជូនបញ្ជីទៅបង្ហាញដល់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញបេសកកម្មនោះ ដែលបញ្ជីនោះត្រូវបានចុះនិទ្ទេសអំពីអត្តសញ្ញាណជនដែលត្រូវបានឃុំខ្លួន កាលបរិច្ឆេទឃុំខ្លួន កាលបរិច្ឆេទដោះលែង [41]។ ចំពោះមាត្រា ៥០៨ បានបញ្ជាក់ឲ្យដឹងពីការដែលគ្រប់ភ្នាក់ងាររដ្ឋបាលពន្ធនាគារ ត្រូវតែបង្ហាញខ្លួនជនជាប់ឃុំរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបំពេញបេសកកម្ម តាមការប្រគល់អំណាចពីអាជ្ញាធរតុលាការ ។

### ៣. ការជូនដំណឹង ការចាប់ខ្លួន និងការឃុំខ្លួនទណ្ឌិតក្នុងករណីបង្ខំដល់រូបរាងកាយ

ចំពោះករណីដែលទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីទេ អង្គភាពរតនាគារជូនដំណឹងដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង ។ ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយទណ្ឌិតដើម្បីបង់ប្រាក់នោះ បើមិនព្រមបង់នោះទេ សាមីខ្លួនអាចត្រូវបង្ខំដល់រូបរាងកាយ ហើយរយៈពេលនេះមិនអាចតិចជាង១០ (ដប់) ថ្ងៃទេ ។ ការឲ្យដំណឹងត្រូវធ្វើឡើងដោយផ្ទាល់មាត់ តាមផ្លូវតុលាការ តាមអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចំណុចនេះច្រើនតែសំដៅលើនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាយុត្តិធម៌ ។ដូច្នេះពួកគាត់ត្រូវមានបេសកកម្មក្នុងការជូនដំណឹងនេះ ។ ប្រសិនបើផុតរយៈពេលកំណត់ ហើយទណ្ឌិតនៅតែមិនទាន់បង់ប្រាក់ពិន័យ ឬប្រាក់ពន្ធនៃនីតិវិធីប្រាក់សំណងរដ្ឋប្បវេណីនោះទេ ព្រះរាជអាជ្ញានឹងចេញបញ្ជាឲ្យបង្ខំ និងឃុំខ្លួនបាន ដោយយោងតាមមាត្រា ៥២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។តែដើម្បីសម្រេចកិច្ចការនេះ ព្រះរាជអាជ្ញាត្រូវសុំកងកម្លាំងសាធារណៈ ពោលគឺនគរបាលយុត្តិធម៌នេះឯងដែលទទួលបេសកកម្មក្នុងការចាប់ និងឃុំខ្លួនទណ្ឌិតតាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ ប៉ុន្តែព្រះរាជអាជ្ញា ក៏អាចបង្អង់សេចក្តីសម្រេចនេះបានដែរ ដោយសារ មូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាបញ្ហាស្ថានភាពនៃសុខភាពរបស់ទណ្ឌិត[42] ។

### កថាខណ្ឌ២៖ បេសកកម្មនៅដំណាក់កាលនីតិវិធីដោយឡែក

នៅក្នុងនីតិវិធីដោយឡែក យើងឃើញថាមានចែងចាប់ពីមាត្រា ៥៥៥ ដល់មាត្រា ៦០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តែមានចំណុចមួយដែលទាក់ទងទៅនឹងបេសកកម្មរបស់នគរបាលយុត្តិធម៌ផងដែរ គឺការរក្សាទុកនូវលិខិតនៃនីតិវិធី ពោលគឺ លិខិតនៃនីតិវិធីត្រូវបង្កឡើងវិញតាមលិខិតចម្លងដែលរក្សាទុកដោយអង្គភាពនគរបាល

[41] .មាត្រា ៥០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ សីហា ឆ្នាំ ២០០៧

[42] .មាត្រា ៥២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ សីហា ឆ្នាំ ២០០៧

ឬកងរាជអាវុធហត្ថ ភាគី អ្នកជំនាញ ក្រឡាបញ្ជី ឬបុគ្គលផ្សេងទៀត ។ការរក្សាទុកនៅកន្លែងផ្សេងៗបែបនេះ គឺដើម្បីមានភាពងាយស្រួលក្នុងពេលបាត់បង់លិខិតចម្លង ដោយថាហេតុណាមួយ របស់បុគ្គលដែលទទួលបន្ទុករក្សាលិខិតនោះ (ចុងសន្លឹក) ទើបខ្លួនអាចបង្កើតឡើងវិញលិខិតចម្លងថ្មីទៅតាមលិខិតដែលរក្សាទុកនៅឯអង្គភាពរបស់ខ្លួន ។

# ជំពូកទី ៣

## បេសកកម្មរបស់នគរបាលយុត្តិធម៌នៅកន្លែងកើតហេតុ

# ជំពូកទី ៣

## បេសកកម្មរបស់នគរបាលយុត្តិធម៌នៅកន្លែងកើតហេតុ

នគរបាលយុត្តិធម៌ នៅក្នុងការប្រត្តិបត្តិការរបស់ខ្លួនត្រូវការប្រើប្រាស់នូវបច្ចេកទេស និងយុត្តិសាស្ត្រជាច្រើន ព្រមទាំងមានលក្ខណៈម៉ត់ចត់ ដើម្បីឲ្យបេសកកម្មរបស់ខ្លួនទទួលបានលទ្ធផលល្អ និងសុក្រឹតភាព ។ នៅជំពូកទី ២ គឺបានបកស្រាយនូវចំណុចជាច្រើនទាក់ទងនឹងការដែនសមត្ថកិច្ច និងការអនុវត្តរបស់នគរបចាលយុត្តិធម៌ ដែលបានផ្តល់នូវចំណេះវិជ្ជាយ៉ាងច្រើនដែលរំលេចចេញពីអត្ថន័យនៃមាត្រាជាច្រើនក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មានលក្ខណៈទ្រឹស្តីរបស់ច្បាប់។ ក្នុងជំពូកទី ៣ នេះយើងនឹងធ្វើការសិក្សាស៊ីជម្រៅទៅលើបេសកកម្មរបស់នគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសនៅកន្លែងកើតហេតុ ។ ដើម្បីងាយស្រាយក្នុងការបកស្រាយក្នុងជំពូកទី ៣ នេះយើងធ្វើការបែកចែកជា ៣ ផ្នែកធំៗ ដូចតទៅ ៖

### ផ្នែកទី១៖ បេសកកម្មទៅកាន់កន្លែងកើតហេតុ

យើងនឹងសិក្សាទៅបេសកកម្ម របស់មន្ត្រីនគរបាលយុត្តិធម៌ទៅកាន់កន្លែងកើតហេតុ ថាតើហេតុអ្វីបានជាគាត់ស៊ើបអង្កេតនៅកន្លែងកើតហេតុ ។ តើនគរបាលយុត្តិធម៌ស៊ើបអង្កេតដើម្បីអ្វី ? ត្រូវធ្វើអ្វីខ្លះនៅកន្លែងកើតហេតុ? យើងនឹងធ្វើការបកស្រាយដូចខាងក្រោម ៖

#### កថាខណ្ឌទី១៖ គោលបំណងនៃការស៊ើបអង្កេតកន្លែងកើតហេតុ

គោលបំណងនៃការស៊ើបអង្កេតកន្លែងកើតហេតុ គឺដើម្បីជួយឲ្យដឹងនូវបទល្មើសដែលបានកើតឡើង ប្រមូលភស្តុតាងសំខាន់ៗ និងកំណត់អត្តសញ្ញាណជនល្មើស ។ វាត្រូវបានធ្វើឡើងដោយប្រុងប្រយ័ត្នក្នុងការពិនិត្យស្ថានភាពនៅកន្លែងកើតហេតុ និងទទួលស្គាល់គ្រប់ភស្តុតាងរូបវន្តទាំងអស់ ដែលតម្រូវឲ្យអ្នកស៊ើបអង្កេតប្រើប្រាជ្ញារបស់គាត់និងលទ្ធភាពរកហេតុផល និងពិសោធន៍របស់គាត់ទៅលើគោលការណ៍នោះ ។ លទ្ធភាពក្នុងការទទួលស្គាល់ និងប្រមូលភស្តុតាងរូបវ័ន្តដោយសុក្រឹតភាព គឺដើម្បីដោះស្រាយ និងចោទប្រកាន់លើបទល្មើសទាំងឡាយ ។ ក្នុងករណីជាច្រើនមន្ត្រីនគរបាលយុត្តិធម៌ ដែលការពារនិងឆែកឆេរកន្លែងកើតហេតុ ដើរតួនាទីយ៉ាងសំខាន់ក្នុងការវិភាគទៅលើកភស្តុតាងរូបវ័ន្ត អាចត្រូវបានប្រើប្រាស់ក្នុងការដោះស្រាយ ឬចោទប្រកាន់នូវបទល្មើស ពិតមែនដែរឬទេ ។

#### កថាខណ្ឌទី២៖ ដំណើរទៅកាន់កន្លែងកើតហេតុ

ដំណើរទៅកាន់កន្លែងកើតហេតុ របស់មន្ត្រីនគរបាលយុត្តិធម៌ធ្វើដំណើរទៅកាន់កន្លែងកើតហេតុ មិនមែនធ្វើដោយមិនធ្វើឡើងដោយគ្មានមានការគ្រោងទុកនោះទេ គឺត្រូវរៀបចំផែនការយ៉ាងម៉ត់ចត់ និងអនុវត្តតាមគោលការណ៍មួយចំនួនដូចជា៖

កាលណាមន្ត្រីនគរបាលយុត្តិធម៌បានដឹងពីបទល្មើស ជាបឋមខ្លួនត្រូវតែពិនិត្យនូវភាពគួរឲ្យជឿជាក់នៃដំណឹងដែលទទួលបានថាតើពិតដែ ឬទេ? ហើយធ្វើការចាត់វិធានការ ថែរក្សាស្លាកស្នាមនឹងតម្រុយ វិធានការសង្គ្រោះបុគ្គល នឹងវិធានការសន្តិសុខចាំបាច់នានា ជាមុន ។ នៅក្នុងលក្ខខណ្ឌនៃចំណុចបានបង្ហាញថា ដើម្បីបំពេញប្រត្តិបត្តិការនេះ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចធ្វើដំណើរទៅកាន់កន្លែងកើតហេតុ( យោងតាមមាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបានចែងអំពី បទឧក្រិដ្ឋ និងបទល្មើសជាក់ស្តែង ) ក្នុងលក្ខខណ្ឌដែលបទល្មើសនោះជាក់ស្តែង ។

ភាពចាំបាច់នេះកើតឡើងស្ទើរតែគ្រប់ករណីនៃបទឧក្រិដ្ឋ ។ ការត្រួតពិនិត្យកក់ត្រាត្រូវតែធ្វើបើសិនជាការណ៍នេះអាច ជំរុញឲ្យឃើញជាក់ស្តែងនូវរឿងហេតុ តម្រុយ ឬស្លាកស្នាមដែលបន្សល់ទុកដោយចារី ។ នៅពេលមានដីការស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ មានកាតព្វកិច្ចធ្វើដំណើរទៅកាន់ទីកន្លែង ដើម្បីពិនិត្យកក់ត្រា បើសិនបេសកកម្មនេះមានចុះដីការ ។ ចំពោះការស៊ើបអង្កេតបឋមវិញ ការធ្វើដំណើរទៅកាន់ទីកន្លែងមិនមានចែងក្នុងអត្ថបទជាក់លាក់មួយនោះទេ ប៉ុន្តែជាការសមហេតុផលដែលចាំបាច់ត្រូវធ្វើដំណើរទៅកាន់ទីកន្លែង គ្រប់ករណីដែលបទល្មើសត្រូវស៊ើបអង្កេត នោះគេអាចឲ្យកក់ត្រាជាក់ស្តែងបាន ។ មុនពេលធ្វើដំណើរទៅកាន់ទីកន្លែង ឬក្នុងពេលជាមួយគ្នា មន្ត្រីនគរបាលយុត្តិធម៌ត្រូវ ៖

➢ រាយការណ៍ជូន
- នាយកអង្គភាព
- ព្រះរាជអាជ្ញា (ជាយថាហេតុក្រោយការធ្វើដំណើរ)
- អាជ្ញាធររដ្ឋបាលមួយចំនួន (អភិបាល...) ចំពោះសំនុំរឿងដែលមានផលវិបាកលើជីវិតជីវភាពសាធារណៈ គឺជាការទទួលខុសត្រូវរបស់នាយកអង្គភាព ។

➢ សុំ ឬបញ្ជាឲ្យសុំជំនួយទៅតាមប្រភេទនៃសំនុំរឿង
- ពីអ្នកបច្ចេកទេសអត្តសញ្ញាណតុលាការ
- អង្គភាពសង្គ្រោះ (គ្រូពេទ្យ អ្នកពន្លត់អគ្គីភ័យ...)
- អង្គភាពសន្តិសុខ (សារព័ន្ធផ្លូវ អគ្គីសនី យោធិននៃកងវិស្វកម្ម... )

➢ បង្កើតក្រុមការងារអន្តរាគមន៍

មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងមុនគេ ឬត្រូវចាត់តាំងបង្កើតក្រុមការងារអន្តរាគមន៍មួយដែលមានសមាសភាពជាមន្ត្រីរាជការម្នាក់ ឬច្រើននាក់ដើម្បីជាជំនួយក្នុងការស្នើសុំរបស់ខ្លួន (បរិវេនសុវត្ថិភាព...) ។

**កថាខណ្ឌទី៣៖ ដំណើរទៅកាន់កន្លែងកើតហេតុ**

ការស៊ើបអង្កេតទាំងអស់មិនមែនសុទ្ធិតែអាចសន្និដ្ឋានបានមុនពីអ្វីដែលអាចកើតឡើងនោះទេ ដែល

ញឹកញាប់អ្នកស៊ើបអង្កេតត្រូវតែទៅកន្លែងកើតហេតុភ្លាមៗ ដោយពុំបានធ្វើផែនការអនុវត្តមុននោះទេ ។

### ក. ការចាត់ចែងបឋមនៅកន្លែងកើតហេតុ

គោលបំណងនៃការចាត់ចែងបឋម គឺដើម្បីស្វែងរក នូវតាងភស្តុតាងដែលអាចរកបានដែលទាក់ទងនឹងប្រតិបត្តិការនៅកន្លែងកើតហេតុ ហើយធ្វើការកំណត់អត្តសញ្ញាណជនល្មើស ។ នៅក្នុងការចាត់ចែងបឋមនេះ មន្ត្រីនគរបាលនៅមូលដ្ឋានដែលមានវត្តមាននៅកន្លែងកើតហេតុមុនគេបង្អស់ត្រូវ[43] ៖

- ធ្វើការសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះ
- ពិនិត្យថាតើមានបទល្មើស ឬអត់?
- ផ្តល់ព័ត៌មានដល់អង្គភាពស្ថាប័នពាក់ព័ន្ធដូចជា នគរបាល (រាជធានី ខេត្ត ខណ្ឌ) នាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួង (យោងតាមប្រភេទរឿងហេតុ) ការជូនដំណឹងទៅព្រះរាជអាជ្ញា ។
- ចាប់វិធានការការពារភស្តុតាង ពិសេសភស្តុតាងដែលងាយនឹងខូចខាត ឬបាត់បង់មុនមន្ត្រីនគរបាលបច្ចេកទេសវិទ្យាសាស្ត្រមកដល់ដៅព្រំដែន និងហ៊ុំព័ទ្ធកន្លែងកើតហេតុ កំណត់ច្រកចេញចូលកន្លែងកើតហេតុ
- បង្កើតគណៈកម្មការ ដើម្បីត្រួតពិនិត្យទីកន្លែងកើតហេតុ
- គណៈកម្មាការនេះត្រូវពិភាក្សាដើម្បីបើកយុទ្ធនាការចូលកន្លែងកើតហេតុ
- បែងចែកឲ្យអ្នកជំនាញណាចូលមុន និងចូលបន្ទាប់ ដើម្បីជៀសវាងកុំឲ្យកិច្ចប្រតិបត្តិការត្រួតពិនិត្យទីកន្លែងកើតហេតុ ក្លាយជាការបំផ្លាញភស្តុតាង ។

### ខ. វិធានការសណ្តាប់ធ្នាប់សាធារណៈ

ក្នុងប្រតិបត្តិការបំពេញបេសកកម្មរបស់ខ្លួននៅកន្លែងកើតហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែអនុវត្តនូវវិធានការមួយចំនួននៅកន្លែងកើតហេតុក្នុងគោលដៅ ធ្វើឲ្យបេសកកម្មរបស់ខ្លួន ទទួលបាននូវផលវិជ្ជមាន។ ដែលវិធានការទាំងនោះមានដូចជា ៖

- **វិធានការបង្ការការពារ**

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវផ្តល់អទិភាពដល់វិធានការ ការពារ ដូចជា ផ្តល់ការសង្គ្រោះដល់ជនរងគ្រោះមុនគេ

- បង្អស់ ។ បើសិនជនរងគ្រោះនៅមានជីវិត ករណីសំខាន់ត្រូវជួយមនុស្សមានសារៈសំខាន់ជាងការស៊ើបអង្កេត ។ បើសិនការស៊ើបអង្កេតមិនរារាំងដល់ការព្យាបាលជនរងគ្រោះទេ គឺគាត់ត្រូវកក់ត្រានូវទីតាំង និងជនរងគ្រោះ ព្រមទាំង អត្តសញ្ញាណ ត្រូវឲ្យមន្ត្រីរាជការម្នាក់ ឬពីនាក់ ដើម្បីធ្វើជាជំនួយការដែលត្រូវ

[43] .សៀវភៅ **អត្ថាធិប្បាយច្បាប់ ភស្តុតាង ក្នុងរឿងក្តីព្រហ្មទណ្ឌ** លោកចៅក្រម ហ៊ីង ធីឫទ្ធិ (ភាគ ២) ទំព័រ ៨៣ ដល់ ទំព័រ ៨៤

➢ កក់ត្រាហេតុដែលមានប្រយោជន៍ ចម្លើយជនរងគ្រោះ និងជាយថាហេតុរឹបអូសសំលៀកបំពាក់ ដែលផ្តល់អត្ថប្រយោជន៍ដល់ការស៊ើបអង្កេត ។**ការឡោមព័ទ្ធកន្លែងកើតហេតុ**

មន្ត្រីនគរបាលយុត្តិធម៌ត្រូវ តែឡោមព័ទ្ធទីកន្លែង និងបិទច្រកចេញដើម្បីការពារ និងថែរក្សាស្លាកស្នាម និងតម្រុយបន្សល់ទុក ព្រមទាំងរារាំងបុគ្គលគ្រប់រូបមិនឲ្យគេចខ្លួនដូចជាជនសង្ស័យ ឬសាក្សីដែលមានប្រយោជន៍ ។ មន្ត្រីនគរបាលរាំងបុគ្គលគ្រប់រូបមិនឲ្យទៅឆ្ងាយពីទីកន្លែងកើតហេតុរហូតដល់ប្រតិបត្តិការរបស់ខ្លួន បានបញ្ចប់ ។ ក្នុងពេលឡោមព័ទ្ធទីកន្លែងកើតហេតុមន្ត្រីនគរបាលយុត្តិធម៌ចាំបាច់ត្រូវ ៖

- រាប់ចំនួនអ្នកមានវត្តមាន
- ធ្វើអត្តសញ្ញាណកម្មអ្នកទាំងនោះ
- កក់ត្រាមូលហេតុ ឬអង្គភាពនៃវត្តមានអ្នកទាំងនោះ
- ប្រមូលពួកគេដាក់ក្នុងកន្លែងមួយ ដូចជា ទីធ្លា ជណ្តើរ បន្ទប់ជាដើម ដែលទាក់ទងនឹងទីកន្លែងដែលត្រួតពិនិត្យ ។

បុគ្គលសង្ស័យគ្រប់រូបនឹងត្រូវបានធ្វើអចលនកម្ម និងឆែកឆេរ រាងកាយយ៉ាងម៉ត់ចត់ ។ ត្រូវចាំថានៅពេលដែលមកដល់ទីកន្លែងកើតហេតុ អ្នកស៊ើបអង្កេតត្រូវស្វែងរកជនល្មើស និងសាក្សីឲ្យបានកាន់តែលឿនតាមដែលអាចធ្វើបាន ។យើងចាត់វិធានការលើពួកគេដោយមានដូចជា ៖ ចំពោះជនល្មើស ឬជនសង្ស័យ និងចំពោះសាក្សី [44]។

## គ. ការពិនិត្យកន្លែងកើតហេតុ និងទីកន្លែងជុំវិញ

តាមលក្ខណៈទូទៅអ្នកបច្ចេកទេសអត្តសញ្ញាណតុលាការ ជាអ្នកអន្តរាគមន៍ដំបូងបង្អស់ក្នុងគ្រប់សំណុំរឿងសំខាន់ៗ ពីព្រោះមុននឹងបង្ហាញភស្តុតាងផ្សេងៗ ចាំបាច់ត្រូវរក្សាសភាពដើមទីកន្លែងដោយការថតរូប ។ ត្រូវការពារវាកុំឲ្យមានការបំផ្លាញណាមួយពីសំណាក់មនុស្ស និងករណីធម្មជាតិជាដើម ។

មន្ត្រីនគរបាលយុត្តិធម៌ គឺត្រូវតែគោរពឲ្យបានយ៉ាងខ្ជាប់ខ្ជួននូវ គោលការណ៍នៃការស្រាវជ្រាវទាំង ៨ (ប្រាំបី)ចំណុចនៅកន្លែងកើតហេតុមានដូចជា[45] ៖

- ពិចារណា គូសបន្ទាត់កន្លែងកើតហេតុដោយពុំធ្វើអោយប៉ះពាល់ដលកន្លែងកើតហេតុ(ហ៊ុំព័ទ្ធកន្លែងកើតហេតុ)
- ថតកន្លែងកើតហេតុដោយពុំមានប៉ះពាល់អ្វីទាំងអស់
- ឆែកឆេកន្លែងកើតហេតុ

---

[44] .សៀវភៅ **មគ្គុទេសសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៧៨

[45] .សៀវភៅ **មគ្គុទេសសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៨១

- ថតរូបវត្ថុតាងនីមួយៗនៅពេលរកឃើញ
- ពិនិត្យស្នាមម្រាមដៃវត្ថុតាងនីមួយៗនៅពេលរកឃើញ
- ពិនិត្យ ADN វត្ថុតាងនីមួយៗនៅពេលរកឃើញ
- ប្រមូល និងដាក់វត្ថុតាងនៅពេលដែលរកឃើញ
- អនុវត្តកន្លែងកើតហេតុដទៃ ដូចគ្នាទៅនឹងកន្លែងកើតហេតុទីមួយដែរ។

**កថាខណ្ឌទី៤៖ តួនាទី និងការទទួលខុសត្រូវនៅកន្លែងកើតហេតុ**

ដូចដែកបានរៀបរាបជូនខាងលើ មន្ត្រីនគរបាលត្រូវបែងចែកគណៈកម្មការនីមួយៗ ដែលទទួលតួនាទី ភារកិច្ច និងការទទួលខុសត្រូវខុសៗគ្នា ហើយក្នុងនោះមានដូចជាៈ

**១.មន្ត្រីកាន់កាប់បញ្ជីកត់ត្រាកន្លែងកើតហេតុ**

ជាទូទៅប្រសិនបើមានវត្ថុមានមនុស្សកាន់តែតិចនៅកន្លែងកើតហេតុ នោះគ្រោះថ្នាក់ទំនងកាន់តែ តិចដែរ មានន័យថាកន្លែងកើតហេតុនិងមិនមានហានិភ័យខ្ពស់ក្នុងការបំផ្លាញតម្រុយ។ ជាការចាំបាច់ត្រូវ ធ្វើការហ៊ុំព័ទ្ធកន្លែងកើតហេតុ ចាក់សោទ្វារ រ៉ូតវាំងនន ឬ ប៉ារ៉ាស។ល។ ដើម្បីសម្រួលដល់បេសកម្មការងារ របស់ខ្លួន និងការពារកន្លែងកើតហេតុជាសវាងបាត់បង់តម្រុយ ឬភស្តុតាងណាមួយដាំយថាហេតុ។

ជាចាំបាច់ត្រូវតែមានអ្នកកាន់កាប់សៀវភៅបញ្ជីកំណត់ត្រាកន្លែងកើតហេតុ ក្នុងការកត់ត្រាពេវលា និងសេចក្តីលម្អិត រាល់ព្រឹត្តិការណ៍ទាំងឡាយដែលទាក់ទិននិងកន្លែងកើតហេតុ។ អ្នកកាន់កាប់បញ្ជីនេះត្រូវគេណែនាំអោយទៅយាមកន្លែងកើតហេតុ ហើយកត់ត្រាលម្អិតអំពីនមុស្សទាំងឡាយដែលចេញចូលកន្លែងកើតហេតុ។ សៀវភៅបញ្ជីនេះតរូវធ្វើយ៉ាងត្រឹមត្រូវ ព្រោះវាអាចត្រូវបានតុលាការពិនិត្យ ពច្ច័យនៅពេលក្រោយ។ គេត្រូវកត់ត្រាព៌ត៌មាន មួយចំនួនដូចជាៈ

- ឈ្មោះមន្ត្រីនគរបាល
- ម៉ោងចេញចូលកន្លែងកើតហេតុ
- មូលហេតុដែលពួកគេចូលទៅទីនោះ

អ្នកស៊ើបអង្កេតដទៃទៀត និងមន្ត្រីនគរបាល រួមមានមន្ត្រីនគរបាលជាន់ខ្ពស់ដែលមិនមានភារកិច្ចនៅកន្លែង កើតហេតុ និងអ្នកចង់ចូលមើលកន្លែងកើតហេតុ មិនត្រូវបានអនុញ្ញាតឱ្យចូលមើលឡើយ។អ្នកកាន់កាប់សៀវភៅបញ្ជី មានភារកិច្ចត្រួតពិនិត្យអ្នកដែលងាចចូលកន្លែងកើតហេតុបាន ដូច្នេះគាត់ត្រូអង្គុយនៅច្រកចេញកន្លែងកើតហេតុដែលគេហៅថា"ច្រកចេញចូលតែមួយ" [46] ។

[46] . សៀវភៅ **មគ្គុទេសសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៨២

### ២. មន្រ្តីថតរូប ឬថតវីឌីអូនៅកន្លែងកកើតហេតុ

អ្នកស៊ើបអង្កេតត្រូវតែថតរូប ឬវីឌីអូ នៅកន្លែងកើតហេតុ ដែលមានទិដ្ឋភាពពីខាងមុខ ពីខាងក្រោយ ពីចំហៀងនៃកន្លែងកើតហេតុ។ មន្ត្រីណគរបាលម្នាក់ត្រូវចាត់តាំងជាអ្នកថតរូប ហើយមិនត្រូវធ្វើអោយម៉ាស៊ីនថតរូប ឬម៉ាស៊ីនថតវីឌីអូខូច ឬថតមិនកើតនោះទេ ព្រោះរូបភាព និងវីឌីអូមានសារៈសំខាន់ណាស់ សម្រាប់ស៊ើបអង្កេត ហើយវាជាភស្តុតាងដ៏សំខាន់សម្រាប់បង្ហាញចំពោះមុខតុលាការទៀតផង ជាពិសេសវាបានបង្ហាញពីអ្វីដែលអ្នកកត់ត្រាមិនបានកត់ត្រាចូលក្នុងបញ្ជីរបាយការណ៍ ហើយល្អជាងគំនូសប្លង់ដទៃ ឬកំណត់ ហេតុដើម។ គេរក្សាបញ្ជីរូបថតដែលថតបានទាំងអស់ និងសេចកដីបរិយាយខ្លីៗ ដើម្បីកុំអោយពិបាក់សំណត់ អត្តសញ្ញាណភស្តុតាងណាមួយនៅក្នុងដំណាក់កាលបន្តរបន្ទាប់មកទៀត[47]។

### ៣. មន្រ្តីគំនូសប្លង់កន្លែងកើតហេតុ

ដើម្បីកត់ត្រាអំពីស្ថានភាពនៅកន្លែងកើតហេតុ និងកំណត់ទីតាំងស្ថានភាពនៃវត្ថុតាង គេត្រូវគូសគំនូសប្លង់ទីតាំងកន្លែងកើតហេតុ បើទោះជាបានថតរូបហើយក៏ដោយ ពពោះវាអាចនឹងរលុបមុនពេលយកទៅប្រើប្រាស់ ឬចៃដន្យត្រូវបាត់ ឬខូចជាដើម។ ទន្ទឹងនិងនេះដែរ វាចាំបាច់ដល់ការនិយាយយោងដល់ទីតាំងនៃវត្ថុតាង ឬស្ថានភាពទីតាំងក់តហេតុនោះ។ បញ្ហាអាចធ្វើទៅបានដោយនិយាយយោងដល់គំនូសប្លង់ដោយដៃ[48]។ ទោះបីជាបានធ្វើគំនូសប្លង់នៅកន្លែង កើតហេតុក៏ដោយ ក៏រាល់ការវាស់វែងទាំងអស់ត្រូវដាក់សញ្ញាសំគាល់អោយបានត្រឹមត្រូវដើម្បីកំណត់ទីតាំងត្រឹមត្រូវ នៃវត្ថុតាង គ្រឿងសង្ហារឹម ទ្វារ បង្អួច និងវត្ថុផ្សេងៗទៀត។

### ៤. មន្រ្តីឆែកឆេ និងរឹបអូស

ចំពោះមន្រ្តីដែលជាអ្នកឆែកឆេរ នឹងរឹបអូស វាអាស្រ័យទៅលើទីកន្លែងកើតហេតុនីមួយៗ និងមន្ត្រីដែលមានភារកិច្ចចូលក្នុងកន្លែងកើតហេតុ និងស្រាវជ្រាវរកវត្ថុតាង ។ មន្ត្រីគ្រប់រូបដែលចូលទៅកាន់កន្លែងកើតហេតុ គឺចាំបាច់ត្រូវពាក់ស្រោមដៃ ពាក់ម៉ាស និងមានស្រោម ឬចង់ច្រកពីលើស្បែកជើង ។

ឈ្មោះមន្រ្តីទាំងអស់ដែលចូលទៅក្នុងកន្លែងកើតហេតុ ត្រូវបានកក់ចូលក្នុងសៀវភៅបញ្ជីកន្លែងកើតហេតុដោយមានបញ្ជាក់ពីពេលម៉ោង និងមូលហេតុ ច្បាស់លាស់ ដែលពួកគេចូលទៅនោះ ។ ការស្រាវជ្រាវរបស់ពួកគាត់គឺត្រូវបានធ្វើដោយម៉ត់ចត់ និងពេញលេញក្នុងការស្វែងរកតម្រុយ ឬវត្ថុតាង ។ វត្ថុតាងដែលត្រូវដែលត្រូវបានរកឃើញនៅកន្លែងកើតហេតុនោះ គឺវាមានតម្លៃ ភស្តុតាងដទៃៗទាំងអស់ដែលវាអាចបង្ហាញប្រាប់ថាការ

[47] . សៀវភៅ **មគ្គុទេសសម្រាប់មន្រ្តីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ គ្រង់ ទំព័រ ៨៣

[48] .គំរូនៃគំនូសប្លង់កន្លែងកើតហេតុមានក្នុងឧបសម្ព័ន្ធ

ស្រាវជ្រាវអាចមានទំហំប៉ុណ្ណា ។ ជាទូទៅការស្រាវជ្រាវ គេមិនធ្វើការប្រញាប់ប្រញាល់នោះទេ ពោលគេត្រូវចាប់ផ្ដើមវាមួយៗ ពីចំណុចមួយទៀត ។

### ៥. មន្ត្រីគ្រប់គ្រងវត្ថុតាង

នៅមុនពេលធ្វើការរឹបអូសភស្តុតាងណាមួយពីកន្លែងកើតហេតុ ជានិច្ចជាកាលចាំបាច់ត្រូវមានមន្ត្រីម្នាក់គ្រប់គ្រងវត្ថុតាង ។ ការទទួលខុសត្រូវតែមួយគត់គឺការទទួលយកវត្ថុតាង ហើយបន្ទាប់មកត្រូវគ្រប់គ្រងវត្ថុតាងដែលបានរឹបអូសនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតទាំងមូល ។ មន្ត្រីរូបនេះត្រូវសរសេរឈ្មោះ កាលបរិច្ឆេទ និងចុះហត្ថលេខារបស់ខ្លួននៅលើស្លាកសញ្ញាសំគាល់វត្ថុតាង នៅពេលដែលគាត់ទទួលយកវត្ថុតាងនោះ ហើយត្រូវរក្សាទុកវត្ថុតាងទាំងអស់នោះនៅជាមួយគាត់ រហូតដល់គាត់ប្រគល់វាឲ្យប្រគល់វាឲ្យទៅប៉ុស្តិ៍នគរបាល ហើយបន្ទាប់មកត្រូវទុកយ៉ាងម៉ត់ចត់ និងមានសុវត្ថិភាព ។ នៅពេលដែលគេត្រូវការវត្ថុតាងទាំងនោះយកទៅធ្វើវិភាគ ជាអាទិ៍ នៅកន្លែងកោសល្យវិច្ច័យ ឬបានស្នើដោយអ្នកជំនាញបច្ចេកទេសណាមួយ វាគឺជាភារកិច្ចរបស់មន្ត្រីគ្រប់គ្រងវត្ថុតាង ក្នុងការសម្រួលសម្រួលការងារនេះដែលជានិច្ចជាកាលត្រូវតែធានាកិច្ចដំណើរការគ្រប់គ្រងវត្ថុនីមួយៗឲ្យបានពេញលេញ ។ មន្ត្រីគ្រប់គ្រងវត្ថុតាង ត្រូវតែរក្សាទំនាក់ទំនងឲ្យបានទៀងទាត់ជាមួយមន្ត្រីស៊ើបអង្កេតដែលគាត់អាចនឹងប្រាប់ពីការធ្វើវិភាគវត្ថុតាងចាំបាច់មួយចំនួន ។ ប្រសិនបើជាព្រះរាជអាជ្ញា ឬមេធាវីណាម្នាក់ចង់ពិនិត្យមើលវត្ថុតាងណាមួយ គឺជាការទទួលខុសត្រូវទៀតរបស់មន្ត្រីគ្រប់គ្រងវត្ថុតាងនោះក្នុងការសម្របសម្រួលការងារនេះ ។ នៅពេលដែលករណីនេះត្រូវបានបញ្ជូនទៅតុលាការដើម្បីជំនុំជម្រះ វាក៏ជាការទទួលខុសត្រូវទៀតរបស់មន្ត្រីគ្រប់គ្រងវត្ថុតាង ក្នុងការធានាថារាល់វត្ថុតាងចាំបាច់ទាំងអស់ត្រូវបានបញ្ជូនទៅតុលាការ [49]។

## ផ្នែកទី២៖ បច្ចេកទេសក្នុងការប្រមូល និងរក្សាទុកវត្ថុតាង

ការប្រមូលភស្តុតាងទាំងអស់ ត្រូវតែវេចខ្ចប់ ដឹកជញ្ជូន និងរក្សាទុក តាមសមាសភាពដើមរបស់វាមិនត្រូវផ្លាស់ប្តូរ ឬប្រែប្រួលវាទៅជាវត្ថុផ្សេងទេរហូតដល់អ្នកជំនាញត្រួតពិនិត្យ ឬរហូតត្រូវបានគេបង្ហាញវានៅតុលាការ ។ ការធ្វើបែបនេះ គឺជាដំណាក់កាលដំបូងក្នុងការប្រមូលភស្តុតាងប្រកបដោយវិជ្ជាជីវៈ ដែលផ្តល់ផលវិជ្ជាមានដល់ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ ។

### កថាខណ្ឌ១៖ ការប្រមូលវត្ថុតាងជាសំលៀកបំពាក់

ចំពោះបំណែកក្រណាត់ពីសំលៀកបំពាក់ អាចមានទូទៅនៅកន្លែងកើតហេតុ វាអាចជារបស់ជនល្មើស ឬជនរងគ្រោះជាអ្នកបន្សល់ទុក ហើយវាមិនត្រឹមតែអាចជួយក្នុងការកំណត់អត្តសញ្ញាណមនុស្សតាមរយៈភិន

[49] .សៀវភៅ **មគ្គុទេសសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៨៥

ភាគរបស់វាប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងអាចមានតម្លៃជាភស្តុតាងកោសល្យវិច្ឆ័យបានទៀតផង ។ នៅពេលរកឃើញវានៅកន្លែងកើតហេតុ ត្រូវដាក់លេខសំគាល់ហើយថតរូប ហើយប្រសិនបើយល់ថាចាំបាច់ត្រូវកក់ចំណាំទីតាំងចំៗ ដោយធ្វើការវាស់វែងវត្ថុនោះពីជ្រុងម្ខាងទៀតនៃកន្លែងកើតហេតុ ដែលអាចឲ្យដឹងពីទីតាំងវត្ថុនោះពិតប្រាកដ ។ បញ្ជាក់ថា ទីតាំងវត្ថុតាងនោះត្រូវកត់ចំណាំក្នុងគំនូសប្លង់ដោយដៃ មុននឹងយកវាចេញពីកន្លែងកើតហេតុ ។ ក្នុងការរៀបចំទុកដាក់ វេចខ្ចប់សំលៀកបំពាក់ដោយក្រដាសប៉ុណ្ណោះ ព្រោះដោយសារវាអាចធានាឲ្យសម្ភារៈនោះមិនដុះផ្សិត និងប្រុងប្រយ័ត្ន ហើយរាល់ថង់ត្រូវតែវេចខ្ចប់ ក្នុងលក្ខណៈវិជ្ជាជីវៈ ដើម្បីរក្សារូបរាងភស្តុតាង ។ ម៉្យាងទៀត ការវេចខ្ចប់ត្រូវតែឲ្យបានជិតដែលគ្មានអ្វីអាចចេញចូលថង់ក្រដាសនោះបាន ។ ហើយចុងក្រោយត្រូវសរសេរបំពេញលើស្លាកសញ្ញាសម្គាល់វត្ថុតាង ហើយប្រគល់ឲ្យមន្ត្រីគ្រប់គ្រងវត្ថុតាង ។ វត្ថុតាងដែលចាប់បាន ត្រូវតែទុកនៅកន្លែងដែលមានសីតុណ្ហភាពត្រជាក់មធ្យម ស្ងួត និងដោយម៉ត់ចត់ មុននឹងប្រគល់វាទៅឲ្យប៉ុស្តិ៍នគរបាល ។

**កថាខណ្ឌ:២ ការប្រមូលវត្ថុតាងជាឯកសារ**

ការប្រមូលវត្ថុតាងជាឯកសារ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកភស្តុតាង ។ វត្ថុតាងជាឯកសារ គឺជាភស្តុតាងមួយប្រភេទដែលត្រូវបានបង្ហាញនៅពេលសវនាការ ក្នុងទម្រង់ជាសំនុំឯកសារ ។ វត្ថុតាងប្រភេទនេះ មិនមែនសំដៅតែទៅលើ វិក័យប័ត្រ កិច្ចសន្យា ឬមតកសាសន៍ជាដើមនោះទេ តាមពិតទៅ គឺរាប់បញ្ចូលទាំងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលតាមរយៈនោះ ព័ត៌មានអាចត្រូវបានរក្សាទុក ។ រូបថត ការថតសម្លេង ខ្សែរភាពយន្ត អ៊ីម៉ែល ជាអក្សរទាំងអស់នេះសុទ្ធតែជាទម្រង់នៃភស្តុតាងឯកសារ ។ ជាពិសេសត្រូវស្វែងរក ឯកសារទាំងឡាយដែលទាក់ទងនឹង ៖

- កិច្ចសន្យាហិរញ្ញវត្ថុ
- ឯកសារអត្តសញ្ញាណ ( លិខិតឆ្លងដែន សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ ។ល។ )
- លិខិតធ្វើដំណើរ ( ទិដ្ឋាការ សំបុត្រ ប័ណ្ណលើកដាក់ទំនិញ ។ល។ )
- កិច្ចសន្យាជួល ឬលិខិតភតិសន្យានៃទីតាំង ឬរថយន្ត )
- ការគ្រប់គ្រងសេវាអាជីវកម្ម ( បញ្ជីរាយមុខសេវា និងបញ្ជីតំលៃ តារាងទិន្នន័យ ។ល។ )

ជារឿយៗ ដែលត្រូវធ្វើការថតចំលងឯកសារដែលបានរឹបអូសសម្រាប់ប្រើការ ហើយទុកឯកសារដើមឲ្យបានគង់វង្សនៅក្នុងថង់មួយមានស្កុតបិទ តែត្រូវចាំ ត្រូវតែពាក់ស្រោមដៃនៅពេលចាប់កាន់ឯកសារទាំងនោះ ប្រសិនជាត្រូវការយកឯកសារនោះទៅពិនិត្យស្នាមក្រយៅដៃ ។ ក្នុងករណីនេះ ក៏ត្រូវធ្វើដូចករណីមុន គឺត្រូវដាក់វត្ថុនោះក្នុងថង់មួយ ហើយចាប់ភ្ជាប់ស្លាកសញ្ញាសម្គាល់វត្ថុតាងពីលើវា ប៉ុន្តែមិនទាន់បិទមាត់ថង់ ត្រូវរង់ចាំរហូតទាល់តែបានថតចំលងរួចរាល់សិន ។ ប្រសិនជាមាន ត្រូវដាក់វត្ថុតាងនៅក្នុងថង់ផ្លាស្ទិចមួយដោយសារនេះវានឹង

អាចឲ្យមន្ត្រីនគរបាល ឬព្រះរាជអាជ្ញា ពិនិត្យឯកសារនោះនៅថ្ងៃខាងមុខ ដោយមិនចាំបាច់ហែក ឬបកស្កុតនោះចេញឡើយ ។

**កថាខណ្ឌ៣៖ ការប្រមូលវត្ថុតាងជាអេឡិចត្រូនិក**

បច្ចេកវិទ្យាព័ត៌មាន តែងមានការវិវត្តន៍ជានិច្ច ហើយបច្ចេកវិទ្យានេះ ដើរតួនាទីរឹតតែសំខាន់ខ្លាំងឡើងថែមទៀត ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សទូទៅលើពិភពលោក ។ បច្ចុប្បន្ន គេអាចរក្សាទុកព័ត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់នៅក្នុងឧបករណ៍អេឡិចត្រូនិកដែលមានទំហំធំ ។ ពួកឧក្រិដ្ឋជន ក៏បាននឹងកំពុងតែកេងយកផលប្រយោជន៍ ពីការជឿនលឿនផ្នែកវិទ្យាសាស្ត្រនេះផងដែរ ។

ពួកឧក្រិដ្ឋជន ជានិច្ចជាកាល ប្រើប្រាស់ទូរស័ព្ទចល័ត កុំព្យូទ័រ ឧបករណ៍ធ្វើផែនការអេឡិចត្រូនិក និងឧបករណ៍ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតដើម្បីរក្សាទុកនិន្នន័យ ក្នុងការប្រព្រឹត្តសកម្មភាពល្មើសរបស់ពួកគេ ។ ដូច្នេះ មន្ត្រីនគរបាលដែលធ្វើការស៊ើបអង្កេតនោះអាចធ្វើទៅបាន ដោយមិនត្រូវអនុញ្ញាតឲ្យជនសង្ស័យនោះប្រើប្រាស់វត្ថុតាងទាំងនោះទេ ។ វត្ថុតាងអេឡិចត្រូនិក គឺជាភស្តុតាងមួយមានតម្លៃហើយគួរតែបានចាត់ទុកវាដូចគ្នានឹងភស្តុតាងកោសល្យវិច្ច័យដែរ ដោយថែរក្សាទុកយ៉ាងយកចិត្តទុកដាក់ ។

របៀបនៃការប្រមូល និងរក្សាទុក រក្សារូបរាងដើមរបស់វា គឺអាចជាការងារមួយដែលពិបាកស្មុគស្មាញ ប៉ុន្តែបើអាចរក្សាទុកវាបានត្រឹមត្រូវ វានឹងក្លាយជាភស្តុតាងមួយដ៏រឹងមាំប្រឆាំងនឹងជនសង្ស័យ ។ ត្រូវរក្សាទុកវត្ថុតាងនោះ នៅក្នុងបន្ទប់មួយដែលមានសីតុណ្ហភាពមធ្យម ដោយមិនត្រូវស្ថិតក្នុងភាពសើមខ្លាំង និងនៅឆ្ងាយពីទំនាញមេដែក ដូចជាវិទ្យុទាក់ទងជាដើម ។

**កថាខណ្ឌ៤៖ ការប្រមូលវត្ថុតាងជាវត្ថុដែលមុតស្រួច**

វត្ថុមុតស្រួចមួយចំនួនដូចជា កាំបិត ម្ជុល ឫដបបែកនៅកន្លែងកើតហេតុជាប្រភពមួយដ៏ល្អ សម្រាប់ស្វែងរកក្រយៅដៃ និងភស្តុតាង ឌី អិន អេ ។ វាក៏អាចបង្កគ្រោះថ្នាក់ផងដែរដល់មន្ត្រីនគរបាលដែលចាប់កាន់វត្ថុនោះដោយសារតែវាមានចុងមុតស្រួច ។ គេមិនអាចដាក់វត្ថុបែបនេះដោយផ្ទាល់ ចូលទៅក្នុងថង់ផ្លាស្ទិចបាន ព្រោះវាអាចចាក់ទម្លាយគូទថង់បាន ដូចនេះគេត្រូវដាក់វាចូលក្នុងដបផ្លាស្ទិចរឹងជាមុន មុននឹងដាក់វាចូលក្នុងថង់ផ្លាស្ទិកសម្រាប់ដាក់វត្ថុតាង ។ តែគេត្រូវបិទដបនោះមុននឹងដាក់វាទៅក្នុងថង់ផ្លាស្ទិក ។ ហើយបន្ទាប់មកធ្វើដូចការរៀបរាប់ខាងមុនៗ គឺសរសេរបំពេញជាភាសាខ្មែរលើស្លាកសញ្ញាសំគាល់វត្ថុតាង ហើយបិទលើថង់ផ្លាស្ទិកនោះមុនប្រគល់ឲ្យមន្ត្រីគ្រប់គ្រងវត្ថុតាង ។ ប្រសិនបើវត្ថុមុតស្រួចនោះ មានផ្ទុកភស្តុតាង ឌី អិន អេ ត្រូវរក្សាទុកនៅកន្លែងមួយដែលស្ងួត ដើម្បីរក្សាភស្តុតាងនោះ ពេលខ្លះគេរក្សាវាទុកនៅក្នុងទូរទឹកកក [50]។

[50] .គំរូនៃការវេចខ្ចប់វត្ថុមុតស្រួច មាននៅក្នុងឧបសម្ព័ន្ធ

**កថាខណ្ឌ៥៖ ការប្រមូលវត្ថុតាងជាស្លាកស្លាមផ្សេងៗ**

ជាញឹកញាប់ គេតែងតែរកឃើញនូវ ស្លាកស្លាគ ដូចជា កង់ ឡាន ម៉ូតូ ស្នាមស្បែកជើង ឬស្នាមក្រយៅដៃ ក្រយៅជើង ជាដើម នៅក្នុងកន្លែងកើតហេតុ ។ ដូច្នេះ ចំពោះស្នាមស្បែកជើង គេត្រូវថតរូបពិស្តារ លើស្នាមជិតទាំងនោះនីមួយៗដើម្បីធ្វើការ ។គេត្រូវដាក់បន្ទាត់ពីរចំហៀង និងនៅខាងខ្នងនៃស្នាមជាន់ស្បែកជើងដើម្បីវាស់ទំហំស្នាមជាន់ជើងនោះហើយជានិច្ចជាកាលត្រូវថតជិតមុខចំពីលើស្នាមដើម្បីឲ្យមើលឃើញច្បាស់ពីទំហំស្នាមជាន់ស្បែកជើងទាំងនោះ ។ នៅពេលកិនភាគត្រូវបានថតត្រឹមត្រូវហើយ ជានិច្ចជាកាលគេពិនិត្យពិច្ច័យទៅលើស្នាមពុម្ពជាលំអិតបន្ថែមទៀត ដើម្បីឲ្យចេញជារូបរាង និងធ្វើការប្រៀបធៀបឲ្យកាន់តែច្បាស់ ។

**កថាខណ្ឌ៦៖ ការប្រមូលវត្ថុតាងជាស្លាមម្រាមដៃ**

ស្នាមម្រាមដៃ និងបាតដៃនៅកន្លែងកើតហេតុ គឺជាវត្ថុតាងដ៏មានតម្លៃបំផុត ក្នុងការសន្និដ្ឋានរបស់អ្នកជំនាញដែលអាចជួយការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តធម៌ ឈានទៅរកនូវលទ្ធផលមួយយ៉ាងឆាប់រហ័សក្នុងការកំណត់ អត្តសញ្ញាណជនល្មើស និងជនដែលពាក់ព័ន្ធនៅកន្លែងកើតហេតុ ។ជានិច្ចជាកាលតែងតែមានចម្ងល់ពីស្នាមដៃនេះ ថាហេតុអ្វីបានជាអាចមានស្នាមម្រាមដៃកើតឡើង ? តាមលក្ខណៈធម្មជាតិខ្នាំងដៃម្រាមដៃ ត្រូវបានចេញជាទម្រង់នៅពេលទារកនៅក្នុងស្បូន ។ ខ្នាំងដៃចាប់ផ្តើមវិវត្តលើមេដៃនិង ម្រាមដៃ ។ គោលបំណងនៃខ្នាំងដៃចាប់កាន់វត្ថុអ្វីមួយបានយ៉ាងរឹងមាំជៀសវាងការរបូត ។ ខ្នាំងដៃអាចធ្វើឲ្យម្រាមដៃចាប់យកនូវវត្ថុបាន ។ ខ្នាំងដាំកកិតលើម្រាមដៃរបស់ពួកគេទោះតិច ឬច្រើន ។ ម្រាមដៃទាំងអស់មានការបង្កើតនិងរៀបចំតែមួយប៉ុណ្ណោះលើគម្រូ និងលក្ខណៈនៃខ្នាំងដៃ ។ ខ្នាំងដៃមានចង្អូរដែលញើសហូរ ។ ញើសផ្សំជាមួយនឹង ប្រេងលើដងខ្លួននិងធូលីបង្កើតជាស្នាមម្រាមដៃលើផ្ទៃរលោង ។អ្នកជំនាញខាងស្នាមម្រាមដៃប្រើប្រាស់ម្សៅ និងសារធាតុគីមីដើម្បីធ្វើឲ្យមើលឃើញនូវស្នាមម្រាមដៃទាំងនោះ ។ ភាពដែលអាចមើលឃើញនេះ អាស្រ័យលើផ្ទៃដែលពួកគេប៉ះពាល់ ប៉ុន្តែអ្នកជំនាញស្នាមម្រាមដៃអាចបង្កើនការទាញយកស្នាមម្រាមដៃពីផ្ទៃជាច្រើន ។ រយៈពេលនៃស្នាមម្រាមដៃគឺស្ទើរតែពុំអាចកំណត់បាន ដែលជាញឹកញាប់ ចុងចោទតែងនិយាយថា ពួកគេនៅកន្លែងកើតហេតុហើយបានបន្សល់ទុកស្នាមម្រាមដៃ មុនពេលអំពើល្មើសកើតឡើង ។ ស្នាមម្រាមដៃ អាចត្រូវបានរកឃើញស្ទើរតែគ្រប់ទីតាំងនៅកន្លែងកើតហេតុ ។ ស្នាមទាំងនោះអាចរកឃើញ នៅលើកែវព័រសាឡៃន ដប កន្លែងដុសខាត់លាបថ្នាំ ឬផ្ទៃរលោងផ្សេងៗទៀត បង្កាន់ដៃទ្វារ កន្លែងកុងតាក់ភ្លើង ឌីវីឌី ឬស៊ីឌី គ្រឿងបរិក្ខារលោង និងក្រដាសជាដើម ។ ល ។ ស្នាមម្រាមដៃនេះអាចប្រភេទខុសគ្នាៗ ដែលមានដូចជា **ស្នាមម្រាមដៃប្លាស្ទិក ស្នាមម្រាមដៃដែលកើតឡើងពីសារធាតុខាងក្រៅ ស្នាមម្រាមដៃដែលកើតចេញពីសរីរាង្គក្នុងខ្លួន និង ស្នាមម្រាមដៃដែលមើលពុំឃើញ** ។

**កថាខណ្ឌ៧៖ ការប្រមូលភស្តុតាងជា ឌី អ៊ិន អេ** (DNA)

នៅក្នុងចំណុចនេះ យើងនិងធ្វើការសិក្សាលម្អិត ថាតើអ្វីជា ឌី អ៊ិន អេ ? ហើយគេធ្វើការប្រមូលវាដោយវិធីណាខ្លះ ?

**១.សញ្ញាណទូទៅនៃ ឌី អ៊ិន អេ** (DNA)

អ្វីទៅជា ឌី អ៊ិន អេ (DNA) ? ឌី អ៊ិន អេ ឬអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិន គឺជាធាតុដំបូងនៃស្បែនទាំងមូលរបស់មនុស្សដែលត្រូវបានបង្កើតឡើង ។ ជាងនេះទៅទៀត ឌី អ៊ិន អេ របស់មនុស្សម្នាក់គឺដូចគ្នារបស់កោសិកានីមួយៗ ។ ឧទាហរណ : ឌី អ៊ិន អេ នៅក្នុងឈាមរបស់មនុស្សប្រុសម្នាក់ គឺដូចគ្នានិង ឌី អ៊ិន អេ នៅកោសិកាស្បែក ទឹកកាម និងទឹកមាត់របស់គាត់ ។ ឌី អ៊ិន អេ គឺជាវត្ថុតាងដ៏មានដ៏ឥទ្ធិពលពីព្រោះមនុស្សម្នាក់ៗគឺមាន ឌី អ៊ិន អេ ខុសគ្នាលើកលែងតែករណីភ្លោះ ។ ដោយសារតែភាពខុសគ្នានេះ ឌី អ៊ិន អេ ដែលបានប្រមូលពីកន្លែងកើតហេតុ អាចទាក់ទងនិងជនសង្ស័យជាមួយនិងភស្តុតាង ឬ ដោះលែងជនសង្ស័យ ដែលដូចនិងការប្រើប្រាស់ស្នាមម្រាមដៃដែរ ។

គេកំណត់នូវជនរងគ្រោះបានតាមរយះ ឌី អ៊ិន អេ ដែលបានពីសាច់ញាតិ សូម្បីតែនៅពេលដែលខ្លួនប្រាណពុំទាន់បានរកឃើញក៏ដោយ ។ តាមនីតិវិធីតុលាការ ឌី អ៊ិន អេ ដែលមានប្រយោជន៍នេះអាចត្រូវបានរកឃើញលើភស្តុតាងដែលមានអាយុកាលរាប់ទស្សវត្សន៍ ។ ប៉ុន្តែ អាចមានកត្តាមួយចំនួនដែលអាចជះឥទ្ធិពលដល់ ឌី អ៊ិន អេ ដែលនៅកន្លែងកើតហេតុ ដែលរួមមានកត្តាបរិស្ថាន ឧទាហរណ កម្តៅ ពន្លឺព្រះអាទិត្យ សំណើម បាក់តេរី ជាដើម ។ ដូច្នេះមិនមែនភស្តុតាងទាំងអស់សុទ្ធតែអាចប្រើប្រាស់បាននោះទេ ។ ជាងនេះទៅទៀត ដូចេជាស្នាមម្រាមដៃ ដែលការធ្វើតេសលើ ឌី អ៊ិន អេ មិនអាចប្រាប់មន្ត្រីថា នៅពេលណាដែលជនសង្ស័យ នៅកន្លែងកើតហេតុបាន ឬរយះពេលប៉ុន្មាននោះទេ ។

ឌី អ៊ិន អេ អាចត្រូវបានរកឃើញលើខ្លួនមនុស្សដូចគ្នា ក្នុងឈាម ទឹកកាម កោសិកាស្បែក ក្រដាសជូតមាត់ សរីរាង្គ សាច់ដុំ កោសិកាខួរក្បាល ធ្មេញ ឬសក់ ទឹកមាត់ សំបោរ និងទឹកនោមជាដើម ។ល។ ម៉្យាងទៀត ភស្តុតាង ឌី អ៊ិន អេ ស្ទើរតែអាចប្រមូលបានពីគ្រប់ទីកន្លែង ដែលវាបានជួយដោះស្រាយករណីជាច្រើន នៅពេលដែលស៊ើបអង្កេតបានប្រមូលភស្តុតាងពីប្រភពទំនើប ពោលគឺប្រភពវេជ្ជសាស្រ្ត ។

**ឧទាហរណ៏ ៖**

- អំពើឃាតកម្ម អាចត្រូវបានកំណត់យ៉ាងច្បាស់ និងត្រូវបានដោះស្រាយ នៅពេលដែលជនសង្ស័យត្រូវបានយកពីទឹកមាត់នៅក្នុងពុម្ពធ្មេញ ដែលត្រូវគ្នានិង ឌី អ៊ិន អេ ដែលបានយកពីស្នាមខាំជនរងរបស់ជនរងគ្រោះ ។

- ជនល្មើសត្រូវបានចោទប្រកាន់ពីការបង្ខំរួមភេទ នៅពេលដែល ឌី អិន អេ របស់ជនសង្ស័យត្រូវ គ្នា និង ឌី អិន អេដែលប្រមូលបានពីប្រដាប់ភេទជនរងគ្រោះ៦ម៉ោងក្រោយពីកើតហេតុ ។

ករណីជាច្រើន ត្រូវបានដោះស្រាយដោយការវិភាគ ឌី អិន អេ ទឹកមាត់លើ ចាន បារី ដប និង កោសិកាស្បែកដែលបានពីដែកកេះអុចបារី ជាដើម ។ល។ កោសិកាតែពីរ បី ប៉ុណ្ណោះ គឺគ្រប់គ្រាន់សម្រាប់ប្រមូលព័ត៌មាន ឌី អិន អេ ដ៏មានប្រយោជន៍ ដើម្បីជួយដោះស្រាយករណីក្នុងការស៊ើបអង្កេតទាំងឡាយ ។ បញ្ជីខាងក្រោម កំណត់នូវភស្តុតាងទូទៅមួយចំនួន ដែលគេអាចត្រូវការដើម្បីប្រមូលកន្លែងដែលអាចប្រមូល ឌី អិន អេ លើភស្តុតាង ប្រភពវេជ្ជសាស្ត្រដែលផ្ទុកកោសិកា[51] ។

## ២. ការប្រមូល និងថែរក្សា ឌី អ៊ិន អេ (DNA)

ជានិច្ចជាកាល អ្នកពិសោធន៍ រួមមានមន្ត្រីនគបាលយុត្តិធម៌ ជាអ្នកអនុវត្តនូវបេសកកម្មទាំងនេះ ក្នុងការកំណត់ភស្តុតាង និងមានភាពងាយស្រួលក្នុងការឈានទៅដល់ការកំណត់អទិភាពនៃបទល្មើស ។ វិធីសាស្ត្រនៃការនៃការប្រមូលទាំងនោះរួមមាន ៖

-គេត្រូវពាក់ស្រោមដៃ និងម៉ាសបិទមុខ ប្រើសំឡីចាប់យកសំណាកឈាម ឬសំណាក ឌី អិន អេ ។ប្រភេទផ្សេងទៀត

-ប្រសិនបើមានស្នាមប្រឡាក់នោះស្ងួត គេត្រូវប្រើទឹកស្តេរីល បន្តិចពីលើស្នាមប្រឡាក់នោះដើម្បីផ្សើមវា និងដើម្បីឲ្យដានស្នាមប្រឡាក់នោះត្រឡប់មកវិញ

-នៅពេលដែលស្នាមប្រឡាក់បានស្ងួតនៅលើសំឡីជូត ត្រូវដាក់សំឡីនោះចូលទៅក្នុងដបប្រអប់ជិតមួយ

-បន្ទាប់មក ត្រូវដាក់វត្ថុតាងដែលនៅក្នុងប្រអប់នោះទៅក្នុងថង់ផ្លាសស្ទិចដាក់ភស្តុតាង

-ដើម្បីបិទមាត់ថង់ផ្លាសស្ទិចសម្រាប់ដាក់ភស្តុតាង ត្រូវគូសតាមបណ្តោយផ្នែកខាងលើមាត់ថង់

-បិទមាត់ថង់ដាក់ភស្តុតាង ដោយបត់ថង់ផ្នែកខាងលើ ចំពីលើខាងក្រោមបន្ទាត់ដែលមានជាតិស្អិត

-ដោយសារស្លាកសញ្ញាសម្គាល់វត្ថុតាងត្រូវបានសរសេរជាភាសាអង់គ្លេស ត្រូវសរសេរបំពេញស្លាកសញ្ញាសម្គាល់ វត្ថុតាងដែលមានេជាតិស្អិតជាភាសាខ្មែរ ហើយបកបិទពីលើថង់ដាក់វត្ថុតាង ហើយចុងក្រោយប្រគល់វាឲ្យមន្ត្រីគ្រប់គ្រងវត្ថុតាង ។ ការរក្សាទុកបន្ទាប់ពីការរឹបអូស រាល់វត្ថុតាងទាំងអស់ដែលមានសារធាតុ ឌី អិន អេ ត្រូវតែរក្សាទុកឲ្យបានត្រឹមត្រូវនៅក្នុងទូរទឹកកកមួយ នៅពេលប្រគល់ទៅប៉ុស្តិ៍នគបាល ។ ការប៉ះពាល់ដោយផ្ទាល់ទៅនិងពន្លឺនិងៈអាកាសធាតុក្តៅ អាចនិងធ្វើឲ្យខូចសារធាតុភស្តុតាងនោះ ដូច្នេះគេជៀសវាងដាក់ភស្តុតាងប្រភេទនេះ នៅកន្លែងដែលមានអាកាសធាតុក្តៅដូចជានៅក្នុងបន្ទប់ ឬក្នុងរថយន្តដែលគ្មានម៉ាស៊ីនត្រជាក់ជា

[51] .បញ្ជីកំណត់រក ឌី អិន អេ ក្នុងឧបសម្ព័ន្ធ

ដើម ព្រោះវានិងអាចស្ងួតដោយសារកំដៅ ។ ត្រូវរក្សាទុកវត្ថុតាងនៅកន្លែងមួយដែលមានអាកាសធាតុត្រជាក់ស្ងួត ដែលជាមធ្យោបាយដ៏ល្អបំផុតក្នុងការរក្សាទុកភស្តុតាងបែបនេះមុនបញ្ជូលវាទៅមន្ទីរពិសោធន៍ ។

❖ **ប្រការគួរយល់ដឹងដើម្បីជៀសវាងការធ្វើឲ្យខូចភស្តុតាង ឌី អិន អេ** :

-ពាក់ស្រោមដៃ និងប្តូរវាឲ្យបានញឹកញាប់

-ពាក់ម៉ាសបិទមុខ-ប្រើសម្ភារៈតែម្តងរួចបោះចោល ឬសម្អាតវាមុនពេល និងក្រោយពេលប៉ះពាល់សំណាក់នីមួយៗ

-ជៀសវាងប៉ះពាល់កន្លែងដែលគិតថាមាន ឌី អិន អេ

-ជៀសវាងការនិយាយច្រើន កណ្តាស់ និងក្អកលើភស្តុតាង

-ជៀសវាងការប៉ះមុខ ច្រមុះ និងមាត់ខ្លួនឯង នៅពេលប្រមូល និងវេចខ្ចប់ភស្តុតាង

-សម្ងួតភស្តុតាងក្នុងខ្យល់មុនពេលវេចខ្ចប់

-ដឹកជញ្ជូន និងថែរក្សាទុកឲ្យបានត្រឹមត្រូវ ។

ប្រសិនបើវត្ថុតាងនោះគេឃើញ ជាដំណក់ទឹកកាមដែលមាននៅលើស្រោមអនាម័យ ដែលគេបានប្រើនៅពេកប្រព្រឹត្តបទល្មើស គេត្រូវដាក់វាក្នុងដបស្តែរិលដាក់វត្ថុតាងមួយ ដែលអាចឲ្យខ្យល់ស្ងួត មុននិងធ្វើការវេចខ្ចប់ដាក់ក្នុងថង់ផ្លាស្ទិច ។ ការធ្វើដូច្នេះ គឺវាអាចរក្សារូបរាងពិតប្រាកដរបស់វត្ថុតាងនោះ ហើយគេបិទគម្របដប បន្ទាប់មកត្រូវយកបង់ស្អិត ឬស្កុតបិទជុំវិញផ្នែកគម្របដបទាំងមូលដើម្បីធានាថា វានៅជាប់មិនរបូត ហើយវត្ថុធាតុរាវមិនអាចជ្រាប ឬហូរចេញបាន ។ ហើយធ្វើដូចមុនដែរគឺដាក់ទៅក្នុងថង់ផ្លាសស្ទិចដាក់វត្ថុតាង និងសរសេរបំពេញជាភាសាខ្មែរលើស្លាកសញ្ញាសំគាល់វត្ថុតាង រួចហើយបិទវាភ្ជាប់ពីចំហៀងថង់ មុននិងប្រគល់ឲ្យមន្ត្រីគ្រប់គ្រងភស្តុតាង[52] ។

## កថាខណ្ឌ៨៖ ការបិទកន្លែងកើតហេតុ

ការបិទកន្លែងកើតហេតុត្រូវបានគេបែងចែកជា ពីរ គឺ ការបិទកន្លែងកើតហេតុជាស្ថាពរ និង ការបិតកន្លែងកើតហេតុជាបណ្តោះអាសន្ន ។

### ១.ការបិទកន្លែងកើតហេតុជាស្ថាពរ

ការបិទកន្លែងកើតហេតុជាស្ថាពរ គឺជាការបិទកន្លែងកើតហេតុដោយបញ្ចប់ការពិនិត្យកន្លែងកើតហេតុដែលគណៈកម្មការយល់ឃើញថា បានពិនិត្យ និងធ្វើត្រឹមត្រូវគ្រប់តាមបែបបទនីតិវិធីរួចហើយ ក៏ប៉ុន្តែ កន្លែងកើត

[52] .សៀវភៅ **មគ្គុទេសសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ១១៧ ដល់ ទំព័រ ១២៥

ហេតុនេះនៅតែមានសុពលភាពសម្រាប់ការស្រាវជ្រាវចំពោះមន្ត្រីនគបាលយុត្តិធម៌ ។ ហើយការបិទកន្លែងកើតហេតុនេះ មិនចាំបាច់ដាក់កម្លាំងការពារឲ្យមានសន្តិសុខសុវត្ថិភាពទៀតទេ។

### ២.ការបិទកន្លែងកើតហេតុជាបណ្ដោះអាសន្ន

ការបិទកន្លែងកើតហេតុជាបណ្ដោះអាសន្ន គឺជាការបិទកន្លែងកើតហេតុមួយរយៈពេល ហើយក្នុងរយៈពេលនៃការបិទនេះ គណៈកម្មការពិនិត្យស្រាវជ្រាវកន្លែងកើតហេតុមានសិទ្ធិធ្វើ រហូតដល់ចប់ ។ នីតិវិធីនៃការបិទកន្លែងកើតហេតុជាក់ស្ដែងដូចជា ការបិទផ្លុំបេ និងការដាក់កម្លាំងការពារជាដើម ។

#### ២.១ ការបិទផ្លុំបេ

ការបិទផ្លុំបេនៅកន្លែងកើតហេតុណាដែលកើតមានឡើងនៅក្នុងបន្ទប់ដូចជា នៅក្នុងការិយាល័យ ផ្ទះឃ្លាំង សណ្ឋាគារ ។ល។ ហើយសមាជិកគណៈកម្មការពិនិត្យកន្លែងកើតហេតុយល់ឃើញថា អាចបិទផ្លុំបេបាននៅលើទ្វាចេញចូល បង្អួច ជាដើម ។ នៅពេលបិទ សមាជិកគណៈកម្មការពិនិត្យកន្លែងកើតហេតុទាំងអស់ចាំបាច់ត្រូវចុះហត្ថលេខានៅលើផ្លុំបេ ។

#### ២.២ ការដាក់កម្លាំងការពារ

ការដាក់កម្លាំងការពារកន្លែងកើតហេតុឲ្យមានសន្តិសុខ សុវត្ថិភាពនៅកន្លែងកើតហេតុណាដែលគណៈកម្មការពិនិត្យកន្លែងកើតហេតុយល់ថា កន្លែងកើរហេតុមានទូធ្លាធំទូលាយដូចជា ទីសាធារណៈ សួនច្បាររមណីដ្ឋាន ផ្លូវថ្នល់ កន្លែងរាំកំសាន្ត ពេលមានប្រារព្ធពិធីផ្សេងៗ ។ល។ កន្លែងកើតហេតុត្រូវបន្តការគ្រប់គ្រងរហូតដល់មន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រមកដល់ ។ បើមន្ត្រីបច្ចេកទេសវិទ្យាសាស្ត្រពុំទាន់មកដល់ទេ ការត្រួតពិនិត្យកន្លែងកើតហេតុមិនអាចបញ្ចប់ជាផ្លូវការបាននោះទេ ។

### កថាខណ្ឌ៩៖ ការគ្រប់គ្រងកំណត់ហេតុ

កំណត់ហេតុដែលបានដាក់ឲ្យពិនត្យនៅកន្លែងកើតហេតុមានដូចជា[53] :

-កំណត់ហេតុពិនិត្យកន្លែងកើតហេតុ (កត់ត្រាអំពីសកម្មភាពបទល្មើស និងស្លាកស្នាមវត្ថុតាង)

-កំណត់ហេតុរូបថត (តារាងរូបថតកន្លែងកើតហេតុ)

-គំនូសប្លង់កន្លែងកើតហេតុ

-កំណត់ហេតុដកហូតវត្ថុតាង (រាល់វត្ថុតាងដែលជាប់ពាក់ព័ន្ធដល់សកម្មភាពល្មើស ឬវត្ថុសម្ភារៈដែលមានជាប់ស្លាកស្នាម ឬមធ្យោបាយប្រព្រឹត្តិបទល្មើស)

-កំណត់ហេតុសាកសួរបំភ្លឺ (ព័ត៌មានពីសាក្សីនៅជុំវិញកន្លែងកើតហេតុ មុនកើតក្រោយពេលកើតហេតនិងភ្ជាប់ដោយសាលាកប័ត្រ ភិនភាគមុខសញ្ញា)

[53]. សៀវភៅ **អត្ថាធិប្បាយច្បាប់ ភស្តុតាង ក្នុងរឿងក្ដីព្រហ្មទណ្ឌ** លោកចៅក្រម ហ៊ីង ធីឫទ្ធិ (ភាគ ២) ទំព័រ ៨៣ ដល់ ទំព័រ ៨៦

-កំណត់ហេតុប្រគល់ទទួល (កំណត់ហេតុធ្វើឡើងក្រោយពេលបញ្ចប់ពិនិត្យកន្លែងកើតហេតុ)

-របាយការណ៍បូកសរុប វាយតម្លៃករណីរឿងបម្រើឲ្យការស៊ើបអង្កេត (របាយការណ៍នេះធ្វើឡើងដោយប្រធានគ្រប់គ្រងកន្លែថកើតហេតុ ចូលរួមវាយតម្លៃសន្និដ្ឋានដោយសមាជិកគណៈកម្មការពិនិត្យស្រាវជ្រាវកន្លែងកើតហេតុ)

ក្រោយពេលប្រតិបត្តិការពិនិត្យកន្លែងកើតហេតុបានបញ្ចប់ បន្ទាប់មកគណៈកម្មការពិនិត្យកន្លែងកើតហេតុត្រូវបានកោះប្រជុំភ្លាមៗនៅកន្លែងកើតហេតុ ដើម្បីបូកសរុបវាយតម្លៃសន្និដ្ឋានជំហានដំបូង គឺ :

-ករណីរឿងហេតុកើតឡើងបណ្តាលមកពីរឿងអ្វីខ្លះ?

-សកម្មភាពបទល្មើសធ្ងន់ធ្ងរ ឬស្រាល ហើយប៉ះពាល់អ្វីខ្លះ?

-ជនល្មើសដែលចូលរួមសកម្មភាពប្រព្រឹត្តិមានចំនួនប៉ុន្មាននាក់?

-វាយតម្លៃព័ត៌មានជុំវិញកន្លែងកើតហេតុសមស្របតាមរឿងហេតុដែលកើតឡើងដែរឬទេ?

-សម្ភារៈ វត្ថុតាងដែលបានដកហូតនៅកន្លែងកើតហេតុមានអ្វីខ្លះ? ត្រូវពិនិត្យ និងកត់ត្រាលម្អិតនៅក្នុងកំណត់ហេតុ

-ការឃាត់ខ្លួនជនសង្ស័យ និងចម្លើយរបស់ជននោះភ្លាមៗនៅកន្លែងកើតហេតុស៊ីសង្វាក់និងព័ត៌មានប្រមូលបាននៅកន្លែងកើតហេតុ (សាក្សី) និងភស្តុតាងទាំងឡាយដែលប្រមូលបានពីកន្លែងកើតហេតុដែរឬទេ?

-វាយតម្លៃលើការបាត់បង់ និងខូចខាតដូចជា អាយុជីវិតមនុស្ស សត្វ និងទ្រព្យសម្បត្តិ

-ត្រួតពិនិត្យមើលការងារទាំងអស់ឡើងវិញម្តងទៀតតើធ្វើបានត្រឹមត្រូវតាមនីតិវិធីដែរ ឬទេ? តើអាចបញ្ចប់ការត្រួតពិនិត្យកន្លែងកើតហេតុបានឬអត់?

## ផ្នែកទី៣៖ បេសកម្មក្នុងការស្វែងរកជនល្មើស

ពាក់ព័ន្ធនឹងផ្នែកចុងក្រោយនេះ យើងនឹងការសិក្សាទៅលើ បេសកកម្មក្នុងការស្វែងរកស្វែងរកជនល្មើសតាមវិធីសាស្ត្រផ្សេងៗ ដូចខាងក្រោម :

### កថាខណ្ឌ១៖ ការស្វែងរកតាមរយៈការសម្ភាសន៍សាក្សី និងជនរងគ្រោះ

ការសម្ភាសន៍ គឺជាជំនាញស៊ើបអង្កេតមួយដែលមិនអាចមើលរំលងមន្ត្រីនគរបាលយុត្តិធម៌នៅលើពិភពលោក។ ករណីជាច្រើនមន្ត្រីស៊ើបអង្កេត ដែលមានកាតព្វកិច្ចលើករណីនោះពួកគាត់ត្រូវបានតម្រូវឲ្យទៅជួបជនរងគ្រោះ និងសាក្សីដើម្បីទទួលបានចម្លើយកាន់តែប្រសើរឡើងជាងអ្នកដែលនៅពេលប្រព្រឹត្តបទល្មើសកើតឡើង។ ជាញឹកញាប់ការសម្ភាសន៍ គឺជាផ្នែកមួយក្នុងការស៊ើបអង្កេត។ បើទោះបីជាមានវត្ថុតាងមួយចំនួន

អាចបង្ហាញផ្លូវដល់អ្នកស៊ើងអង្កេត តែក្នុងករណីជាច្រើនភស្តុតាងបែបនេះពុំអាចរកបាននោះទេ។ ដូច្នេះ មន្ត្រីនគរបាលត្រូវតែពឹងផ្អែកលើចម្លើយ ជនរងគ្រោះ និងសាក្សី។

**កថាខណ្ឌ២៖ ការស្វែងរកតាមរយៈការសួរចម្លើយជនសង្ស័យ**

ការសួរចម្លើយ គឺជាការចោទសំណួរទៅលើជនសង្ស័យដែលថាបានប្រព្រឹត្តបទល្មើសណាមួយដែលខ្លួនស្ទាក់ស្ទើរ ឬមិនចង់សារភាពនូវអំពើដែលខ្លួនបានប្រព្រឹត្ត។ ឬម៉្យាងទៀត ជាការសន្ទនាដោយគ្រោងទុកមួយដើម្បីរាវរកការពិតស្តីពីបទល្មើស ឬហេតុការណ៍ជនសង្ស័យ។

គោលបំណងនៃការសួរចម្លើយ គឺដើម្បីទទួលបានចម្លើយសារភាពរបស់ជនសង្ស័យ និងរែកមុខជនដែលពាក់ព័ន្ធក្នុងអំពើពីល្មើស។ មន្ត្រីនគរបាលដែលជាអ្នកស៊ើបអង្កេតនោះ មិនត្រូវចេះតែទទួលយកចម្លើយសារភាពផ្តេសផ្តាសនោះទេ ចម្លើយសារភាពត្រូវតែលម្អិត គ្មានការផ្លាស់ប្តូរហើយស៊ីសង្វាក់ព្រមទាំងបំពេញបន្ថែមលើភស្តុតាង ចម្លើយសច្ចាធារណ៍ដែលប្រមូលបានជាមុននៅពេលស៊ើបអង្កេត។ ការដឹកនាំការសួរចម្លើយត្រូវទាំមទារឲ្យគោរពនូវវិធានមួយចំនួនមិនត្រូវតែក្នុងពេលប្រតិកម្មការប៉ុណ្ណោះទេ ថែមទាំងមុនពេលប្រតិបត្តិការផងដែរ។

**កថាខណ្ឌ៣៖ ការស្វែងរកតាមរយៈស្ទង់មតិតាមផ្ទះ**

ការស្ទង់មតិតាមផ្ទះគឺវាមានតម្លៃ វាជាវិធីសាស្ត្រស៊ើបអង្កេតយ៉ាងសំខាន់ដែលមឹងមានប្រយោជន៍ម្តងហើយម្តងទៀត ដែលជាដំណើរស៊ើបអង្កេតចេញពីផ្ទះមួយ ដែលនៅក្បែរទីកន្លែងកើតហេតុ ដើម្បីស្វែងរកសាក្សី។ ដែលជូនកាលសាក្សីមានការស្ទាក់ស្ទើរក្នុងផ្តលសក្ខីកម្មដោយស្ម័គ្រចិត្ត ហើយបើមិនធ្វើដូចនេះមន្ត្រីនគរបាលនឹងមិនទទួលបានភស្តុតាងទាំងនោះទេ បើគាត់មិនស្វែងរកទេនោះ[54]។

**កថាខណ្ឌ៤៖ ការការពារសាក្សី**

សាក្សី គឺជាបុគ្គលដ៏សំខាន់មួយ ក្នុងការធ្វើឲ្យការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌មានភារកិច្ចផងដែរលើការការពារសាក្សី។ យើងនឹងធ្វើពីមូលហេតុការការពារ និងវិធានការការពារនៅចំណុចខាងក្រោម :

**១. មូលហេតុនៃការការពារសាក្សី**

មន្ត្រីនគរបាលយុត្តិធម៌មានបេសកកម្ម មួយទៀត គឺការពារសាក្សីនៃបទឧក្រិដ្ឋ។ ហេតុអ្វីបានជាគេចាំបាច់ត្រូវការពារសាក្សី? មានមូលហេតុជាច្រើនដែលគេចាំបាច់ត្រូវការពារសាក្សី ៖

**-ដើម្បីជំនួយដល់ស៊ើបអង្កេត** : នៅក្នុងកំឡុងពេលស៊ើបអង្កេត សាក្សីពិតជាមានសារសំខាន់ណាស់ក្នុងការប្រមូលភស្តុងតាងទាក់ទងនឹងបទឧក្រិដ្ឋមួយ និងបុគ្គលទាំងឡាយដែលទទួលខុសត្រូវក្នុងបទឧក្រិដ្ឋ

[54] .សៀវភៅ **មគ្គុទេសសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ៧៩

នេះ។ សាក្សីអាចផ្តល់តម្រុយ ដែលអាចជួយដល់ការស៊ើបអង្កេត និងការផ្តន្ទាទោសបទឧក្រិដ្ឋជនណាម្នាក់ ឬមួយក្រុមជាយថាហេតុ។ ជូនកាលសក្ខីកម្មរបស់សាក្សី គឺជាភស្តុតាងដ៏សំខាន់បំផុតផងដែរ ក្នុងការប្រឆាំងតទល់នឹងចុងចោទក្នុងពេលសវនាការ។

**-ដើម្បីរក្សាសុចរិតនៃការជំនុំជម្រះក្តី** : ប្រសិនបើជាចុងចោទ និងឧក្រិដ្ឋជនផ្សេងទៀត ត្រូវបានគេអនុញ្ញាតឲ្យធ្វើការបំភិតបំភ័យ ឬធ្វើទុក្ខបុកម្នេញដល់សាក្សី ដូច្នេះសេចក្តីសុចរិតនៃការជំនុំជម្រះក្តីនឹងត្រូវអន្តរាយជាក់ជាមិនខានឡើយ។ សំណុំរឿងទាំងមូលរបស់ព្រះរាជអាជ្ញា អាចនឹងទទួលរងឥទ្ធិពលណាមួយ ប្រសិនបើសាក្សីសំខាន់ៗរបស់គាត់មិនអាចផ្តល់សក្ខីកម្មដូចដែលបានគ្រោងទុកនោះទេ។ ជូនកាល ករណីខ្លះអាចនឹងត្រូវលើកលែងការចោទប្រកាន់ ដោយគ្រាន់តែមានការបំភិតបំភ័យសាក្សី។

**-ដើម្បីទប់ស្កាត់បទឧក្រិដ្ឋមិនឲ្យមានកើតតទៅទៀត** : សាក្សីជួយដោយផ្ទាល់ ឬដោយប្រយោលក្នុងការនាំខ្លួនឧក្រិដ្ឋជនមកតុលាការដើម្បីកាត់ទោសទៅតាមច្បាប់ ដើម្បីបង្ការទប់ស្កាត់បទឧក្រិដ្ឋមិនឲ្យកើតមាននៅថ្ងៃអនាគត់។ ម៉្យាងវិញទៀត ការអនុញ្ញាតឲ្យឧក្រិដ្ឋជនណាម្នាក់បំភិតបំភ័យ ឬធ្វើទុកបុកម្នេញដល់សាក្សីណាមួយ អាចជាការរួមចំណែកបង្កបរិយាកាសភ័យខ្លាច និងមិនគោរពច្បាប់[55]។

## ២. វិធានការណ៍ក្នុងការការពារសាក្សី

ជារឿយៗ មន្ត្រីនគរបាល តែងតែគាំទ្រផ្លូវចិត្ត ផ្លូវអារម្មណ៍ ផ្លូវកាយ និងផ្តល់ជាយោបល់ដល់សាក្សីពោលគឺគាំទ្រផ្នែកសុខមាលភាព។ ដែលគេត្រូវធ្វើយ៉ាងណាមិនឲ្យពួកគេមានអារម្មណ៍ថាខ្លួនគេឯកោអសន្តិសុខនោះទេ ដូចជា មិនត្រូវឲ្យពួកគាត់រស់នៅនៅឆ្ងាយដាច់ពីគេ ហើយត្រូវតែមកមើលគាត់ញឹកញាប់។

ក្នុងករណីដែលមានការព្រួយបារម្ភខ្លាំង ពីហាភ័យដែលអាចកើតមានខ្ពស់ ត្រូវរកកន្លែងមួយសម្រាប់ពួកគាត់ស្នាក់នៅ ឬចាត់មន្ត្រីនគរបាលមួយចំនួនតាមការពារដោយសម្ងាត់ដើម្បីធានានូវសន្តិសុខរបស់ពួកគាត់។ មានពេលខ្លះសាក្សីខ្លួនឯងផ្ទាល់ក៏អាចឧក្រិដ្ឋជនផងដែរ ដែលអាចជាគូកនចាស់របស់ចុងចោទក៏មាន។ ក្នុងករណីនេះ សាក្សីដែលជាប់ពន្ធនាគារនោះ អាចប្រឈមមុខនឹងការគម្រាម កំហែងពីបុគ្គលដែលជាបក្នុងបន្ទប់ឃុំឃាំងជាមួយគ្នានោះក៏អាចថាបាន ដូចនេះគេត្រូវដាក់ពួកគេឲ្យនៅដាច់ដោយឡែកពីគ្នា ។

[55] .សៀវភៅ **មគ្គុទេសសម្រាប់មន្ត្រីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្ត្រីនគរបាលយុត្តិធម៌** របស់អង្គការ **អន្តរជាតិអន្តោប្រវេសន៍** ហៅកាត់ថា **IOM** បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២ ត្រង់ ទំព័រ ១៩៣ ដល់ ទំព័រ ១៩៤

# ជំពូកទី៤

# ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៤

# ការពិភាក្សាលើលទ្ធិផលនៃការស្រាវជ្រាវ

## ផ្នែកទី១៖ បញ្ហាប្រឈម

### កថាខណ្ឌទី១៖ ការធ្វេសប្រហែសគួបផ្សំ និងការខ្វះសម្ភារៈមធ្យោបាយ

#### ១.១ ការងារមួយចំនួនអសកម្ម

ការងារមួយចំនួនអសកម្ម គឺដោយសារកង្វះខាតនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើងបាន ធ្វើឱ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលសភាពការណ៍កើតឡើង។

#### ១.២ ការចាត់តាំងអនុវត្ត

ការចាត់តាំរបស់អង្គភាពពាក់ព័ន្ធនៅមានការយឺតយ៉ាវ ខ្វះការទទួលខុសត្រូវ គួបផ្សំនឹងការមិនបានត្រួត ពិនិត្យសកម្មភាពការងាររបស់មន្ត្រីគ្រប់ថ្នាក់ឱ្យបានត្រឹមត្រូវ ធ្វើឱ្យប្រសិទ្ធភាពនៃការអនុវត្តផែនការ វិធានមិនទាន់ ទទួលបានលទ្ធផលល្អនៅឡើយ។

#### ១.៣ ការងារស៊ើបអង្កេត និងការបង្ក្រាប

កាងារស៊ើបអង្កេត និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបតាមសំណូមពរ និងទិស ដៅផែនការការងារនៅឡើយ ជាពិសេស ការគ្រប់គ្រងមុខសញ្ញានៅក្នុងមូលដ្ឋាន ដូចជាមុខសញ្ញា ក្មេងទំនើងប្រើ ប្រាស់គ្រឿងញៀន មុខសញ្ញាមានដីការចាប់ខ្លួន មុខសញ្ញាករណីតស៊ូ និងមុខសញ្ញាដោះលែងចេញពីពន្ធាគារ។

#### ១.៤ ការខ្វះមធ្យោបាយ

ការខ្វះខាតមធ្យោបាយ សម្ភារៈ ថវិកា ដើម្បីបម្រើឱ្យកិច្ចប្រត្តិការស្រាវជ្រាវ ធ្វើឱ្យការងារប្រឆាំងនឹងបទល្មើស ព្រហ្មទណ្ឌ មិនបានទាន់ពេលវេលា។ ប៉ុន្តែពេលខ្លះមានមធ្យោបាយខ្វះប្រេង ឬអាគុយខូចជាដើម។

### កថាខណ្ឌទី២៖ អាណាព្យាបាលរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅក្នុងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ ស្ថិតក្រោមអំណាចរបស់ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរតាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងការបំពេញបេសកម្មមន្ត្រី នគរបាលយុត្តិធម៌ទទួលបញ្ជា ឬ សុំបញ្ជាតែពីអាជ្ញាធរតុលាការរហូតដល់ចប់កិច្ចប្រតិបត្តិការរបស់ខ្លួនតែ ប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវរាយការណ៍តាមឋានានុក្រមរបស់ខ្លួន អំពីរឿងហេតុកើត ឡើងនិងសុំយោបល់ដឹកនាំ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានអាណាព្យាបាលពីរគឺ តាមឋានានុក្រម នគរបាលរាជធានីភ្នំពេញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងការងារនីតិវិធីព្រហ្មទណ្ឌស្ថិតក្រោមការសម្រប សម្រួលរបស់ព្រះរាជអាជ្ញា។

### ២.១ គោលការណ៍ច្បាប់

តាមគោលការណ៍ច្បាប់ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងទុកឥតចាត់ការបានទេទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬ ក៏មានការដកពាក្យប្ដឹងក៏ដោយ។ មន្ត្រីនគរបាលយុត្តិធម៌ ក្រោយពីទទួលបញ្ជាពីថ្នាក់ដឹកនាំឱ្យធ្វើការសម្របសម្រួលបញ្ចប់រឿងទំនាស់មួយ ដោយមានការឯកភាពរវាងជនល្មើស និងជនរងគ្រោះ។ មន្ត្រីនគរបាលយុត្តិធម៌បានរៀបចំសំណុំរឿងមកកាន់ព្រះរាជអាជ្ញា នៅពេលព្រះរាជអាជ្ញាទទួលបានសំណុំរឿង គាត់ក៏បានពិនិត្យមើលអង្គហេតុ និងអង្គច្បាប់ចប់សព្វគ្រប់ហើយ គាត់យល់ឃើញថាមានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាក៏សម្រេចធ្វើការចោទប្រកាន់ បញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ។ ជាលទ្ធផលចុងក្រោយសំណុំរឿង ត្រូវបានបញ្ចប់ជាស្ថពរនៅស្ថប័នតុលាការ ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌ រូបនោះត្រូវបានថ្នាក់ដឹកនាំសម្រួលភារកិច្ច។

### កថាខណ្ឌទី៣៖ សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ

គោលការណ៍នៃក្រមនីតិវិធិព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា ៦០ បានផ្ដល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអវុធហត្ថ មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង[56]។ មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថ ចុះទៅដល់កន្លែងកើតហេតុដូចគ្នា មានសិទ្ធិពិនិត្យទីកន្លែងកើតហេតុ សម្ភាសន៍សាក្សី ជនរងគ្រោះ ស្រង់ចម្លើយជនសង្ស័យ និងឃាត់ខ្លួនជនសង្ស័យព្រមទាំងធ្វើការឆែកឆេររហូតដល់ចប់កិច្ចប្រតិបត្តិការរៀងៗខ្លួន។ គ្រប់បេសកម្មរបស់អង្គភាពទាំងពិរមានគោលដៅរួម មានគោលបំណងតែមួយគត់ គឺដើម្បីការពារផលប្រយោជន៍សាធារណៈ ទ្រព្យសម្បត្តិ អាយុជីវិត ដូច្នេះមិនចាំបាច់ឱ្យគាត់បំពេញភារកិច្ចជាន់គ្នា ដែលនាំឱ្យខាតបង់ពេលវេលាបាត់បង់ថវិការជាតិនោះទេ គឺ គួរតែបែងចែកភារកិច្ចរវាងមន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថឱ្យបានច្បាស់លាស់ក្នុងការដើរតួជាមន្ត្រីនគរបាលយុត្តិធ៌។

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៨១ បានចង្អុលបង្ហាញពីការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធហត្ថ នៅក្នុងវិស័យនគរបាលយុត្តិធម៌[57]។ ទោះបីជាក្រមនេះ បានចង្អុលបង្ហាញទៅលើអនុក្រឹត្យ ស្ដីពីការបែងចែកភារកិច្ចរវាងនគរបាលជាតិ និងកងរាជអាវុធហត្ថក៏ដោយ ប៉ុន្តែរហូតមកដល់ពេលនេះ នៅពុំទាន់ឃើញមានអនុក្រឹត្យ ស្ដីពីការកំណត់សមត្ថកិច្ចក្នុងការបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌នោះឡើយ។

[56] .មាត្រា ៦០ ស្ដីពី មន្ត្រីនគរបាលយុត្តិធម៌ នៃ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)

[57] .មាត្រា ៨១ ស្ដីពី មន្ត្រីនគរបាលយុត្តិធម៌ នៃ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)។

## ផ្នែកទី២៖ ដំណោះស្រាយ

### កថាខណ្ឌទី១៖ យន្តការបណ្តុះបណ្តាលជំនាញ និងច្បាប់

គោលនយោបាយកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍធនធានមនុស្ស និងការបង្កើនសមត្ថភាព វិជ្ជាជីវៈ នៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទតាមរយៈនៃការបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធិភាព។ក្រសួងមហាផ្ទៃ បានដាក់ចេញនូវយន្តការកំណែទម្រង់កងកម្លាំងនគរបាលជាតិឱ្យក្លាយជាកម្លាំងមួយដែលមានវិជ្ជាជីវៈពិតប្រាកដបំពាក់ ដោយបច្ចេកទេសទំនើប មានអត្តចរិតសុភាពរាបសារ មានសមត្ថភាពបំពេញភារកិច្ច មានស្មារតីទទួលខុសត្រូវខ្ពស់ គោរពប្រតិបត្តិច្បាប់ គោរពសិទ្ធិមនុស្សរក្សាសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ។ដើម្បីអនុវត្តយន្តការនេះ ក្រសួងមហាផ្ទៃបានប្រគល់ភារកិច្ចទៅឱ្យបណ្ឌិតសភានគរបាលកម្ពុជា ធ្វើជាសេនាធិការក្នុងការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិនៅទូទាំងប្រទេស។ ដើម្បីឱ្យបណ្ឌិតសភានគរបាលកម្ពុជា អនុវត្តបានតាមផែនការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិទទួលបានជោគជ័យ ត្រូវមានការគាំទ្រពីរាជរដ្ឋាភិបាល ពីក្រសួងមហាផ្ទៃ និងមានការចូលរួមសហការគ្រប់អង្គភាព គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសនាយកដ្ឋានបុគ្គលិកនៃអគ្គស្នងការដ្ឋាននគរបាលជាតិមានការគាំទ្រ និងមានយន្តការតាមដានចំពោះនិស្សិត សិក្ខាកាម ដែលបណ្ឌិតសភានគរបាលកម្ពុជាបានដាក់ពិន័យ ឬបណ្តេញ ចេញពីការសិក្សា។

### កថាខណ្ឌទី២៖ យន្តការពង្រឹងការអនុវត្តច្បាប់

#### ២.១ ការលុបបំបាត់អំពើពុករលួយ

ជាគោលការណ៍ ការលុបបំបាត់អំពើពុករលួយ នគរបាលយុត្តិធម៌ មិនត្រូវយកតួនាទីខ្លួនទៅការពារបនល្បែងសងបនស្រីពេស្យាចារ ឬ កន្លែងប្រព្រឹត្តអំពើអបាយមុខ អំពើពាលាអាវាសែដែលផ្ទុយនឹងច្បាប់ឡើយ។ មិនត្រូវយកតួនាទីខ្លួនទៅកាពារបទល្មើស ដូចជាការពារជនប្រព្រឹត្តសកម្មភាព ចាប់ជំរិត លួច ឆក់ ប្លន់កេងប្រវ័ញ្ចសម្បត្តិជាតិ ឬ កេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃដែលស្របច្បាប់ មិនត្រូវប្រើអំណាចគំរាមគំហែងទៅលើប្រជាពលរដ្ឋ ដើម្បីការពារជនល្មើស និងប្រើប្រាស់សម្ភាររបស់រដ្ឋបម្រើផលប្រយោជន៍ខ្លួន ព្រមទាំងហ៊ានប្រព្រឹត្តបទល្មើសផ្សេងៗ ដែលផ្ទុយនឹងច្បាប់ហើយមិនត្រូវលាក់សំណុំរឿង វត្ថុតាង ឬ ធ្វើការដោះដូរនូវវត្ថុតាង ដើម្បីប្រយោជន៍បុគ្គលណាមួយឡើយ។

#### ២.២ ការលុបបំបាត់វប្បធម៌អន្តរាគមន៍

បរិបទនៃសង្គមខ្មែរបច្ចុប្បន្ន តែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប វាគឺជាទម្លាប់ពលរដ្ឋខ្មែរក្នុងការទំនាក់ទំនងគ្នានៅក្នុងសង្គមទៅហើយ ប៉ុន្តែបញ្ហាទាំងនេះបានក្លាយជាទម្លាប់មិនអាចកែប្រែបាន សូម្បី តែអ្នក

រត់ម៉ូតូឌុបម្នាក់ក៏អាចស្គាល់នគរបាលម្នាក់ដែរ ក្នុងការជួយអន្តរាគមន៍ពេលដែលខ្លួនត្រូវការជាយថាហេតុ មិនថាមានរឿងរ៉ាវតូច ឬ ធំនោះទេ តែងតែចូលខ្លួនមកដោះស្រាយបញ្ចប់បញ្ហា ដោយមិនទុកឱ្យសមត្ថកិច្ចចាត់ការតាមនីតិវិធី និងច្បាប់ឡើយ។ អ្នកដែលមានអំណាច មានឋានៈនៅក្នុងសង្គមមួយចំនួន តែងតែលូកលាន់នៅក្នុងកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើឱ្យការបំពេញតួនាទីមិនទាន់បានល្អមិនបានប្រកាន់ភ្ជាប់នូវការអនុវត្តច្បាប់ និងមិនមានយុត្តិធម៌នៅក្នុងសង្គម។ ដើម្បីលុបបំបាត់នូវបញ្ហាទាំងនេះចាំបាច់ត្រូវពង្រឹងតួនាទី ភារកិច្ចរបស់មន្ត្រីនគបាលយុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់មូលដ្ឋានគ្រឹះ។ បើមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ មិនបានប្រតិបត្តិតាមច្បាប់ត្រូវទទួលពិន័យ និងទណ្ឌកម្មជាដាច់ខាតមិនត្រូវលើកលែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ដែលធ្វើឱ្យមានកំហុសឆ្គងក្នុងការបំពេញតួរនាទីនោះទេ។

### ២.៣ ការលុបបំបាត់វប្បធម៌និទណ្ឌភាព

កាលណាគ្មានយុត្តិធម៌នឹងធ្វើឱ្យមាននិទណ្ឌភាប បើមាននិទណ្ឌភាព គឺគ្មានភាពស្មើគ្នាចំពោះមុខច្បាប់ឡើយ។ និទណ្ឌភាព គឺគ្មានការចាប់ស្លួន និងនាំខ្លួនជនប្រព្រឹត្តបទល្មើសមកធ្វើការវិនិច្ឆ័យទោស ពីព្រោះតែមុខតំណែង ឥទ្ធិពល ឬ ទ្រព្យធនរបស់ពួកគេ។ ដើម្បីចៀសវាងនូវបញ្ហាទាំងនេះ នគរបាលជាតិត្រូវមានភក្តីភាពចំពោះជាតិ សាសនា ព្រះមហាក្សត្រ។ នគរបាលយុត្តិធម៌ត្រូវធ្វើការស៊ើបអង្កេតភ្លាមៗ នៅខណៈពេលដែលខ្លួលបានដឹងពិការប្រព្រឹត្តិបទល្មើស មិនត្រូវរង់ចាំឱ្យនរណាម្នាក់ធ្វើពាក្យបណ្ដឹងជាមុននោះទេ មុនពេលដែលខ្លួនចាប់ផ្ដើមស៊ើបអង្កេត។

ជាគោលការណ៍បើមានបទល្មើសព្រហ្មទណ្ឌ កើតឡើងទោះបីជាគ្មានបណ្ដឹងក៏ដោយក៏មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបើកកាស៊ើបអង្កេត ស្រាវជ្រាវ ស្វែងរកជនប្រព្រឹត្តបទល្មើស ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ។បើមិនដូច្នេះទេ បញ្ហានិទណ្ឌភាព និងសកម្មភាពល្មើសច្បាប់កាន់តែមានច្រើនឡើងៗ ធ្វើឱ្យសង្គមច្របូកច្របល់ គ្មានសណ្ដាប់ធ្នាប់ គ្មានសន្តិភាព ក្លាយទៅជាសង្គមមួយអនាធិបតេយ្យ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌គឺពិតជាដំណាក់កាលមួយក៏សំខាន់ ព្រោះនគរបាលយុត្តិធម៌ គឺជាជំនួយការរបស់អំណាចតុលាការ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើសព្រមទាំងប្រមូលភស្តុតាង ។ ព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែនៅក្នុងការអនុវត្តដីកាចាត់ចែងឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ។ ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌដាក់នគរបាលយុត្តិធម៌ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នកអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ ។

បេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានគោលដៅរកមុខរកជនដែលបានប្រព្រឹត្តបទល្មើស និងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងសង្គមជាតិ។ មន្ត្រីនគរបាលមិនត្រូវរំលងនូវនីតិវីធីសាកសួរជនសង្ស័យ និងសាក្សីឡើយ ព្រោះវាក៏ជាសញ្ញាមួយដែលអាចឲ្យមន្ត្រីនគរបាលធ្វើការកំណត់អត្តសញ្ញាណជនដែលប្រព្រឹត្តបទល្មើស។ ក្រោយពីស្វែងរកភស្តុតាងដែលបានបន្សល់ ទុកនៅកន្លែងកើតហេតុ ការសម្ភាសន៍ជនសង្ស័យ និងសាក្សីហើយនោះ ប្រសិនបើមានភាពស៊ីសង្វាក់គ្នា ពេលនោះមន្ត្រីនគរបាលអាចចាត់វិធានការតាមស្វែងរកចាប់ខ្លួន ជនដែលបានប្រព្រឹត្តបទល្មើស ដោយមានសេចក្តីសម្រេចពីព្រះរាជអាជ្ញា ឬដោយមានដីកាចាប់ខ្លួនផងដែរ។

នៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌណាមួយវា គឺជាសកម្មភាពដ៏សកម្ម ឬក៏ជាបេសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងដំណើរការស៊ើបអង្កេតបទល្មើសនីមួយៗ មន្ត្រីអាចធ្វើការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់ ដោយគ្រាន់តែមានតម្រុយមួយចំនួន ឬទទួលពាក្យបណ្តឹងពីជនរងគ្រោះផ្ទាល់ ព្រមទាំងតតិយជន ឬអាចជាជនអនាមិកដែលបានរាយការណ៍ជូនមកមន្ត្រីនគរបាលយុត្តិធម៌ផ្ទាល់។ បេសកម្មទាំងនេះមានពីរប្រភេទគឺការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងការស៊ើបអង្កេតបឋម។ ការស៊ើបអង្កេតនីមួយៗមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែត្រួតពិនិត្យឲ្យបានច្បាស់លាស់នូវនីតិវិធីដែលមានចែងនៅក្នុងច្បាប់ ប្រសិន បើការស៊ើបអង្កេតណាមួយមិនស្របទៅនឹងនីតិវិធីដែលមានចែងនៅក្នុងច្បាប់ទេ ពេលនោះការស៊ើបអង្កេតនឹងត្រូវចាត់ទុកជាមោឃៈ។

# អនុសាសន៍

# អនុសាសន៍

យោងតាមការស្រាវជ្រាវរបស់យើងខ្ញុំ ដើម្បីចូលរួមចំណែកសារណារបស់យើងខ្ញុំមួយនេះ អាចយកទៅអនុវត្តបាននៅក្នុងប្រទេសជាតិ ដូច្នេះយើងខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោមៈ

- សូមសំណូមពរទៅដល់ប្រជាពលរដ្ឋគ្រប់រូប សូមមេត្តាជួយសហការណ៍គ្នា ជាមួយមន្ត្រីនគរបាលយុត្តិធម៌ពេលមានបទល្មើសកើតឡើង។ ក្នុងការសហការណ៍ជាមួយមន្ត្រីនគរបាលយុត្តិធម៌មានដូចជាត្រូវតែរាយការណ៍ទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាល ដែលមានទីតាំងនៅជិតកន្លែងកើតហេតុបំផុត។
- ប្រជាពលរដ្ឋគ្រប់រូបអាចដាក់ពាក្យបណ្តឹងដោយចំហរ ឬពាក្យបណ្តឹងអនាមិកក៏បានដែរ ដោយមិនគិតថាប្រជាពលរដ្ឋរូបនោះជាជនរងគ្រោះផ្ទាល់ ឬតតិយជនក្តី គឺមានសិទ្ធិដាក់ពាក្យបណ្តឹងបាន។
- សូមសំណូមពរដល់មន្ត្រីនគរបាលយុត្តិធម៌ យកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋ ជាពិសេស លើកស្ទួយដល់វិស័យយុត្តិធម៌ និងការអនុវត្តន៍ច្បាប់។
- សូមសំណូមពរដល់មន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ឲ្យលុបបំបាត់ចោល នូវអំពីពុករលួយ ជាពិសេសអ្នកធ្វើកំណត់ហេតុ និងអ្នកធ្វើកោសលវិច្ឆ័យ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅដោយយុត្តិធម៌ យ៉ាងល្អបំផុត ជាងនេះទៅទៀត បានធ្វើឲ្យប្រទេសជាតិមានភាពតម្លាភាព និងនីតិរដ្ឋ។
- សូមឲ្យមានការរីកចំរើននៃវិស័យច្បាប់ ទាក់ទងនិងផ្នែកព្រហ្មទណ្ឌ នៅក្នុងដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ព្រោះដំណាក់កាលនេះគឺពឹងផ្អែកទាំងស្រុងទៅលើសមត្ថភាព និងបច្ចេកទេស ឬជំនាញមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្ការ និងបង្ក្រាបបទល្មើសដែលកើតមានឡើង។
- សូមឲ្យមន្ត្រីនគរបាលយុត្តិធម៌ រក្សាសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងការពារប្រទេសជាតិ កុំឲ្យមានភាពវឹកវរ ដើម្បីជៀសវាងកុំឲ្យមានភាពអសកម្មនៅក្នុងសង្គមជាតិ។
- មន្ត្រីនគរបាលយុត្តិធម៌ទាំងឡាយ សូមគោរពតាមតួនាទី និងតាមច្បាប់ឲ្យបាននូវក្រមសីលធម៌ជាមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងគោរពតាមគោលណ៍របស់ច្បាប់ដែលបានចែងនៅក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើមិនគោរពតាមច្បាប់នោះទេ និងធ្វើឲ្យមានការរំលោភបំពាននូវ សិទ្ធិមនុស្ស សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋគ្រប់រូប ដែលធ្វើឲ្យប្រទេសជាតិបាត់បង់នូវនីតិរដ្ឋ និងសន្តិភាពទាំងស្រុង។

# ឯកសារយោង

## ឯកសារយោង


- ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ស្តីពី «ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ស្រុក ខណ្ឌ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៨»
- ច្បាប់ស្តីពី «ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ ២០០៥»
- ច្បាប់ស្តីពី» ព្រៃឈើ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២»
- វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត
- សទ្ទានុក្រម រដ្ឋប្បវេណីឆ្នាំ២០០៧
- សៀវភៅរបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៧
- វីដេអូស្តីពី “ វគ្គបណ្តុះបណ្តាលមន្រ្តីនគរបាលយុត្តិធម៌” ក្រោមការធ្វើបទបង្ហាញរបស់ ឯកឧត្តម កើត រិទ្ធី អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ ចុះផ្សព្វផ្សាយថ្ងៃទី ២០-២៤ មិថុនា ឆ្នាំ ២០១៦
- សៀវភៅ “ នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាលយុត្តិធម៌” (អំណោយស្ថានទូតបារាំង ឆ្នាំ ២០០៩)
- សៀវភៅ មគ្គុទេសសម្រាប់មន្រ្តីអនុវត្តច្បាប់ ស្តីពី បច្ចេកទេសមន្រ្តីនគរបាលយុត្តិធម៌ របស់អង្គការ អន្តរជាតិអន្តោប្រវេសន៍ ហៅកាត់ថា អាយ.អូ. អឹម (I OM )បេសកម្មនៅកម្ពុជា ឆ្នាំ ២០១២
- សៀវភៅអត្ថាធិប្បាយច្បាប់ “ ភស្តុតាងក្នុងរឿងក្តីព្រហ្មទំណ្ឌ” រៀបរៀងដោយ លោកចៅក្រម ហ៊ីង ធីឫទ្ធី (ភាគ ២) បោះពុម្ពលើកទី ១ ឆ្នាំ ២០០៨
- សៀវភៅ “ នគរបាលយុត្តិធម៌” រៀបរៀងដោយ សាស្រ្តចារ្យ កៅ សីហា បោះពុម្ពផ្សាយឆ្នាំ ២០០៩ (រោងពុម្ព អង្គរ)
- សៀវភៅស្តីពី «នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល ឆ្នាំ២០០៩
- ប្រកាសស្តីពីរបៀបប្រកាសធ្វើការងាររបស់មន្រ្តីនគរបាលយុត្តិធម៌ របស់ក្រសួងយុត្តិធម៌ លេខ ២៧ ប្រ.ក.រ.ប.ក ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០០៤

# ឧបសម្ព័ន្ធទី១

# ក្រមសីលធម៌សំរាប់
# មន្ត្រីប្រតិបត្តិច្បាប់

## Code of Conduct
## for Law Enforcement Officials



# ក្រមសីលធម៌សំរាប់មន្ត្រីប្រតិបត្តិច្បាប់
# Code of Conduct for Law Enforcement Officials

*អនុម័តដោយសេចក្តីសំរេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ ៣៤/១៦៩ ចុះថ្ងៃ ទី១៧ ខែធ្នូ ឆ្នាំ១៩៧៩ ។*
*Adopted by General Assembly resolution 34/169 of 17 December 1979.*

**មាត្រា ១**

ក្នុងការបំរើសហគមន៍ និងក្នុងការការពារមនុស្សគ្រប់រូបកុំឱ្យប្រព្រឹត្តខុសច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់គ្រប់ពេលវេលា ដោយមានការទទួលខុសត្រូវខ្ពស់តាមវិជ្ជាជីវៈរបស់ខ្លួន ។

***អត្ថាធិប្បាយ :***

ក- ពាក្យថា " មន្ត្រីប្រតិបត្តិច្បាប់ " សំដៅដល់មន្ត្រីទាំងអស់ ទោះជាត្រូវតែងតាំង ឬត្រូវជ្រើសតាំងក្តី ឱ្យតែប្រើប្រាស់អំណាចនគរបាល ជាពិសេសអំណាចក្នុងការចាប់ខ្លួន ឬឃុំខ្លួន ។

ខ- នៅក្នុងប្រទេសទាំងឡាយ ដែលអាជ្ញាធរយោធាប្រើប្រាស់អំណាចនគរបាល ទោះជាមាន ឬគ្មានឯកសណ្ឋានក្តី ឬដោយកំលាំងសន្តិសុខរបស់រដ្ឋ មន្ត្រីទាំងឡាយដែលបំរើការងារនោះត្រូវចាត់ចូលក្នុងនិយមន័យនៃមន្ត្រីប្រតិបត្តិច្បាប់ ។

គ- ការផ្តល់សេវាបំរើសហគមន៍ គឺមានគោលដៅដាក់បញ្ចូលជាពិសេសនូវសេវាជំនួយឧបត្ថម្ភដល់សមាជិកសហគមន៍ទាំងនោះ ហើយដោយសារតែមូលហេតុផ្ទាល់ខ្លួន មូលហេតុសេដ្ឋកិច្ច មូលហេតុសង្គមកិច្ច ឬភាពបន្ទាន់បង្ខំផ្សេងទៀត ទើបពួកគេត្រូវការជំនួយទាំងនេះជាបន្ទាន់ ។

ឃ- បញ្ញត្តិនេះមានគោលដៅធ្វើការទប់ស្កាត់ មិនត្រឹមតែអំពើហឹង្សា អំពើសាហាវព្រៃផ្សៃ និងការធ្វើទុក្ខទោសដល់អ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងធ្វើការទប់ស្កាត់ចំពោះអពើល្មើសផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ។ បញ្ញត្តិនេះក៏ អនុវត្តចំពោះជនទាំងឡាយដែលមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទ័ណ្ឌផងដែរ ។

**មាត្រា ២**

ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ រក្សា និងលើកស្ទួយសិទ្ធិមនុស្សរបស់ជនគ្រប់រូប ។

***អត្ថាធិប្បាយ :***

ក- សិទ្ធិមនុស្សដូចមានចែងខាងលើ ត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។ ក្នុងនោះមានលិខិតុបករណ៍ពាក់ព័ន្ធមួយចំនួន ដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីប្រកាសស្តីពីការពារជនគ្រប់រូប កុំឱ្យមានការធ្វើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍ អនុសញ្ញាអន្តរជាតិស្តីពីការបង្ក្រាប និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃពួកអាប៉ាថេដ អនុសញ្ញាអន្តរជាតិស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ បញ្ញត្តិជាបទដ្ឋានអប្បបរមា សំរាប់គ្រប់គ្រងអ្នកទោស ហើយនិងមាន អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ។

ខ- សេចក្តីអត្ថាធិប្បាយថ្នាក់ជាតិលើបញ្ញត្តិនេះ គួរបញ្ជាក់ថាជាបទបញ្ញត្តិថ្នាក់ជាតិ ឬថ្នាក់តំបន់ដែលបានទទួលស្គាល់ និងការពារសិទ្ធិទាំងនេះ ។

## មាត្រា ៣

មន្ត្រីប្រតិបត្តិច្បាប់អាចប្រើប្រាស់កំលាំងបាន តែក្នុងកាលៈទេសៈណាដែលចាំបាច់បំផុត និងស្ថិតនៅក្នុងវង្វង់នៃការបំពេញភារកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

***អត្ថាធិប្បាយ :***

ក- បញ្ញត្តិនេះបញ្ជាក់ថា ការប្រើប្រាស់កំលាំងដោយមន្ត្រីប្រតិបត្តិច្បាប់អាចមានការលើកលែង មានន័យថា មន្ត្រីប្រតិបត្តិច្បាប់ត្រូវបានអនុញ្ញាតិឱ្យប្រើប្រាស់កំលាំងតាមការចាំបាច់ និងសមហេតុផល ដើម្បីទប់ស្កាត់បទល្មើស ឬដើម្បីធ្វើឱ្យមានប្រសិទ្ធិភាព ឬដើម្បីជួយក្នុងការចាប់ខ្លួនជនល្មើស ឬជនសង្ស័យតាមច្បាប់ ប៉ុន្តែមិនត្រូវប្រើកំលាំងហួសហេតុឡើយ ។

ខ- តាមធម្មតា ច្បាប់ជាតិនៃប្រទេសនីមួយៗ បានដាក់កំហិតយ៉ាងតឹងតែងដល់មន្ត្រីប្រតិបត្តិច្បាប់ក្នុងការប្រើប្រាស់កំលាំងនេះ ដោយអនុលោមតាមគោលការណ៍សមាមាត្រ ។ គេក៏ត្រូវយល់ដែរថា គេត្រូវគោរពតាមគោលការណ៍ជាតិស្តីពីសមាមាត្រក្នុងការបកស្រាយបញ្ញត្តិនេះ ។ ទោះជាក្នុងករណីណាក៏ដោយ មិនត្រូវធ្វើការបកស្រាយ

បញ្ញត្តិនេះ ដើម្បីអនុញ្ញាតឱ្យប្រើប្រាស់កំលាំង ដែលមិនសមាមាត្រ ដើម្បីសំរេចបាននូវគោលដៅស្របច្បាប់ណាមួយឡើយ ។

គ- ការប្រើប្រាស់អាវុធត្រូវបានគេចាត់ទុកថា ជាវិធានការមួយដែលខ្លាំងក្លាបំផុត ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវខំជៀសវាងការប្រើប្រាស់អាវុធ ជាពិសេសទៅលើអនីតិជន ។ ជាទូទៅ ការប្រើអាវុធត្រូវហាមឃាត់ លើកលែងតែក្នុងករណីណាដែលជនល្មើសតដៃ ឬបង្កគ្រោះថ្នាក់ដល់ជីវិតអ្នកដទៃ ឬក្នុងកាលៈទេសៈណាដែលការចាត់វិធានការមិនមានកំលាំងគ្រប់គ្រាន់ ដើម្បីបញ្ឈប់ ឬចាប់ខ្លួនជនល្មើស ។ ពេលណាដែលមានការបាញ់កាំភ្លើងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចភ្លាម ។

## មាត្រា ៤

ចំពោះរឿងរ៉ាវទាំងឡាយមានចរិតជាការសំងាត់ ហើយដែលឋិតនៅក្នុងដៃមន្ត្រីប្រតិបត្តិច្បាប់ត្រូវតែរក្សាទុកជាសំងាត់ លើកលែងតែត្រូវបំពេញភារកិច្ច ឬត្រូវស្វែងរកយុត្តិធម៌ ។

***អត្ថាធិប្បាយ :***

តាមប្រភេទការងាររបស់ខ្លួន មន្ត្រីប្រតិបត្តិច្បាប់ ទទួលពត៌មាននានា ដែលអាចមានការទាក់ទងដល់ជីវិតរស់នៅផ្ទាល់ខ្លួន ឬដែលអាចបណ្តាលឱ្យខូចខាតដល់ប្រយោជន៍ជាសក្តានុពល ឬជាពិសេសប៉ះពាល់ដល់កិត្តិយសអ្នកដទៃ ។ មន្ត្រីប្រតិបត្តិច្បាប់ត្រូវប្រុងប្រយ័ត្នបំផុតក្នុងការរក្សា និងការប្រើប្រាស់ពត៌មាននេះ ហើយព័ត៌មាននេះអាចលាតត្រដាងបានសំរាប់តែការបំពេញភារកិច្ច ស្វែងរកយុត្តិធម៌តែប៉ុណ្ណោះ ។ ការយករឿងអាថ៌កំបាំងរបស់អ្នកដទៃ ទៅលាតត្រដាងក្នុងគោលបំណងអ្វីផ្សេងពីនេះ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះនេះជាការមិនសមរម្យទាល់តែសោះ ។

## មាត្រា ៥

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនអាចប្រព្រឹត្ត ធ្វើការញុះញង់ ឬបណ្តោយឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតឡើយ ។ ក្រៅពីនេះ មន្ត្រីប្រតិបត្តិច្បាប់មិនត្រូវដាក់បញ្ជាបែបជាចៅហ្វាយនាយផ្សេងៗ ឬមានការលើកលែងចំពោះករណីមួយចំនួនដូចជា ក្នុងស្ថានភាពដែលមានសង្គ្រាម ឬការគំរាម

ធ្វើសង្គ្រាម ការគំរាមដល់សន្តិសុខជាតិ អស្ថេរភាពនយោបាយផ្ទៃក្នុង ឬភាពចលាចលទូទៅណាមួយ ដែលជាមូលហេតុនៃការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬទណ្ឌកម្មឯទៀតនោះឡើយ ។

***អត្ថាធិប្បាយ :***

ក- ការហាមប្រាមនេះ មានចែងនៅក្នុងបញ្ញត្តិនៃសេចក្តីប្រកាសជាសកលស្តីអំពីកិច្ចការពារបុគ្គលគ្រប់រូប ដើម្បីកុំឱ្យមានការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយខ្លឹមសារនៃ [អំពើនេះ] គឺជាអំពើល្មើសមួយដែល ប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើល្មើសនេះនឹងត្រូវផ្តន្ទាទោសដោយសារមិនព្រមអនុវត្តតាមស្មារតីធម្មនុញ្ញសហប្រជាជាតិ ហើយវាជាការរំលោភលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលមានចែងនៅក្នុងសេចក្តីប្រកាសជា សាកលស្តីពីសិទ្ធិមនុស្ស [និងលិខិតុបករណ៍អន្តរជាតិដទៃទៀតដែលទាក់ទងនិងសិទ្ធិមនុស្ស] ។

ខ- សេចក្តីប្រកាសនេះបានឱ្យនិយមន័យនៃពាក្យទារុណកម្ម ដូចខាងក្រោមនេះ :

"...ពាក្យទារុណកម្ម សំដៅដល់អំពើទាំងឡាយណាដែលនាំឱ្យមានការឈឺចាប់ ខាងផ្លូវកាយ ឬផ្លូវចិត្ត ដែលមន្ត្រីសាធារណៈណាម្នាក់បង្កឡើងដោយចេតនា ឬដោយការញុះញង់របស់មន្ត្រីនោះ ឱ្យប្រព្រឹត្តលើជនណាម្នាក់ ក្នុងគោលបំណងឱ្យជននោះ ឬតតិយជនណាម្នាក់ ឱ្យផ្តល់ព័ត៌មាន ឬចំលើយសារភាព ការដាក់ទណ្ឌកម្មចំពោះអំពើ ដែលជននោះបានប្រព្រឹត្ត ឬសង្ស័យថាបានប្រព្រឹត្ត ឬធ្វើការបំភិតបំភ័យជននោះ ឬជនដទៃផ្សេងទៀត ។ នេះមិនបានគិតពីការឈឺចាប់ ដែលកើតមានដោយសារការដាក់ទណ្ឌកម្មស្របច្បាប់ ក្នុងករិតមួយដែលស្របតាមបញ្ញត្តិ ដែលមានចែងក្នុង បទដ្ឋានអប្បបរមាសំរាប់គ្រប់គ្រងអ្នកទោស " ឡើយ ។

គ- ចំពោះពាក្យថា " ការប្រព្រឹត្ត ឬការធ្វើទណ្ឌកម្មឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប " មហាសន្និបាតមិនទាន់បានឱ្យអត្ថន័យពិស្តារនៅឡើយទេ ប៉ុន្តែពាក្យនេះគួរតែធ្វើការបកស្រាយយ៉ាងណា ដើម្បីពង្រីកការការពារឱ្យបានយ៉ាងទូលំទូលាយបំផុតតាមដែលអាចធ្វើបាន ប្រឆាំងរាល់ការរំលោភបំពានគ្រប់បែបយ៉ាង ខាងផ្លូវកាយ ឬ ផ្លូវចិត្ត ។

## មាត្រា ៦

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបត្រូវធានារក្សាសុខភាពជនទាំងឡាយដែលឋិតក្នុងការឃុំឃាំងរបស់ខ្លួនឱ្យបានពេញលេញបរិបូរណ៍ ជាពិសេស ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីធានាឱ្យមានការព្យាបាលជម្ងឺ តាមការចាំបាច់ ។

***អត្ថាធិប្បាយ :***

ក- "ការព្យាបាលជម្ងឺ" សំដៅដល់ការផ្តល់សេវាផ្សេងៗដោយបុគ្គលិកផ្នែកសុខាភិបាល ក្នុងនោះមានគ្រូពេទ្យជំនាញវិជ្ជាជីវៈ និងគ្រូពេទ្យជំនួយ ដែលគ្រូពេទ្យទាំងនេះត្រូវធានាឱ្យមានជានិច្ចសំរាប់បំរើសេចក្តីត្រូវការ ។

ខ- ប្រសិនបើបុគ្គលិកផ្នែកសុខាភិបាលចាំបាច់ត្រូវចូលរួមក្នុងកិច្ចប្រតិបត្តិការជាមួយមន្ត្រីប្រតិបត្តិច្បាប់ ហើយមន្ត្រីប្រតិបត្តិច្បាប់ត្រូវពិចារណាលើការវិនិច្ឆ័យរបស់បុគ្គលផ្នែកសុខាភិបាលទាំងនេះ នៅពេលដែលគេព្យាបាលជនដែលនៅក្នុងការឃុំគ្រងរបស់ខ្លួន តាមរយៈ ឬក្នុងការពិគ្រោះយោបល់ជាមួយបុគ្គលិកផ្នែកសុខាភិបាលដែលមិនឋិតក្នុងកិច្ចប្រតិបត្តិការរបស់មន្ត្រីប្រតិបត្តិច្បាប់ ។

គ- មន្ត្រីប្រតិបត្តិច្បាប់ក៏ត្រូវធានាឱ្យមានការព្យាបាលសុខភាពដល់ជនរងគ្រោះ ដោយការរំលោភច្បាប់ ឬដោយឧបទ្ទវហេតុផ្សេងៗ ដែលកើតឡើងក្នុងពេលមានការប្រព្រឹត្តរំលោភច្បាប់ផងដែរ ។

## មាត្រា ៧

មន្ត្រីប្រតិបត្តិច្បាប់គ្រប់រូបមិនត្រូវប្រព្រឹត្តអំពើពុករលួយជាដាច់ខាត ហើយត្រូវប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះឱ្យបានយ៉ាងខ្លាំងក្លា ។

***អត្ថាធិប្បាយ :***

ក- អំពើពុករលួយ ក៏ដូចគ្នានឹងការបំពានច្បាប់របស់រដ្ឋពីសំណាក់អាជ្ញាធរដែរ ហើយអំពើបែបនេះជាអំពើដែលផ្ទុយពីកាតព្វកិច្ចរបស់មន្ត្រីប្រតិបត្តិច្បាប់ ។ មន្ត្រីប្រតិបត្តិច្បាប់ដែលប្រព្រឹត្តអំពើពុករលួយត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ដោយគ្មានការយោគយល់ឡើយ ព្រោះថារដ្ឋាភិបាលពុំអាចយកច្បាប់ មកគ្រប់គ្រងលើប្រជាពលរដ្ឋបានទេ ប្រសិនបើ រដ្ឋាភិបាលមិនអាចអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវទៅលើភ្នាក់ងារ ឬស្ថាប័នរបស់ខ្លួន ។

ខ- និយមន័យនៃពាក្យ "អំពើពុករលួយ" ត្រូវតែមានចែងក្នុងច្បាប់ជាតិ ។ ការរួមគំនិតប្រព្រឹត្តអំពើសូកប៉ាន់ផ្សេងៗ គឺជាបទល្មើសពុករលួយ។ នៅពេលកំពុងបំពេញភារកិច្ចក្នុងនាម ជាមន្ត្រីប្រតិបត្តិច្បាប់ បើមានការ

ព្រមើយកន្តើយមិនបង្ក្រាបអំពើស្មូកប៉ាន់ឱ្យបានច្បាស់លាស់ទេ មន្ត្រីប្រតិបត្តិច្បាប់ ត្រូវចាត់ទុកថា បានឃុបឃិតក្នុងអំពើពុករលួយដែរ ។ ការទទួលអំណោយ (ជាវត្ថុ ឬជាប្រាក់) រង្វាន់លើកទឹកចិត្តផ្សេងៗ ការសន្យានានា ដែលមិនសមស្របទៅនឹងវិន័យត្រូវចាត់ទុកថាជាបទល្មើសពុករលួយ ។

គ- ពាក្យថា "អំពើពុករលួយ" ដែលបានចែងក្នុងប្រយោគខាងលើ ត្រូវរាប់បញ្ចូលផងដែរនូវឆន្ទៈ ឬការប៉ុនប៉ងទទួលសំណូកគ្រប់ប្រភេទ ។

## មាត្រា ៨

មន្ត្រីប្រតិបត្តិច្បាប់គ្រប់ស្រទាប់ជាន់ថ្នាក់ ត្រូវគោរពតាមច្បាប់ និងបទវិន័យនេះ ហើយត្រូវទប់ស្កាត់ និងប្រឆាំងយ៉ាងខ្លាំងក្លាបំផុតចំពោះអំពើទាំងឡាយណា ដែលបំពាន ឬប៉ះពាល់ដល់ច្បាប់ និងបទវិន័យនេះ ។

មន្ត្រីប្រតិបត្តិច្បាប់ ដែលដឹងប្រាកដថា មានជនណាម្នាក់បានរំលោភ ឬប្រុងនឹងរំលោភលើបទវិន័យនេះ ត្រូវតែរាយការណ៍អំពីរឿងនេះទៅអាជ្ញាធរថ្នាក់លើ ហើយប្រសិនជាចាំបាច់ត្រូវរាយការណ៍ទៅស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត ដែលមានអំណាចពិនិត្យ ឬដោះស្រាយ ។

***អត្ថាធិប្បាយ :***

ក- គេត្រូវតែគោរពតាមបទវិន័យនេះភ្លាម កាលណាបទវិន័យនេះបានត្រូវគេបញ្ចូលទៅក្នុងក្របខ័ណ្ឌច្បាប់នីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។ ប៉ុន្តែនៅប្រទេសខ្លះច្បាប់នីតិបញ្ញត្តិ ឬនីតិប្រតិបត្តិរបស់គេ មានលក្ខណៈតឹងរឹងជាងបទវិន័យបច្ចុប្បន្ននេះទៅទៀត ។ ក្នុងករណីបែបនេះ មន្ត្រីប្រតិបត្តិច្បាប់ត្រូវតែគោរពតាមច្បាប់ដែលតឹងរឹងនោះ ។

ខ- មាត្រានេះ សំដៅធ្វើការថ្លឹងថ្លែងរវាងសេចក្តីត្រូវការឱ្យមានការគោលសំខាន់ពីរ គោលសំខាន់ទី១ គឺការរក្សា និងការពង្រឹងវិន័យផ្ទៃក្នុងរបស់ស្ថាប័ន ដើម្បីជាប្រយោជន៍ដ៏ទូលំទូលាយដល់សន្តិសុខសាធារណៈ ។ គោលសំខាន់ទី២ គឺការបង្ការ និងការការពារកុំឱ្យមានអំពើរំលោភលើសិទ្ធិមនុស្សជាមូលដ្ឋាន ។ បើមានការរំលោភច្បាប់ មន្ត្រីប្រតិបត្តិច្បាប់ត្រូវធ្វើសេចក្តីរាយការណ៍ជូនទៅនាយចៅហ្វាយតាមលំដាប់ឋានានុក្រម ។ ដរាបណាស្ថាប័នរបស់ខ្លួនបានប្រើគ្រប់មធ្យោបាយហើយនៅតែគ្មានប្រសិទ្ធិភាព ដរាបនោះមន្ត្រីប្រតិបត្តិច្បាប់ អាចរាយការណ៍អំពីរឿងរំលោភច្បាប់នេះ ទៅស្ថាប័នមានសមត្ថកិច្ចដទៃទៀត ។ ក្នុងការធ្វើសេចក្តីរាយការណ៍អំពីការរំលោភលើបទវិន័យ ឬអំពីគំរោងផែនការ នៃការប្រព្រឹត្តអំពើពុករលួយណាមួយ អ្នករាយការណ៍ (មន្ត្រីប្រតិបត្តិច្បាប់) មិនត្រូវបាន ទទួលទណ្ឌកម្ម ឬដាក់វិន័យរដ្ឋបាលណាមួយពីស្ថាប័នរបស់ខ្លួនឡើយ ។

គ- ពាក្យថា "អាជ្ញាធរមានសមត្ថកិច្ច ឬអង្គការរដ្ឋដែលមានអំណាចពិនិត្យ និងដោះស្រាយ" សំដៅដល់អាជ្ញាធរ ឬអង្គការរដ្ឋដែលស្ថិតនៅក្នុងរង្វង់នៃច្បាប់ជាតិ ទោះជាអាជ្ញាធរ ឬអង្គការរដ្ឋនោះនៅក្នុង ឬឯករាជ្យពីស្ថាប័នប្រតិបត្តិច្បាប់នោះក៏ដោយ ដែលមានអំណាចតាមលក្ខខណ្ឌអំណាចតាមទម្លាប់ ឬអំណាចផ្សេងៗទៀត ក្នុងការពិនិត្យលើបណ្តឹងសារទុក្ខ ឬបណ្តឹងផ្សេងទៀតអំពីការរំលោភបំពានច្បាប់នៅក្នុងរង្វង់ព្រំដែននៃបទវិន័យនេះ ។

ឃ- នៅប្រទេសខ្លះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគ្រប់បែបយ៉ាង ត្រូវបានគេចាត់ទុកថាបានបំពេញភារកិច្ចក្នុងការពិនិត្យសើរើពាក្យបណ្តឹងនានា ប្រហាក់ប្រហែលគ្នាទៅនឹងភារកិច្ចដែលបានរៀបរាប់នៅក្នុងវគ្គ (គ) ខាងលើ ។

ង- ដើម្បីទាក់ទាញមតិសាធារណជន ឱ្យចេះឈឺឆ្អាលក្នុងរឿងរំលោភច្បាប់នេះ ភ្នាក់ងារក្រសួងការពារច្បាប់អាចផ្សព្វផ្សាយតាមរយៈវិទ្យុ, ទូរទស្សន៍, ភាពយន្ត, ល្ខោន, ទស្សនាវដ្តី ឬកាសែតក៏បាន ឱ្យតែគេអាចបញ្ជាក់ហេតុផលថា គេបានអនុលោមទៅតាមច្បាប់ទម្លាប់របស់ប្រទេសគេ និងគោរពតាមបញ្ញត្តិនៃមាត្រាទី៨ ក្នុងបទវិន័យនេះ ។ ប៉ុន្តែការប្រើតាមមធ្យោបាយខាងលើនេះ អាចប្រើបានតែក្នុង ដំណាក់ការចុងក្រោយបំផុតប៉ុណ្ណោះ ប្រសិនបើគ្រប់មធ្យោបាយឯទៀតដែលគេបានប្រើរួចមកហើយនោះ ពុំបានសំរេចដូចបំណង ។

ច- ភ្នាក់ងារក្រសួងការពារច្បាប់ទាំងឡាយណា ដែលបានគោរពច្បាប់នៃបទវិន័យនេះ តែងតែបានទទួលនូវការគោរពស្ញើចសរសើរ, ការគាំទ្រ, ព្រមទាំងការរួមសហប្រតិបត្តិការពីសំណាក់សហគមន៍, ពីសំណាក់ស្ថាប័នអនុវត្តន៍ច្បាប់ និងពីសំណាក់អ្នកដែលមានអាជីពក្នុងវិស័យប្រតិបត្តិច្បាប់ ។

~~~~~~~~~
~~~~~~~~~

# ឧបសម្ព័ន្ធទី២

**UNITED NATIONS**
UNITED NATIONS TRANSITIONAL AUTHORITY IN CAMBODIA
(UNTAC)

**NATIONS UNIES**
AUTORITE PROVISOIRE DES NATIONS UNIES AU CAMBODGE
(APRONUC)

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល



*PROVISIONS RELATING TO THE JUDICIARY AND CRIMINAL LAW AND PROCEDURE APPLICABLE IN CAMBODIA DURING THE TRANSITIONAL PERIOD*

*DISPOSITIONS RELATIVES AU SYSTEME JUDICIAIRE AU DROIT PENAL ET ALA PROCEDURE PENALE APPLICABLES AU CAMBODGE PENDANTLA PERIODE TRANSITOIRE*

២១៩៧

**មាត្រា ១៨**

Downloaded from http://www.khmerlaws.com

## មាត្រា ១៨ : បទល្មើសជាក់ស្តែង

នគរបាលអាចចាប់ខ្លួនជនណាដែលបានប្រព្រឹត្តបទល្មើសជាក់ស្តែង គឺថា ៖

- បើជនសង្ស័យត្រូវគេឃើញទាន់ពេលកំពុងតែប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ឬប្រសិនបើកំពុងត្រូវគេស្រែកដេញប្រជាប់ចាប់ប្រភីង
- បើជនសង្ស័យត្រូវបានសាក្សី ឬ អ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬ បទល្មើស ថាជាពិរុទ្ធិកជន
- បើជនសង្ស័យកំពុងរកវិធីរត់ចេញពីកន្លែងដែលប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទល្មើស ។

## មាត្រា ១៩ : ការចាប់ខ្លួនដោយសំអាងលើភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់

១ : ក្នុងករណីផ្សេងទៀតទាំងអស់ នគរបាលតុលាការអាចចាប់ខ្លួនជនជាប់សង្ស័យបាន លុះត្រាតែមានភ័ស្តុតាងជាក់ស្តែងយ៉ាងខ្លាំង, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលបង្ហាញអោយឃើញថា ជននោះបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទបជ្ជីមមែន ។

២ : បើជនជាប់សង្ស័យលួចរត់គេចខ្លួន ជននោះអាចត្រូវចាប់ខ្លួនបាន តាមដីកាចាប់ខ្លួនរបស់រដ្ឋអាជ្ញា ឬ ចៅក្រម ដែលនឹងត្រូវអនុវត្តដោយនគរបាលតុលាការ ។

៣ : ដីកាចាប់ខ្លួនត្រូវមានបញ្ជាក់អំពីអំពើ និងមូលហេតុទាំងឡាយ ដែលនាំអោយមានការចាប់ខ្លួនជនជាប់សង្ស័យនោះ ។

៤ : ជោគវាសនារបស់ជនដែលត្រូវគេចាប់ខ្លួន ត្រូវបានចាត់ចែង តាមលក្ខខ័ណ្ឌកៈនៅក្នុងមាត្រា១៣ នៃបទបញ្ញត្តិនេះ ។

៥ : ម្យ៉ាងទៀត តាមដីកាបង្គាប់អោយឡើងសាលារបស់រដ្ឋអាជ្ញា ឬ ចៅក្រម នគរបាលអាចនាំខ្លួនជនគ្រប់រូប ដែលមានប្រយោជន៍ក្នុងការស៊ើបអង្កេត ហើយដែលប្រកែកមិនព្រមចូលខ្លួនតាមដីកាកោះ មកបង្ហាញខ្លួនចំពោះមុខនាយនគរបាល ឬចៅក្រម ឬរដ្ឋអាជ្ញា។ ក្រោយពីតុលាការបានសាកសួរហើយ ជននោះត្រូវបានដោះលែងជាបន្ទាន់ លើកលែងតែក្នុងករណីមានភ័ស្តុតាងជាក់ស្តែងយ៉ាងធ្ងន់, ច្បាស់លាស់ ហើយស៊ីសង្វាក់គ្នា ដែលត្រូវអនុវត្តតាមនីតិវិធីនៃមាត្រាទី ១៣ នៃបទបញ្ញត្តិនេះ ។

Downloaded from http://www.khmerlaws.com

# ប្រកាសអន្តរក្រសួង

# ស្តីពី

# ការផ្តល់នីតិសម្បទា

# ជា

# មន្ត្រីនគរបាលយុត្តិធម៌

Downloaded from http://www.khmerlaws.com

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខៈ ៥៦៦ ប្រក.កយ.កសក/០៨

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធមិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

Downloaded from http://www.khmerlaws.com

- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានជលផលជលផល ទៅជារដ្ឋបាលជលផល
- បានឃើញប្រកាសលេខ ៣៨៦ ប្រក.កសក.ប ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃអង្គភាពរបស់រដ្ឋបាលជលផល
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១ :**

ត្រូវបានទទួលស្គាល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីរាជការដែលបំរើការងារនៅរដ្ឋបាលជលផល ដូចមានរាយនាមខាងក្រោម :

| ល.រ | គោត្តនាម-នាម | ភេទ | ឋានៈ និងតួនាទី | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១ | ឯកឧត្តម ណៅ ធូក | ប្រុស | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក ជាប្រធានរដ្ឋបាលជលផល | |
| ២ | ឯកឧត្តម ឡុង ឈាង | - | អនុប្រធានរដ្ឋបាលជលផល | |
| ៣ | លោក សម នៅ | - | អនុប្រធានរដ្ឋបាលជលផល | |
| ៤ | លោក អ៊ឹង ទ្រី | - | អនុប្រធានរដ្ឋបាលជលផល | |
| ៥ | លោក អេង ជាសាន | - | អនុប្រធានរដ្ឋបាលជលផល | |
| ៦ | លោក ពុំ សុថា | - | នាយ អធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ៧ | លោក សុង ហុង | - | នាយ អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ | |
| ៨ | លោក ឡុង គន | - | នាយ អធិការដ្ឋានរដ្ឋបាលជលផលមេគង្គ | |
| ៩ | ឯកឧត្តម វ៉ាន់ ផាន់នី | - | នាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប | |
| ១០ | លោក ហុង ហ៊ី | - | នាយអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប | |

Downloaded from http://www.khmerlaws.com

| | | | | |
|---|---|---|---|---|
| ១១ | លោក ផុន សុផាត | - | ប្រធានការិយាល័យរដ្ឋបាល បុគ្គលិក | |
| ១២ | លោក សន ថាន់ | - | ប្រធានការិយាល័យនីតិកម្ម និងវិវាទ | |
| ១៣ | លោក ចាប សៀកហេង | - | នាយ រងអធិការដ្ឋានជលផលចតុមុខ | |
| ១៤ | លោក អ៊ុំ សុគន្ធ | - | នាយ រងអធិការដ្ឋានជលផលសមុទ្រ | |
| ១៥ | លោក ងួន ម៉េង | - | នាយ រងអធិការដ្ឋានជលផលសមុទ្រ | |
| ១៦ | លោក ស៊ិន ផល្គុណ | ប្រុស | នាយ រងអធិការដ្ឋានជលផលសមុទ្រ | |
| ១៧ | លោក ម៉ៅ សុផល | - | នាយ រងអធិការដ្ឋានជលផលចតុមុខ | |
| ១៨ | លោក កៅ មុនីរិទ្ធ | - | នាយ រងអធិការដ្ឋានជលផលសមុទ្រ | |
| ១៩ | លោក ប៊ុន ឆេងហាក់ | - | នាយ រងអធិការដ្ឋានជលផលមេគង្គ | |
| ២០ | លោក ទឹម សារុធ | - | នាយ រងអធិការដ្ឋានជលផលមេគង្គ | |
| ២១ | លោក ស៊ិន សុធី | - | នាយ រងអធិការដ្ឋានជលផលខាងជើងបឹងទន្លេសាប | |
| ២២ | លោក សោម សុវណ្ណ | - | នាយ រងអធិការដ្ឋានជលផលខាងជើងបឹងទន្លេសាប | |
| ២៣ | លោក រស់ វុទ្ធី | - | នាយ រងអធិការដ្ឋានជលផលខាងជើងបឹងទន្លេសាប | |
| ២៤ | លោក មាឃ សៀង | - | នាយ រងអធិការដ្ឋានជលផលខាងត្បូងបឹងទន្លេសាប | |
| ២៥ | លោក ញ៉ែម អុន | - | នាយ រងអធិការដ្ឋានជលផលខាងត្បូងបឹងទន្លេសាប | |
| ២៦ | លោក ជាវ វិជ្ជាក់ | - | នាយ រងអធិការដ្ឋានជលផលខាងត្បូងបឹងទន្លេសាប | |
| ២៧ | លោក សំ សត្យា | | អនុប្រធានការិយាល័យនីតិកម្ម និងវិវាទ | |
| ២៨ | លោក ស៊ូ សាខន | - | អនុប្រធានការិយាល័យនីតិកម្ម និងវិវាទ | |
| ២៩ | លោកស្រី អ៊ុមសោភណ: | ស្រី | អនុប្រធានការិយាល័យនីតិកម្ម និងវិវាទ | |
| ៣០ | លោក សៀន គិន | ប្រុស | នាយខណ្ឌរដ្ឋបាលជលផលក្រចេះ | |
| ៣១ | លោក ប៉ែន ឈុននី | - | នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង | |
| ៣២ | លោក ឆេង វិបុលរិទ្ធ | - | នាយខណ្ឌរដ្ឋបាលជលផលសៀមរាប | |
| ៣៣ | លោក ហេង ពិសិដ្ឋ | - | នាយខណ្ឌរដ្ឋបាលជលផលបាត់ដំបង | |
| ៣៤ | លោក សេង ស៊ុនហ៊ួត | - | នាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ | |
| ៣៥ | លោក គីម សារិទ្ធ | - | នាយខណ្ឌរដ្ឋបាលជលផលតាកែវ | |

Downloaded from http://www.khmerlaws.com

| | | | | |
|---|---|---|---|---|
| ៣៦ | លោក ឃ្យាំង វណ្ណធុល | - | នាយខណ្ឌរដ្ឋបាលជលផលកណ្តាល | |
| ៣៧ | លោក កែវ ថាយ | - | នាយខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង | |
| ៣៨ | លោក ស សុរិន | - | នាយខណ្ឌរដ្ឋបាលជលផលកំពត | |
| ៣៩ | លោក គង់ពុទ្ធារិទ្ធ | - | នាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម | |
| ៤០ | លោក ហៀន វាចារ | - | នាយខណ្ឌរដ្ឋបាលជលផលកំពង់ស្ពឺ | |
| ៤១ | លោក លី វេង | - | នាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ | |
| ៤២ | លោក អួន ស៊ីណាត | - | នាយខណ្ឌរដ្ឋបាលជលផលព្រៃវែង | |
| ៤៣ | លោក ឯក ហេង | - | នាយខណ្ឌរដ្ឋបាលជលផលកំពង់ធំ | |
| ៤៤ | លោក ឡាង គីរី | ប្រុស | នាយខណ្ឌរដ្ឋបាលជលផលកោះកុង | |
| ៤៥ | លោក ប៉ែន ផាន់រិទ្ធ | - | នាយខណ្ឌរដ្ឋបាលជលផលភ្នំពេញ | |
| ៤៦ | លោក ឡុង សំអាត | - | នាយខណ្ឌរដ្ឋបាលជលផលកំពង់សោម | |
| ៤៧ | លោក ម៉ៅ ចាន់សាម៉ន | - | នាយខណ្ឌរដ្ឋបាលជលផលរតនគីរី | |
| ៤៨ | លោក ខៀវ សំបុក | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ស្ពឺ | |
| ៤៩ | លោក ម៉ុក ពន្លក | - | នាយ រងខណ្ឌរដ្ឋបាលជលផលក្រចេះ | |
| ៥០ | លោក ទុំ នីរ៉ូ | - | នាយ រងខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង | |
| ៥១ | លោក ផៀប បូរ៉ាំ | - | នាយ រងខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង | |
| ៥២ | លោក ភុំ វិមល | - | នាយ រងខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ | |
| ៥៣ | លោក ថៃ សីលាលីតា | - | នាយ រងខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ | |
| ៥៤ | លោក ឆាយ មន | - | នាយ រងខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ | |
| ៥៥ | លោក អ៊ុន បុញ្ញវត្ត | - | នាយ រងខណ្ឌរដ្ឋបាលជលផលសៀមរាប | |
| ៥៦ | លោក ព្រិន សារិន | - | នាយ រងខណ្ឌរដ្ឋបាលជលផលសៀមរាប | |
| ៥៧ | លោក ខុង សោភ័ណ | - | នាយ រងខណ្ឌរដ្ឋបាលជលផលសៀមរាប | |
| ៥៨ | លោក លី ប្រុស | - | នាយ រងខណ្ឌរដ្ឋបាលជលផលសៀមរាប | |
| ៥៩ | លោក ហ៊ុង សុផានណារិទ្ធ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ចាម | |
| ៦០ | លោក ភួង ទីណា | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ចាម | |
| ៦១ | លោក យឹម ប៊ុនណារ៉េត | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ចាម | |

Downloaded from http://www.khmerlaws.com

| | | | | |
|---|---|---|---|---|
| ៦២ | លោក សេង សំអឿន | - | នាយ រងខណ្ឌរដ្ឋបាលជលផលព្រៃវែង | |
| ៦៣ | លោក សៅ កុសល | - | នាយ រងខណ្ឌរដ្ឋបាលជលផលតាកែវ | |
| ៦៤ | លោក អ៊ូ សុផាន | - | នាយ រងខណ្ឌរដ្ឋបាលជលផលតាកែវ | |
| ៦៥ | លោក ហេង សេង | - | នាយ រងខណ្ឌរដ្ឋបាលជលផលឧត្តរមានជ័យ | |
| ៦៦ | លោក ងួន សុគន្ធ | - | នាយ រងខណ្ឌរដ្ឋបាលជលផលរតនគិរី | |
| ៦៧ | លោក នី សំអាត | - | នាយ រងខណ្ឌរដ្ឋបាលជលផលរតនគិរី | |
| ៦៨ | លោក ឡុញ វុទ្ធី | - | នាយ រងខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ | |
| ៦៩ | លោក សៀវ សៅភាគ្យ | - | នាយ រងខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ | |
| ៧០ | លោក សោម ពិសិដ្ឋ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកោះកុង | |
| ៧១ | លោក ប៉ែន វណ្ណរិទ្ធ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកោះកុង | |
| ៧២ | លោក អៀង គីមអេង | ប្រុស | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ធំ | |
| ៧៣ | លោក នេត ឈុនអ៊ាម | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ធំ | |
| ៧៤ | លោក ហួត លុច | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ធំ | |
| ៧៥ | លោក ស៊ិន សត្ថារតន៍ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់សោម | |
| ៧៦ | លោក ហុក ឡាំ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់សោម | |
| ៧៧ | លោក ប្រាក់ សារវ័ត្រ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់សោម | |
| ៧៨ | លោក នេន ចំរើន | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់សោម | |
| ៧៩ | លោក ប្រាក់ លាងហួរ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង | |
| ៨០ | លោក សោម ភិរុណ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង | |
| ៨១ | លោក សេង ប៊ុនឈឿន | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង | |
| ៨២ | លោក លី ឡា | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង | |
| ៨៣ | លោក ធិន នី | - | នាយ រងខណ្ឌរដ្ឋបាលជលផលភ្នំពេញ | |
| ៨៤ | លោក គី ស៊ិនយូ | - | នាយ រងខណ្ឌរដ្ឋបាលជលផលភ្នំពេញ | |
| ៨៥ | លោក ថៃ សាម៉ន | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពត | |
| ៨៦ | លោក លី សីហា | - | នាយ រងខណ្ឌរដ្ឋបាលជលផលកំពត | |
| ៨៧ | លោក ប៊ុម សីហា | - | នាយ រងខណ្ឌរដ្ឋបាលជលផលកណ្តាល | |

Downloaded from http://www.khmerlaws.com

| | | | | |
|---|---|---|---|---|
| ៨៨ | លោក មាស ចំរើន | - | នាយ រងខណ្ឌរដ្ឋបាលជលផលកណ្តាល | |
| ៨៩ | លោក ធិល ផល្លា | - | នាយ រងខណ្ឌរដ្ឋបាលជលផលកណ្តាល | |
| ៩០ | លោក ហេង សុភារិទ្ធ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកណ្តាល | |
| ៩១ | លោក វ៉ិត ធាឫទ្ធិ | - | នាយ រងខណ្ឌរដ្ឋបាលជលផលកណ្តាល | |
| ៩២ | លោក ជុង សុភា | - | នាយ រងខណ្ឌរដ្ឋបាលជលផលបាត់ដំបង | |
| ៩៣ | លោក មិត្រ សុខសុភ័ក្រ | - | នាយ រងខណ្ឌរដ្ឋបាលជលផលបាត់ដំបង | |
| ៩៤ | លោក គង់ សុខា | - | នាយ រងខណ្ឌរដ្ឋបាលជលផលបាត់ដំបង | |
| ៩៥ | លោក ជ្រេន វន្ត | - | មន្ត្រីការិយាល័យនីតិកម្ម និងវិវាទ | |
| ៩៦ | លោកស្រី វិបុល សុភាព | ស្រី | មន្ត្រីការិយាល័យនីតិកម្ម និងវិវាទ | |
| ៩៧ | លោក ភ័ន់ ភា | ប្រុស | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ | |
| ៩៨ | លោក ប៉ែន ភារិន | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ | |
| ៩៩ | លោក ម៉ែន វិបុល | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ | |
| ១០០ | លោក អ៊ុន បូរ៉ា | ប្រុស | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលចតុមុខ | |
| ១០១ | លោក ប៊ុយ ឃាង | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០២ | លោក ចាន់ សុវត្ថា | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០៣ | លោក ហុក ប៊ុនថុន | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០៤ | លោក ញ៉ុញ អ៊ុក | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០៥ | លោក អំ អឿន | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០៦ | លោក អ៊ុច ចំណាប់ | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០៧ | លោក អ៊ុង យុទ្ធា | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០៨ | លោក កើត គា | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ | |
| ១០៩ | លោក ប៉ែន សារ៉េង | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលមេគង្គ | |
| ១១០ | លោក ធី វត្ថា | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប | |
| ១១១ | លោក ទ្រឹង គាំងលី | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប | |
| ១១២ | លោក ជាម ប៉ង | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប | |
| ១១៣ | លោក ឈិន តូ | - | មន្ត្រីអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប | |

Downloaded from http://www.khmerlaws.com

| | | | | |
|---|---|---|---|---|
| ១១៤ | លោក ជិន ចាន់ថន | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ | |
| ១១៥ | លោក កែ សារី | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ | |
| ១១៦ | លោក ធិនទី សុទ្ធី | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលសៀមរាប | |
| ១១៧ | លោកស្រី ហែម វណ្ណារ៉េត | ស្រី | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ចាម | |
| ១១៨ | លោក ជុំ វិទ្ធិវុឌ្ឍ | ប្រុស | មន្ត្រីខណ្ឌរដ្ឋបាលជលផលព្រៃវែង | |
| ១១៩ | លោក ម៉ៅ ប៊ុនធឿន | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ចាម | |
| ១២០ | លោក សោម ភា | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលតាកែវ | |
| ១២១ | លោក យុត ឧណ្ណា | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលតាកែវ | |
| ១២២ | លោក ទឹម ប៊ុនថន | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលតាកែវ | |
| ១២៣ | លោក សួន សុម៉ៅ | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ | |
| ១២៤ | លោក ឡៅ នុលលី | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកោះកុង | |
| ១២៥ | លោក ឈ ប៊ុនឈង់ | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកោះកុង | |
| ១២៦ | លោក យិន តាំងស៊ុ | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ធំ | |
| ១២៧ | លោក ជា វ៉ាន់ភី | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ធំ | |
| ១២៨ | លោក ឡៅ ថា | ប្រុស | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់សោម | |
| ១២៩ | លោក ណឹប ស៊ីថា | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់សោម | |
| ១៣០ | លោក ឡៅ សុផានរិទ្ធ | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលភ្នំពេញ | |
| ១៣១ | លោក ឯម វណ្ណារិទ្ធ | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលភ្នំពេញ | |
| ១៣២ | លោក យុន វ៉េហា | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពត | |
| ១៣៣ | លោក ហោ ជា | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពត | |
| ១៣៤ | លោក អ៊ុង ជីតោ | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង | |
| ១៣៥ | លោក ពុំ សុផល | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ឆ្នាំង | |
| ១៣៦ | លោក យឹម ពេញ | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលកណ្តាល | |
| ១៣៧ | លោកស្រី អ៊ូ សុធា | ស្រី | មន្ត្រីខណ្ឌរដ្ឋបាលជលផលកណ្តាល | |
| ១៣៨ | លោក ម៉េង សុថៃ | ប្រុស | មន្ត្រីខណ្ឌរដ្ឋបាលជលផលបាត់ដំបង | |
| ១៣៩ | លោក កក អ៊ីខ្សែន | - | មន្ត្រីខណ្ឌរដ្ឋបាលជលផលបាត់ដំបង | |

Downloaded from http://www.khmerlaws.com

**ប្រការ ២ :**

- ចំពោះមន្ត្រីនគរបាលយុត្តិធម៌ជលផលថ្នាក់កណ្តាល : មានសមត្ថកិច្ចដែនដីនៅលើវិសាលភាពទូទាំងព្រះរាជាណាចក្រកម្ពុជា ។

- ចំពោះមន្ត្រីនគរបាលយុត្តិធម៌ជលផលថ្នាក់អធិការដ្ឋាន និងខណ្ឌរដ្ឋបាលជលផល : មានសមត្ថកិច្ចដែនដីនៅលើវិសាលភាពទៅលើមណ្ឌលរដ្ឋបាលដែលមន្ត្រីនោះត្រូវចាត់តាំងឱ្យទៅបំរើការងារ លើកលែងតែការពន្លាតសមត្ថកិច្ចដែនដីដែលមានចែងក្នុងមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**ប្រការ ៣ :**

មន្ត្រីដូចបានតែងតាំងក្នុងប្រការ១ និងប្រការ២ខាងលើ នឹងទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនស្របតាមនីតិវិធីដូចមានចែងនៅក្នុងច្បាប់ស្តីពីជលផល និងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤ :**

សាមីខ្លួនដូចមានឈ្មោះក្នុងប្រការ ១ និងប្រការ ២ និងស្ថាប័នពាក់ព័ន្ធទាំងអស់មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០០៨

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ចាន់ សារុន

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ វង្សវឌ្ឍនា

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- តុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- សាលាដំបូង និងអយ្យការអមសាលាដំបូងខេត្ត-ក្រុង
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

Downloaded from http://www.khmerlaws.com

# គម្រូ

# ស្ដីពី

# សម្បថ

## ឧបសម្ព័ន្ធ
## នីតិវិធីក្នុងការធ្វើសម្បថ

ការធ្វើសច្ចាប្រណិធាន ត្រូវដឹកនាំដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិ នៅទីកន្លែងនៃតុលាការនីមួយៗ ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូប បូជាចំពោះវត្ថុសក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ ។ បន្ទាប់មកក្រឡាបញ្ជីត្រូវអានប្រាប់ព្វាទខ្លាំងៗ ច្បាស់ៗ ឱ្យអ្នកស្បថស្តាប់ រួចអាន **ពាក្យសច្ចាប្រណិធាន** ឱ្យអ្នកស្បថ ថាតាម ។

ក្រោយពីធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ បញ្ជាក់ថា បានធ្វើត្រឹមត្រូវហើយ សេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណា ត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

### ប្រណិធាន

បពិត្រអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា និងបារមីដ៏សក្តិសិទ្ធិ មានព្រះអង្គដងកើរ ព្រះអង្គ ក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតា ក្រហមក លោកតាដំបងដែក លោកតាដំបងក្រញូង លោកយាយទេព ព្រះអង្គវិហារសួគ៌ ព្រះអង្គព្រះ ជីវិវត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្មែង ជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតី ក្នុងពិធីសម្បថនេះ ស្បិតក្តីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថាជាអ្នកបានដឹង បានឃើញ បានឮ និងបានចាំដោយផ្ទាល់ ហើយច្បាប់តម្រូវឱ្យយកអ្នកទាំងនេះ មកធ្វើជាសាក្សី ឱ្យឆ្លើយឱ្យបានទៀងត្រង់តាមពិត ។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឮ និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីដ៏សក្តិសិទ្ធិ បំផ្លាញឱ្យលាញឱ្យស្លាប់តែហោង យ៉ាងវេទនា ដោយគ្រាប់កាំភ្លើង ខ្សែភ្លើងឆក់ វន្ទះបាញ់ ខ្លាខាំពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាមខ្សត់ទ្រព្យ វង្វេងទុក្ខវេទនា អស់ប្រាំរយជាតិ ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលំអៀង

ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្ជាច ព្រោះស្អប់ ព្រោះលោភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្សអ្នកតា យាយទេព និងបារមីឫទ្ធិសក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រលាញ់ រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើនថ្កុំថ្កើង រុងរឿង សមដូចសេចក្តី បំណាងប៉ងប្រាថ្នា កុំបីអាក់ខានឡើយ ។

## ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិត ដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំថ្នាល់ ។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្សអ្នកតា និងបារមីឫទ្ធិសក្តិសិទ្ធិទាំងអស់ បរាមុខខ្ញុំ ឱ្យវិនាសហោញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន ញាតិផៅសន្តាន ជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ ។

# គម្រូ

# សញ្ញាបត្រ

# និង

# វិញ្ញាបនបត្រ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ

# សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ **៩២១ ឥ.ស** របស់អគ្គស្នងការដ្ឋាននគរបាលជាតិ. ចុះថ្ងៃទី **១១** ខែ **កញ្ញា** ឆ្នាំ ២០០៧ ស្តីពីមន្ត្រីនគរបាលដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦០ និងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : ........................ កើតថ្ងៃទី ........ ខែ ........ ឆ្នាំ ........

ឋានន្តរសក្តិ ........................ អត្តលេខ ........................ ឋានៈ ........................

អង្គភាព : **នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌**

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

សំរាប់ទទួល **សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌**

ចេញជូន : ........................

នូវសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

លេខ: ន.ប.យ.ខ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

អង្គ វង្សវឌ្ឍនា

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាភូមិន្ទនគរបាល

# វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា

## នាយកសាលាភូមិន្ទនគរបាល

# CERTIFICAT DE SCOLARITE

**Le Directeur de l'Ecole Royale de Police**

បញ្ជាក់ថា:.................................................កើតថ្ងៃទី...........................................នៅ.........................ភ្នំពេញ..........................

**Certifie que**.................................................**né(e)le**...........................................**à**.........................Phnom Penh..........................

បានរៀនចប់វគ្គ.........បណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌.........................និទ្ទេស.................................នៅសាលាភូមិន្ទនគរបាល

**a suivi le starge**.........Classe de formation des Policiers Judiciers......... **Mention**.................................**à l'Ecole Royale de police**

ចាប់ពីថ្ងៃទី...២០....ខែ.....មិថុនា.......ឆ្នាំ២០០.៧....ដល់ថ្ងៃទី..២២....ខែ......មិថុនា.....ឆ្នាំ២០០.៧....។

**du**.....................20 June 2007..................... **au**..........................22 June 2007..........................

វិញ្ញាបនប័ត្រនេះត្រូវបានចេញឱ្យសាមីជនដើម្បីប្រើប្រាស់ តាមការដែលអាចប្រើបាន។

**Le présent certificat lui est délivré pour servir et valoir ce que de droit.**

រាជធានីភ្នំពេញ, ថ្ងៃទី..២០.....ខែ[illegible]...ឆ្នាំ២០០៧

លេខ:........................

**Phnom Penh, le**..................................

**នាយកសាលាភូមិន្ទនគរបាល**

**Le directeur de l'Ecole Royale de Police**

ឧត្តមសេនីយ៍ឯក.ម៉ៅ_លឿន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

ក្រសួងយុត្តិធម៌

# សញ្ញាប័ត្រជាន់ខ្ពស់នគរបាលយុត្តិធម៌

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

បានឃើញលិខិតលេខ ២៥០/២០១១ ស.ណក របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ ស្តីពីមន្ត្រីកងរាជអាវុធហត្ថដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដូចបានចែងក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

បញ្ជាក់ថា : **លោក ម៉ាំង សុខលុច** កើតថ្ងៃទី **០៥** ខែ **កក្កដា** ឆ្នាំ **១៩៨០**

ឋានន្តរស័ក្តិ **វរសេនីយ៍ត្រី** អត្តលេខ **១០៨ ៣៦៥** មុខតំណែង **ជំនួយការ ការិយាល័យសន្តិសុខ**

អង្គភាព : **មន្ទីរព័ត៌មាន និងសន្តិសុខ បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ**

បានបំពេញគ្រប់លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ដែលមានចែងនៅក្នុងមាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សំរាប់ទទួល

សញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

ចេញជូន : **លោកវរសេនីយ៍ត្រី ម៉ាំង សុខលុច** ទុកសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌នេះដើម្បីប្រើប្រាស់តាមការដែលអាចប្រើបាន ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១១

លេខ **០៧៣៩/១១** ន.ប.យ.ន.អ.ហ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការពារជាតិ

នាយឧត្តមសេនីយ៍.ទៀ-បាញ់

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ.វង្សវឌ្ឍនា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រ

## វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ជំនាន់ទី ១៦

**បញ្ជាក់ថា :** លោកវរសេនីយ៍ត្រី **ម៉ាំង សុខលុច** អត្តលេខ ១០៨ ៣៦៥

តួនាទីជំនួយការការិយាល័យសន្តិសុខ អ.ហ រាជធានី

**បានបញ្ចប់ : វគ្គបណ្តុះបណ្តាលមន្ត្រីនគរបាលយុត្តិធម៌ ជំនាន់ទី ១៦**

ពីថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ២០១១ ដល់ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

ភ្នំពេញ,ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១១

**មេបញ្ជាការ**

លេខ:.....៣៩..../ស.ស.រ.
/២០១១

នាយឧត្តមសេនីយ៍ សៅ សុខា